ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# របាយការណ៍ការប៉ាន់ប្រមាណស្តីពី
# សមត្ថភាព និងដំណើរការនៃប្រព័ន្ធសុំកូនក្នុងប្រទេស
# និងអន្តរប្រទេសរបស់កម្ពុជា

unicef

for every child

**យូនីសេហ្វ (UNICEF) កម្ពុជា**
**ខែកញ្ញា ឆ្នាំ២០២៥**

**© United Nations Children’s Fund (UNICEF), Cambodia**

**កញ្ញា ២០២៥**

ការសិក្សាស្រាវជ្រាវនេះត្រូវបានសិក្សាដោយ លោកស្រីបណ្ឌិត គ្រីសស្ទិន អ៊ី ឆេននីយ៍ (Kristen E. Cheney, PhD), លោកស្រីបណ្ឌិត ខារិន អែស រ៉ូថាប៊ី ខាសារេស (Karen S. Rotabi-Casares, PhD), លោកស្រី សួង សុខសោភា, លោកស្រី លីហ្សា លីស្ទឺរ (Leisha Lister) ដែលជាទីប្រឹក្សាអន្តរជាតិផ្នែកច្បាប់, និងលោកស្រី វីម៉ាឡា គ្រីស្ពីន (Vimala Crispin)។ របាយការណ៍នេះត្រូវបានប្រគល់ឱ្យធ្វើដោយយូនីសេហ្វប្រចាំកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយបានអនុញ្ញាតឱ្យ ឆាលដ៍ ហ្វ្រន់ធារស៍ (Child Frontiers) ជាស្ថាប័នទទួលបន្ទុកធ្វើកិច្ចការងារនេះនៅក្នុងឆ្នាំ២០២៥។ គំនិតយោបល់ និងសេចក្តីថ្លែងនានាដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺមិនតំណាងឱ្យគំនិតយោបល់របស់យូនីសេហ្វឡើយ។ រាល់កិច្ចខិតខំប្រឹងប្រែងនានាគឺដើម្បីធានាថាព័ត៌មានដែលបង្ហាញក្នុងរបាយការណ៍នេះ គឺពិតប្រាកដមែន នៅក្នុងអំឡុងពេលសរសេររបាយការណ៍នេះ។

**Child Frontiers Ltd.**
Suite A 15/F Hillier Commercial Building
65-67 Bonham Strand East
Sheung Wan, Hong Kong

Child Frontiers is a registered company (No. 1275515)

CHILD FRONTIERS

## មាតិកា


**សេចក្តីថ្លែងអំណរគុណ** ..... ៣

**ពាក្យកាត់** ..... ៥

**សេចក្តីសង្ខេប** ..... ៦

**១. សេចក្តីផ្តើម** ..... ១១

*ការពិពណ៌នាអំពីការសិក្សា* ..... ១២

**២. សាវតាស្តីពីសុំកូន** ..... ១៣

*ការអនុវត្តបែបបុរាណ* ..... ១៣

*សុំកូនអន្តរប្រទេស* ..... ១៤

*ការដកកុមារចេញពីមណ្ឌលថែទាំ និងកំណែទម្រង់ការថែទាំ* ..... ១៧

*គោលនយោបាយថ្មីៗស្តីពីកិច្ចការពារកុមារ និងការលើកកម្ពស់សុំកូនក្នុងប្រទេស* ..... ១៩

*ក្របខណ្ឌការងារផ្នែកច្បាប់សម្រាប់សុំកូនក្នុងប្រទេសកម្ពុជា* ..... ២២

*សុំកូនក្នុងប្រទេស* ..... ២២

*សុំកូនអន្តរប្រទេស* ..... ២៣

*អន្តរទំនាក់ទំនងនៅក្នុងនិយ័តកម្មសុំកូន* ..... ២៤

**៣. ទស្សនៈ/ផ្នែកសង្គម** ..... ២៥

**៤. ទស្សនៈសម្រាប់រដ្ឋាភិបាល/អង្គការមិនមែនរដ្ឋាភិបាល** ..... ៣១

*ភាពខ្វះចន្លោះផ្នែកចំណេះដឹង* ..... ៣១

*ការសម្របសម្រួល ការសហការ និងនិរន្តរភាព* ..... ៣៣

*សហប្រតិបត្តិការ និងការសម្របសម្រួលអន្តរក្រសួង* ..... ៣៦

*គម្លាតផ្នែកច្បាប់* ..... ៣៨

*សុំកូនក្នុងប្រទេស* ..... ៣៨

នីតិវិធីមិនច្បាស់លាស់សម្រាប់ការមើលថែការពារ ..... ៣៩

សមត្ថកិច្ចរបស់មណ្ឌលថែទាំ ..... ៤០

ការចុះបញ្ជី និងការពិនិត្យតាមដានលើមណ្ឌលថែទាំ ..... ៤១

មិនមានសង្គតិភាពក្នុងភាពជាអាណាព្យាបាល ..... ៤១

*សុំកូនអន្តរប្រទេស* ..... ៤៣

*ការរក្សាកំណត់ត្រា និងការគ្រប់គ្រងករណី* ..... ៤៩

*ការចុះបញ្ជីកំណើត និងការរក្សាអត្តសញ្ញាណ* ..... ៥០

*ការគ្រប់គ្រងករណីការងារសង្គម* ..... ៥២

*ការកសាងសមត្ថភាព* ..... ៥៥

*ការចូលរួមរបស់កុមារ* ..... ៥៧

**៥. សង្ខេប** ..... ៥៩

*សុំកូនក្នុងប្រទេស* ..... ៥៩

*ស្តុំកូនអន្តរប្រទេស*........................................................................................................................៥៩
*អនុសាសន៍ទូទៅ*........................................................................................................................៦០
*ធនធាន*........................................................................................................................៦០
*សន្និដ្ឋាន*........................................................................................................................៦១

ឧបសម្ព័ន្ធ៖ ឯកសារទទួលបានពីការពិភាក្សានៅក្នុងសិក្ខាសាលាពិនិត្យផ្ទៀងផ្ទាត់ **..............................................៦២**

# សេចក្តីថ្លែងអំណរគុណ

ការសុំកូនក្នុងប្រទេសត្រូវបានអនុវត្តផ្អែកលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (២០០៧) សម្រាប់ការសុំកូនក្នុងប្រទេស និងច្បាប់ស្តីពីការសុំកូនអន្តរប្រទេស (២០០៩) និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ (២០១១)។ ដើម្បីផ្តល់ជាមូលដ្ឋានព័ត៌មានសម្រាប់ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងនីតិវិធីពាក់ព័ន្ធនឹងសុំកូនទាំងនេះ អង្គការយូនីសេហ្វប្រចាំកម្ពុជា បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជ្រើសរើសស្ថាប័ន Child Frontiers សិក្សាស្តីពី"**ការប៉ាន់ប្រមាណអំពីសមត្ថភាព និងដំណើរការនៃប្រព័ន្ធសុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស**"។ របកគំហើញ និងអនុសាសន៍នៃការសិក្សាស្រាវជ្រាវនេះនឹងផ្តល់ជាមូលដ្ឋានព័ត៌មានសម្រាប់ដាក់ចេញនូវផែនការសកម្មភាពក្នុងការអនុវត្តការងារសុំកូន គោរពតាមគោលការណ៍ មនុស្សធម៌ សមធម៌ តម្លាភាព និងគណនេយ្យភាព ដើម្បីធានាថា កុមារទទួលបាននូវសុខុមាលភាព និងកិច្ចការពារពេញលេញ។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការយូនីសេហ្វ (UNICEF) ប្រចាំកម្ពុជា ដែលបានគាំទ្រថវិកាសម្រាប់ការសិក្សាស្រាវជ្រាវ និងអគុណចំពោះស្ថាប័ន ឆាលហ្វ្រន់ធារស៍ (Child Frontiers) ដែលបានរៀបចំរបាយការណ៍ប៉ាន់ប្រមាណដ៏មានសារៈសំខាន់នេះ។ ជាមួយគ្នានេះ ខ្ញុំសូមកោតសរសើរចំពោះថ្នាក់ដឹកនាំការងារសុំកូនរបស់ក្រសួង រួមមាន **ឯកឧត្តម ម៉ែន សុចិត្រ** រដ្ឋលេខាធិការ **ឯកឧត្តម ហាច ហ៊ាន** អនុរដ្ឋលេខាធិការ និង**ឯកឧត្តម អ៊ុំ សុផាន់ណារ៉ា** អគ្គនាយកដ្ឋានសេវាសង្គមកិច្ច ព្រមទាំងមន្ត្រីជំនាញនាយកដ្ឋានកិច្ចការពារកុមារ ដែលបានដឹកនាំ និងពិនិត្យផ្តល់យោបល់លើដំណើរការ និងខ្លឹមសាររបាយការណ៍នៃការសិក្សាស្រាវជ្រាវនេះឱ្យទទួលបានលទ្ធផលគួរទីគាប់ប្រសើរ។ ទន្ទឹមគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះក្រសួងយុត្តិធម៌ ក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធដែលបានផ្តល់ជាតុចូល ចែករំលែកបទពិសោធន៍ និងគំរូនៃការអនុវត្តល្អៗ ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍នៃការសិក្សានេះឱ្យបានល្អប្រសើរ និងជ្រុងជ្រោយ។

ខ្ញុំសូមលើកទឹកចិត្តដល់នាយកដ្ឋាន អង្គភាពជំនាញ អង្គការដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់ ធ្វើការរួមគ្នាក្នុងការកសាងផែនការឆ្លើយតបទៅនឹងអនុសាសន៍នៃការសិក្សាស្រាវជ្រាវនេះ ដើម្បីធានាថាការអនុវត្តសុំកូននៅកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

ថ្ងៃ ពុធ ១រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០២៥

រដ្ឋមន្ត្រី

ជា_សុមេធី

# ពាក្យកាត់

| | |
|---|---|
| BAKC | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| CRVSID | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម |
| CSO | អង្គការសង្គមស៊ីវិល |
| DoSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (រាជធានី ខេត្ត) |
| HCIA | អនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេស |
| ICA | ការសុំកូនអន្តរប្រទេស |
| ICAA | រដ្ឋបាលនៃការសុំកូនអន្តរប្រទេស |
| INGO | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ថ្នាក់ជាតិ) |
| MoU | អនុសារណៈយោគយល់គ្នា |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NCPC | គណៈកម្មការជាតិដើម្បីកិច្ចការពារកុមារ |
| OSCaR | Open Source Case-management and Record-keeping |
| PAP | Prospective adoptive parent |
| RCI | Residential care institution |
| SASWO | ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមស្រុក |
| SSWF | កម្លាំងសេវាសង្គម |

# សេចក្តីសង្ខេប

របាយការណ៍នេះបង្ហាញពីការសិក្សាប៉ាន់ប្រមាណឯករាជ្យអំពីប្រព័ន្ធសុំកូនក្នុងប្រទេស និងអន្តរប្រទេសរបស់កម្ពុជា ដោយផ្តោតលើវឌ្ឍនភាពរបស់កម្ពុជាក្នុងការបន្សុីការអនុវត្តសុំកូនទៅនឹងបទដ្ឋានអន្តរជាតិ ដើម្បីកិច្ចការពារកុមារ និងកិច្ចថែទាំជំនួសដោយផ្អែកលើការថែទាំនៅក្នុងគ្រួសារជាចម្បង។ ដោយមានការជឿទុកចិត្តប្រគល់កិច្ចការសិក្សានេះពីយូនីសេហ្វ (UNICEF) ប្រចាំកម្ពុជា ក្រោមកិច្ចសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការសិក្សាប៉ាន់ប្រមាណនេះ គឺសិក្សាវាយតម្លៃលើសមត្ថភាព វឌ្ឍនភាព និងក្របខណ្ឌច្បាប់សម្រាប់អភិបាលការសុំកូននាពេលបច្ចុប្បន្ន ព្រមទាំងផ្តល់នូវអនុសាសន៍ក្នុងការពង្រឹងប្រព័ន្ធនៅក្នុងបរិបទដែលមានរបៀបវារៈអំពីការធ្វើកំណែទម្រង់កម្មវិធីថែទាំជាបន្តបន្ទាប់របស់កម្ពុជា។

គោលដៅរួមទូទៅរបស់ការសិក្សាប៉ាន់ប្រមាណនេះ គឺដើម្បីផ្តល់នូវព័ត៌មានជាជំនួយស្មារតីដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការអនុវត្តនីតិវិធីសុំកូនដែលមានចែងនៅក្នុងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤។

## របកគំហើញសំខាន់ៗ

កម្ពុជាបានបោះជំហានទៅមុខដ៏គួរឱ្យកត់សម្គាល់ ក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធកិច្ចការពារកុមារ និងប្រព័ន្ធសុំកូនរបស់ខ្លួន ក្នុងអំឡុងពេលជាងពីរទសវត្សរ៍កន្លងមកនេះ។ រាជរដ្ឋាភិបាលបានធ្វើការយ៉ាងជិតស្និទ្ធជាពិសេសជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើតនូវមូលដ្ឋានគ្រឹះនៃក្របខណ្ឌច្បាប់ និងគោលនយោបាយដោយចាត់អាទិភាពទៅលើសិទ្ធិនិងសុខុមាលភាពរបស់កុមារជាចម្បង។ ចំណុចដៅសំខាន់ៗនៃនីតិបញ្ញត្តិរួមមាន ការផ្តល់សច្ចាប័នអនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេស (HCIA) ឆ្នាំ២០០៧ ការអនុម័តច្បាប់ស្តីពីការសុំកូនអន្តរប្រទេសឆ្នាំ២០០៩ និងការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤ ដែលបានសង្កត់ធ្ងន់ពីការថែទាំនៅតាមគ្រួសារជាចម្បង និងសុំកូនក្នុងប្រទេស ហើយការការទុកដាក់កុមារនៅក្នុងមណ្ឌល ជាជម្រើសចុងក្រោយ និងបណ្តោះអាសន្ន ទន្ទឹមនឹង ការសុំកូនអន្តរប្រទេសធ្វើទៅបាន លុះត្រាតែការស្វែងរកសុំកូនក្នុងប្រទេសអស់លទ្ធភាព។

ទោះបីជា មានការរីកចម្រើនទាំងនេះក្តី ក៏ការប៉ាន់ប្រមាណកំណត់រកឃើញថា នៅតែមានបញ្ហាប្រឈមកើតមានឡើងជាបន្តបន្ទាប់ដូចខាងក្រោម ដែលធ្វើឱ្យរាំងស្ទះដល់ប្រសិទ្ធភាពនៃការអនុវត្តសុំកូន រួមមាន៖

- **ភាពខ្វះចន្លោះនៃច្បាប់ និងគោលនយោបាយ៖** ខណៈដែលក្របខណ្ឌនីតិបញ្ញត្តិមានភាពប្រសើរឡើង ភាពចកល្វែងនៅតែមានក្នុងការអនុវត្ត និងប្រតិបត្តិការច្បាប់ និងគោលនយោបាយ ជាពិសេសពាក់ព័ន្ធនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស និងនីតិវិធីសុំកូន។
- **កង្វះធនធាន៖** ភាពមានកម្រិតនៃធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ក៏ដូចជា ហេដ្ឋារចនាសម្ព័ន្ធសេវាសង្គមដែលមិនទាន់បានអភិវឌ្ឍ គឺរាំងដល់សមត្ថភាពរបស់ទីភ្នាក់ងាររដ្ឋាភិបាល និងអ្នកផ្តល់សេវាសង្គមកិច្ច ក្នុងការផ្តល់សេវាសុំកូន និងកិច្ចការពារកុមារដែលប្រកបដោយគុណភាព។

- **សមត្ថភាព និងការបណ្តុះបណ្តាល៖** មានតម្រូវការក្នុងការពង្រឹងការបណ្តុះបណ្តាល និងវិជ្ជាជីវៈរបស់កម្លាំងសេវាសង្គម រួមទាំងការទទួលស្គាល់ជាផ្លូវការនូវគុណភាពសិក្សា និងអាជ្ញាបណ្ណ ដើម្បីធានាថាអ្នកទទួលភារកិច្ច ត្រូវបានបំពាក់នូវការគ្រប់គ្រងចាត់ចែងលើករណីស្មុំកូនដែលមានភាពស្មុគស្មាញ ដោយស្របទៅតាមការអនុវត្តដែលល្អបំផុតនានា។
- **ការសម្របសម្រួល និងគ្រប់គ្រងត្រួតពិនិត្យទូទៅ៖** ការសម្របសម្រួលដែលបែកខ្ញែកពីគ្នារវាងស្ថាប័នជាសេនាធិការរបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ក៏ដូចជាភាពខ្វះចន្លោះនៃយន្តការពិនិត្យតាមដាន និងវាយតម្លៃ គឺធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃដំណើរការស្មុំកូន និងអន្តរាគមន៍នៃកិច្ចការពារកុមារ។

## បរិបទប្រវត្តិសាស្ត្រ និងកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់

យោងតាមប្រវត្តិសាស្ត្រ ប្រព័ន្ធស្មុំកូនរបស់កម្ពុជា គឺមានចរិតលក្ខណៈជាការរៀបចំមិនផ្លូវការឱ្យមានការថែទាំដោយក្រុមគ្រួសារ ដោយមានសាច់ញាតិ និងសហគមន៍ស្ម័គ្រចិត្តមើលថែទាំកុមារដែលត្រូវការការថែទាំ។ ប៉ុន្តែការកើនឡើងនូវការស្មុំកូនអន្តរប្រទេសក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ផ្ទួបនឹងកំណើននៃមណ្ឌលថែទាំ និងទេសចរណ៍ទៅមណ្ឌលកុមារកំព្រា បានធ្វើឱ្យរីកសាយនូវក្តីបារម្ភអំពីការជួញដូរកុមារ ការរកប្រាក់ចំណេញខុសច្បាប់ និងការទុកដាក់កុមារនៅក្នុងមណ្ឌលទោះក្នុងលក្ខខណ្ឌមិនចាំបាច់។ នៅពេលដែលអវត្តមានក្របខណ្ឌច្បាប់និងគោលនយោបាយសម្រាប់ធ្វើនិយ័តកម្មចំពោះការស្មុំកូនអន្តរប្រទេស ប្រទេសកម្ពុជាក៏បានក្លាយជា «ប្រទេសគោលដៅសម្រាប់ស្មុំកូនអន្តរប្រទេស» យ៉ាងឆាប់រហ័ស ដោយមានកិត្តិស័ព្ទថាអាចស្មុំកូនបានលឿន និងមានទារកដែលមានសុខភាពល្អ។ បញ្ហាទាំងនេះបានធ្វើឱ្យមានការផ្អាកស្មុំកូនអន្តរប្រទេសនៅឆ្នាំ២០០០ និងការធ្វើកំណែទម្រង់ដែលមានគោលបំណងលើកស្ទួយការថែទាំនៅតាមគ្រួសារ និងពង្រឹងសុវត្ថិភាពផ្លូវច្បាប់ប្រឆាំងនឹងការកេងប្រវ័ញ្ច។ នេះបានបង្កើននូវក្តីព្រួយបារម្ភពីសំណាក់អ្នកជំនាញការផ្នែកកិច្ចការពារកុមារ ដែលបានកំណត់ឃើញថា ឪពុកម្តាយត្រូវបានល្បួងឱ្យបោះបង់ចោលកូនរបស់ខ្លួន តាមរយៈការផ្តល់ជាប្រាក់ផ្ទាល់ ឬការសន្យាថានឹងផ្តល់ការអប់រំ ការថែទាំសុខភាព និងសេវាផ្សេងៗទៀត។

កម្មវិធីកំណែទម្រង់ការថែទាំជំនួសចំពោះកុមាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦ បានដាក់ចេញគោលដៅកាត់បន្ថយចំនួនមណ្ឌល និងចំនួនកុមាររស់នៅក្នុងមណ្ឌលថែទាំ ដោយការធ្វើសមាហរណកម្មទៅរស់នៅក្នុងគ្រួសារ និងសហគមន៍ ព្រមទាំងលើកការថែទាំកុមារនៅក្នុងគ្រួសារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ ទោះជាយ៉ាងនេះក្តី ក៏កត្តាប្រឈមនៅតែមាន រួមទាំងការអនុវត្តការធ្វើសមាហរណកម្មដែលគ្មានសង្គតិភាព និងការបន្តជះឥទ្ធិពលរបស់បណ្តាញបែប «ចៅហ្វាយនាយនិងអតិថិតានិយម» (clientelism and patronage networks) ដែលសម្របសម្រួលការជ្រើសរើស និងការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំ ដើម្បីផលប្រយោជន៍ខ្លួន។

## ការអភិវឌ្ឍគោលនយោបាយថ្មីៗ

គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤ គឺជាការផ្លាស់ប្តូរដ៏សំខាន់មួយ របស់កម្ពុជាចំពោះសុខុមាលភាពនិងកិច្ចការពារកុមារកុមារ ការចាត់អាទិភាពលើការថែរក្សាកុមារក្នុងគ្រួសារ ការថែទាំ

កុមារតាមគ្រួសារ និងការសុំកូនក្នុងប្រទេស ដែលជាជម្រើសដ៏ល្អសម្រាប់កុមារដែលពុំមានឪពុកម្ដាយថែទាំ។ គោលនយោបាយនេះ គឺស្របគ្នានឹងអនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេស (HCIA) និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការថែទាំជំនួសចំពោះកុមារ (UN Guidelines on Alternative Care for Children) ព្រមទាំងស្វែងរកនូវការធ្វើបច្ចុប្បន្នភាព និងសុខដុមនីយកម្មបទដ្ឋាន និងនីតិវិធីដែលមានស្រាប់សម្រាប់ការថែទាំជំនួស និងសុំកូន។ ប៉ុន្តែប្រសិទ្ធភាពនៃការអនុវត្តគឺតម្រូវឱ្យមានការវិនិយោគប្រកបដោយចីរភាព ក្នុងការកសាងសមត្ថភាព ហេដ្ឋារចនាសម្ព័ន្ធ និងការសម្របសម្រួលឆ្លងវិស័យ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានខិតខំធ្វើការដើម្បីពង្រឹងវិជ្ជាជីវៈដល់កម្លាំងសេវាសង្គម តាមរយៈការផ្តល់នូវការទទួលស្គាល់គុណភាពនៃការអប់រំជាផ្លូវការ និងការផ្តល់អាជ្ញាបណ្ណ ក្នុងការជួយកុមារនិងគ្រួសារ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះគឺស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយទេ។

## អនុសាសន៍

ដើម្បីឱ្យការសុំកូនមានសុវត្ថិភាព និងប្រសិទ្ធភាព ចាំបាច់ត្រូវតែមានប្រព័ន្ធកិច្ចការពារកុមារមួយដែលមានដំណើរការ មានប្រសិទ្ធភាព ផ្អែកលើសិទ្ធជាចម្បង និងមានបរិយាប័ន្ន។ ដូចនេះការប៉ាន់ប្រមាណគឺត្រូវបានដឹកនាំដោយភាពចាំបាច់ក្នុងការធ្វើបរិវត្តកម្ម **ការសុំកូននៅក្នុងការថែទាំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយពេញលេញ** (ដែលរាប់ពីសេវានានា និងកិច្ចអន្តរាគមន៍ផ្សេងៗដែលតាក់តែងឡើងសម្រាប់គាំទ្រកុមារឱ្យនៅក្នុងគ្រួសារ) **ដែលជាផ្នែកមួយនៃប្រព័ន្ធកិច្ចការពារកុមារដែលមានលក្ខណៈបង្រួបបង្រួមគ្នា និងគ្រប់ជ្រុងជ្រោយ។**

ការសិក្សានេះបានផ្តល់នូវអនុសាសន៍សំខាន់ៗមួយចំនួន ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានកំណត់រកឃើញ និងពង្រឹងបន្ថែមចំពោះប្រព័ន្ធសុំកូនរបស់កម្ពុជា៖

- **រក្សាការផ្អាកការសុំកូនអន្តរប្រទេស៖** បន្តផ្អាកសកម្មភាពសុំកូនអន្តរប្រទេសរហូតដល់មានយន្តការការពារសុវត្ថិភាព (safeguards) និងយន្តការគ្រប់គ្រងត្រួតពិនិត្យទូទៅដែលរឹងមាំ និងចាត់អាទិភាពក្នុងការពង្រឹងការសុំកូនក្នុងប្រទេស ដែលស្របនឹងបទដ្ឋានអន្តរជាតិ។
- **វិនិយោគលើការកសាងសមត្ថភាព៖** បង្កើនការវិនិយោគលើការបណ្តុះបណ្តាល ការផ្តល់ការទទួលស្គាល់គុណភាពអប់រំ និងវិជ្ជាជីវនីយកម្មសម្រាប់កម្លាំងសេវាសង្គម ដើម្បីធានាឱ្យមាននូវការគ្រប់គ្រងករណី និងកិច្ចការពារកុមារដែលប្រកបដោយប្រសិទ្ធភាព។
- **ពង្រឹងការសម្របសម្រួល៖** ការជំរុញឱ្យមានការអភិវឌ្ឍកិច្ចសហការដ៏ល្អរវាងទីភ្នាក់ងាររបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីសម្រួលដំណើរការសុំកូន និងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា។
- **ពង្រឹងការពិនិត្យតាមដាននិងវាយតម្លៃ៖** អភិវឌ្ឍ និងអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ ដើម្បីតាមដានមើលលទ្ធផល (outcomes) កំណត់រកចំណុចខ្វះចន្លោះ និងផ្តល់ជាគំនិតជំនួយស្មារតីសម្រាប់ធ្វើឱ្យគោលនយោបាយ និងការអនុវត្តមានភាពល្អប្រសើរឡើងជាបន្តបន្ទាប់។

- **ធ្វើបច្ចុប្បន្នភាពចំពោះបទដ្ឋាននិងគោលការណ៍ណែនាំ៖** កែសម្រួល និងធ្វើបច្ចុប្បន្នភាព**បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសនៅតាមសហគមន៍ចំពោះកុមារ** ឱ្យស្របនឹង**គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ** និងធានាថាមានសង្គតិភាពនៅក្នុងការអនុវត្តនៅទូទាំងប្រទេស។

## សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តដ៏គួរឱ្យកោតសរសើរក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធសុំកូន និងប្រព័ន្ធកិច្ចការពារកុមាររបស់ខ្លួន ដោយមាននូវវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍច្បាប់ និងគោលនយោបាយ ការមិនទុកដាក់កុមារនៅក្នុងមណ្ឌល និងកំណែទម្រង់ចំពោះការថែទាំ។ ប៉ុន្តែបញ្ហាប្រឈមគួរជាទីកត់សម្គាល់នៅតែមាន ក្នុងការយកគោលនយោបាយនោះទៅអនុវត្តជាក់ស្តែង ជាពិសេសក្នុងន័យវិភាជន៍ធនធាន ការកសាងសមត្ថភាព និងការគ្រប់គ្រងត្រួតពិនិត្យទូទៅប្រកបដោយប្រសិទ្ធភាព។ កិច្ចខិតខំប្រឹងប្រែងបន្តពង្រឹងការសុំកូនក្នុងប្រទេស ការបង្ការការបំបែកចេញដែលមានចាំបាច់ពីគ្រួសារ និងការធានាថាកុមារគ្រប់រូបរីកលូតលាស់ធំធាត់ដោយសុវត្ថិភាព និងនៅក្នុងបរិស្ថានគ្រួសារដែលបណ្តុះកុមារ គឺមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីទទួលបាននូវការគោរពសិទ្ធិកុមារ និងសម្រេចបាននូវលទ្ធផលនៃកិច្ចការពារកុមារដែលប្រកបដោយនិរន្តរភាពនៅកម្ពុជា។

## ១. សេចក្តីផ្តើម

ស្ថាប័ន Child Frontiers ត្រូវបានជ្រើសរើសដោយការិយាល័យប្រចាំប្រទេសកម្ពុជានៃអង្គការយូនីសេហ្វ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឱ្យធ្វើ «ការប៉ាន់ប្រមាណសមត្ថភាព និងដំណើរការនៃប្រព័ន្ធស្មុំកូនក្នុងប្រទេស និងស្មុំកូនអន្តរប្រទេសរបស់កម្ពុជា»។ បច្ចុប្បន្ន ការស្មុំកូនក្នុងប្រទេសត្រូវបានអនុវត្តផ្អែកលើ*ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)* សម្រាប់ការស្មុំកូនក្នុងប្រទេស និង*ច្បាប់ស្តីពីការស្មុំកូនអន្តរប្រទេស (២០០៩)* និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួស (២០១១)។ គោលបំណងទូទៅនៃការប៉ាន់ប្រមាណនេះគឺដើម្បីផ្តល់មូលដ្ឋានព័ត៌មានជូនដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីការស្មុំកូននៅក្នុងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤។ លទ្ធផលនៃការប៉ាន់ប្រមាណនេះនឹងផ្តល់មូលដ្ឋានព័ត៌មានសម្រាប់ការតាក់តែងកម្មវិធី ការអនុវត្តកម្មវិធី ការពិនិត្យតាមដាន និងការបង្កើតគោលនយោបាយ។

គោលបំណងជាក់លាក់រួមមាន៖

១) ប៉ាន់ប្រមាណ និងធ្វើផែនទីប្រព័ន្ធស្មុំកូនក្នុងប្រទេស និងស្មុំកូនអន្តរប្រទេសរបស់ប្រទេសកម្ពុជាដែលមានប្រតិបត្តិការបច្ចុប្បន្ននៅក្រោមប្រព័ន្ធកិច្ចការពារកុមារជាទូទៅ។

២) កំណត់អំពីចំណុចខ្វះខាតផ្នែកសមត្ថភាព និងវិស័យដែលត្រូវកែលម្អអនុលោមតាមបទដ្ឋានអន្តរជាតិ និងឧត្តមានុវត្តន៍អន្តរជាតិ

៣) អភិវឌ្ឍអនុសាសន៍ដើម្បីពង្រឹងប្រព័ន្ធស្មុំកូនក្នុងស្រុក និងស្មុំកូនអន្តរប្រទេសរបស់កម្ពុជា

៤) បញ្ជ្រាបការចូលរួមរបស់កុមារនៅក្នុងដំណើរការទាំងអស់នៃការពិគ្រោះយោបល់ កំណត់ចក្ខុវិស័យការអភិវឌ្ឍ និងការបង្កើតឯកសារជាស្ថាពរ។

ដើម្បីឱ្យស្មុំកូនមានសុវត្ថិភាព និងប្រសិទ្ធភាព ចាំបាច់ត្រូវមានប្រព័ន្ធកិច្ចការពារកុមារដែលដំណើរការបានល្អ មានប្រសិទ្ធភាព ផ្អែកលើសិទ្ធិ និងបរិយាប័ន្ន។ ហេតុដូច្នេះ ការប៉ាន់ប្រមាណនេះគឺដើរតាមគោលការណ៍ដាច់ខាតក្នុងការកំណត់បរិបទស្មុំកូននៅក្នុងបរិបទនៃការថែទាំគ្រប់ជ្រុងជ្រោយពេញលេញ (បណ្តាសេវា និងអន្តរាគមន៍នានា ត្រូវបានតាក់តែងឡើងដើម្បីគាំទ្រកុមារក្នុងគ្រួសារ) ដែលជាផ្នែកមួយនៃប្រព័ន្ធកិច្ចការពារកុមារដែលមានលក្ខណៈសព្វជ្រុងជ្រោយ និងរួមបញ្ចូលគ្រប់ទិដ្ឋភាព។ ការប៉ាន់ប្រមាណនេះក៏មានអនុសាសន៍អំពីវិធីដើម្បីពង្រឹងដំណើរការ ការប្រតិបត្តិ និងកម្មវិធីស្មុំកូនផងដែរ ក្នុងបំណងចូលរួមចំណែកដើម្បីពង្រឹងប្រព័ន្ធកិច្ចការពារកុមារ។ ការប៉ាន់ប្រមាណនេះគាំទ្រដល់រដ្ឋាភិបាលក្នុងការពង្រឹងសមត្ថភាព និងនីតិវិធី ដើម្បីគ្រប់គ្រងស្មុំកូន ជួយធានាឱ្យប្រព័ន្ធកិច្ចការពារកុមារមានភាពបន្សុីគ្នាជាមួយបទដ្ឋានអន្តរជាតិ និងឧត្តមានុវត្តន៍អន្តរជាតិទាំងនៅក្នុងការស្មុំកូនក្នុងប្រទេស និងស្មុំកូនអន្តរប្រទេស។

### ការពិពណ៌នាអំពីការសិក្សា

នៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង ក្រុមការងារប៉ាន់ប្រមាណបានសិក្សាពិនិត្យឯកសារពាក់ព័ន្ធនានារួមមានទាំងឯកសាររបស់រាជរដ្ឋាភិបាលផងដែរ។ ក្រុមត្រួតពិនិត្យបច្ចេកទេសមួយក្រុមដែលដឹកនាំដោយ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការរចនា និងការសម្របសម្រួលការប៉ាន់ប្រមាណនេះ រួមទាំងការផ្តល់យោបល់អំពីទីតាំងសម្រាប់ប្រមូលទិន្នន័យផងដែរ។ បន្ទាប់មក បានចុះធ្វើការប្រមូលទិន្នន័យពេញទំហឹងក្នុងប្រទេសកម្ពុជាចាប់ពីថ្ងៃទី៩ ដល់ទី១៧ ខែមករា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង។ ក្រុមការងារបាននិយាយជាមួយមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារពាក់ព័ន្ធនឹងការថែទាំជំនួស គ្រួសារធម៌ និងគ្រួសារបិញ្ចឹម ទីភ្នាក់ងារសុំកូន មន្ទីរពេទ្យ មណ្ឌលថែទាំ (RCIs) និងចៅក្រម។ ជាសរុប យើងបានធ្វើការសម្ភាសន៍ចំនួន៣៥។ ក្រុមការងារបានរាយការណ៍អំពីចំណាប់អារម្មណ៍បឋមជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមការងារត្រួតពិនិត្យបច្ចេកទេសកាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ ដើម្បីសុំយោបល់ត្រឡប់ ហើយក៏បានធ្វើការសម្ភាសន៍បន្ថែមជាច្រើនទៀត យោងទៅតាមយោបល់ត្រឡប់ដែលបានស្នើឡើង។

## ២. សាវតារស្តីពីសុំកូន

### ការអនុវត្តបែបបុរាណ

កុមារភាគច្រើនក្នុងប្រទេសកម្ពុជាទទួលបានការថែទាំពីឪពុកម្តាយ ឬសមាជិកគ្រួសារជាសាច់ញាតិរបស់ខ្លួន។ នៅពេលគ្រួសារជួបការប៉ះទង្គិច ឬវិបត្តិ សាច់ញាតិ ឬសមាជិកសហគមន៍ច្រើនតែចេញមុខមកផ្តល់ការថែទាំកុមារ។ ជាពិសេស ក្នុងករណីម្តាយពុំអាចមើលថែកូនបានយាយតា ឬសាច់ញាតិដទៃទៀតច្រើនតែផ្តល់ការថែទាំយ៉ាងហោចណាស់ក៏ថែទាំមួយរយៈដែរ។[1] ហេតុផលមួយចំនួនដែលអ្នកចូលរួមក្នុងការសិក្សាលើកឡើងអំពីមូលហេតុនៃការបំបែកចេញពីគ្រួសារ រួមមានដូចជា ឪពុកម្តាយចំណាកស្រុកទៅធ្វើការងារ ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ និងការប្រើប្រាស់សារធាតុញៀនបំពាន។ អ្នកចូលរួមក្នុងការសិក្សាក៏បានរាយការណ៍ដែរថា នៅពេលទារកត្រូវបានគេបោះបង់ចោលនៅពេលកើត ជាទូទៅគឺដោយសារតែភាពក្រីក្រ ការម៉ាក់ងាយរើសអើងចំពោះម្តាយដែលមិនបានរៀបការ ហើយពេលខ្លះគឺដោយសារពិការភាព ឬស្ថានភាពវេជ្ជសាស្ត្ររបស់កុមារ។ ជាទូទៅមណ្ឌលថែទាំត្រូវបានគេប្រើប្រាស់ជំនួសឱ្យការផ្គត់ផ្គង់ផ្នែកសង្គម ជាពិសេសដើម្បីឱ្យកុមារបានរៀនសូត្រដោយកុមារជាច្រើនចូលទៅមណ្ឌលថែទាំនៅពេលពួកគេឈានដល់អាយុចូលរៀន (៦-៨ឆ្នាំ) ហើយភាគច្រើនលើសលប់នៃកុមារទាំងនោះគឺនៅមានយ៉ាងហោចណាស់ម្តាយ ឬឪពុកនៅរស់រានមានជីវិត។[2] ការរៀបចំទាំងនេះជារឿយៗគឺជាផ្នែកមួយនៃ«ទំនាក់ទំនងម្ចាស់ជាមួយអតិថិជន» ដែលត្រូវបានបណ្តុះឡើងរវាងនាយកមណ្ឌលថែទាំ (ជាពិសេស មណ្ឌលថែទាំដែលប្រតិបត្តិការផ្ទុយពីគោលនយោបាយកម្ពុជាដែលតម្រូវឱ្យមានការចុះបញ្ជី និងអាជ្ញាប័ណ្ណ[3]) និងឪពុកម្តាយដែលបានទទួលការសន្យាថា កូនៗរបស់ពួកគេនឹងបានទទួលការអប់រំល្អ ហើយអាចមានលទ្ធភាពមានឱកាសទៅសិក្សានៅបរទេសទៀតផង ប្រសិនបើពួកគេដាក់កូននៅក្នុងមណ្ឌលថែទាំ។[4] បន្ទាប់ពីនោះ បុគ្គលិកមណ្ឌលថែទាំអាចកេងប្រវ័ញ្ចកុមារស្ថិតក្រោមការថែទាំរបស់ខ្លួនដើម្បីរៃអង្គាសថវិកាពីម្ចាស់ជំនួយ។[5]

### សុំកូនអន្តរប្រទេស

ការបណ្តុះភាពត្រួតត្រារបស់មណ្ឌលថែទាំកុមារ ត្រូវបានជំរុញបន្ថែមទៀតដោយចរន្តយ៉ាងគំហុកនៃការសុំកូនអន្តរប្រទេស (ICAs) ក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ក្នុងស្ថានភាពដែលពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធច្បាប់

---

[1] Muney R, Nguon S and Chhim T. (2024) Kinship and Foster Care: Understanding Current Practice in Cambodia. Phnom Penh: Family Care First, 133.

[2] Roby JL and Maskew T. (2012) Human Rights Considerations in Intercountry Adoption: The Children and Families of Cambodia and Marshall Islands. In: Gibbons J and Rotabi KS (eds) *Intercountry Adoption: Policies, Practices, and Outcomes.* Surrey: Ashgate, 55-66. p. 60.

Stark L, Rubenstein BL, Pak K, et al. (2017) National estimation of children in residential care institutions in Cambodia: a modelling study. *BMJ Open* 7(1): 1-8. p. 4.

[3] Kingdom of Cambodia. (2015) Sub-Decree on the Management of Residential Care Center. MoSVY *119 ANKr.BK.* Phnom Penh.

[4] Nhep R. (2024) Clientelism in Cambodian Residential Care Institutions. *Children's Geographies* 23(1): 16-33.

[5] Guiney T and Mostafanezhad M. (2015) The political economy of orphanage tourism in Cambodia. *Tourist Studies* 15(2): 132-155.

Nhep R, Deck S, van Doore K, et al. (2024) Detecting orphanage trafficking and exploitation. *Child Abuse & Neglect* 152: 106813.

និងគោលនយោបាយដើម្បីធ្វើនិយ័តកម្មលើការសុំកូនអន្តរប្រទេសនៅឡើយ ប្រទេសកម្ពុជាក៏បានប្រែក្លាយជា «គោលដៅសុំកូនអន្តរប្រទេស» យ៉ាងឆាប់រហ័ស ហើយជាប្រទេសមានកេរ្តិ៍ឈ្មោះល្បីថាអាចសុំកូនបានឆាប់រហ័ស និងមានទារកមានសុខភាពល្អសម្រាប់សុំ។[6] ចំណុចនេះបានបង្កឱ្យមានការព្រួយបារម្ភពីសំណាក់អ្នកជំនាញការផ្នែកកិច្ចការពារកុមារដែលបានពិនិត្យឃើញថាឪពុកម្ដាយត្រូវបានគេល្បួងឱ្យបោះបង់កូនរបស់ខ្លួនចោល មិនថាតាមរយៈការឱ្យលុយតែម្ដង ឬការសន្យាផ្ដល់ការអប់រំ សុខភាព និងសេវាផ្សេងទៀត ដូចបានកត់សម្គាល់ខាងលើ។ ការសុំកូនអន្តរប្រទេសត្រូវបានផ្អាកក្នុងឆ្នាំ២០០០ អាស្រ័យដោយមានភាពមិនប្រក្រតីដូចបានលើកឡើងខាងលើ។[7] អនុក្រឹត្យឆ្នាំ២០០១ របស់រដ្ឋាភិបាលបានបើកប្រទេសកម្ពុជាសម្រាប់សុំកូនអន្តរប្រទេសឡើងវិញ ប៉ុន្តែការបើកឡើងវិញនេះបានត្រឹមតែបង្កឱ្យមានកង្វល់កាន់តែច្រើនឡើងចំពោះការកេងយកចំណេញ និងការប្រតិបត្តិសុំកូនមិនប្រក្រតី។[8] ដោយសារហេតុនេះ ប្រទេសអូស្ត្រាលី បារាំង ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងហូឡង់ បានផ្អាកសុំកូនអន្តរប្រទេសពីប្រទេសកម្ពុជាចាប់ពីឆ្នាំ២០០១ មក។[9] ប៉ុន្តែសកម្មភាពនេះពុំបានបញ្ឈប់តម្រូវការសុំកូនអន្តរប្រទេសនៅថ្នាក់សកលលោកលែងឱ្យជះឥទ្ធិពល និងកំណត់ទិសទីផ្សារសុំកូន រួមទាំងការដាក់កុមារនៅតាមមណ្ឌលថែទាំក្នុងប្រទេសនានា ដូចជាប្រទេសកម្ពុជា ជាដើមនោះឡើយ។[10]

នៅទសវត្សរ៍ឆ្នាំ២០០០ តម្រូវការសុំកូនអន្តរប្រទេសព្រមជាមួយការកើនឡើងប្រជាប្រិយភាពនៃទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា និងអ្នកទេសចរណ៍ស្ម័គ្រចិត្តទៅទស្សនាមណ្ឌលកុមារកំព្រា ព្រមទាំងការងារស្ម័គ្រចិត្តនៅមណ្ឌលថែទាំពេលពួកគេមកលំហែពេលវិស្សមកាល[11] បន្តលើកទឹកចិត្តឱ្យមានការយកកុមារទៅដាក់ក្នុងមណ្ឌលដោយមិនចាំបាច់ ព្រោះថាការធ្វើបែបនេះបានផ្ដល់ប្រយោជន៍ដល់ភាគីមួយចំនួន។[12] បុគ្គលិកមណ្ឌលថែទាំកុមារនៅតែមានឥទ្ធិពលមិនសមគួរនៅក្នុងសហគមន៍ ហើយទទួលបានការការពារមណ្ឌលថែទាំកុមារមិនបានចុះបញ្ជីរបស់ខ្លួន ជាហេតុអាចបិទបាំងការពារពួកគេពីការត្រួតពិនិត្យផ្នែកនិយ័តកម្មបានប្រកបដោយប្រសិទ្ធភាព។[13] កង្វះការត្រួតពិនិត្យប្រកបដោយតុល្យភាពត្រឹមត្រូវនេះបានអនុញ្ញាតឱ្យមណ្ឌលថែទាំកុមារដែលមានកម្រិតអន់ជាងបទដ្ឋាននៅតែបន្តប្រតិបត្តិការ ហើយធ្វើឱ្យវដ្ដនៃវិធានការការពារ

[6] Roby, J. L. and T. Maskew (2012). Human Rights Considerations in Intercountry Adoption: The Children and Families of Cambodia and Marshall Islands. Intercountry Adoption: Policies, Practices, and Outcomes. J. Gibbons and K. S. Rotabi. Surrey, Ashgate: 55-66. p. 59-64.

[7] Roby, J. L. and T. Maskew (2012). Human Rights Considerations in Intercountry Adoption: The Children and Families of Cambodia and Marshall Islands. Intercountry Adoption: Policies, Practices, and Outcomes. J. Gibbons and K. S. Rotabi. Surrey, Ashgate: 55-66. p. 59-64.

[8] Roby, J. L. and T. Maskew (2012). Human Rights Considerations in Intercountry Adoption: The Children and Families of Cambodia and Marshall Islands. Intercountry Adoption: Policies, Practices, and Outcomes. J. Gibbons and K. S. Rotabi. Surrey, Ashgate: 55-66. p. 59-64.

[9] https://www.cambodianess.com/article/international-adoptions-in-cambodia-the-ghost-of-illegalities

See also Wittner KM. (2003) Curbing Child-Trafficking in Intercountry Adoptions: Will International Treaties and Adoption Moratoriums Accomplish the Job in Cambodia? *Pacific Rim Law & Policy Journal* 12(2): 595-630.

Smolin DM. (2005) Intercountry Adoption as Child Trafficking. *Valparaiso Law Review* 39(2): 281-325.

[10] Cheney, K. E. and S. Ucembe (2019). The Orphan Industrial Complex: the charitable commodification of children and its consequences for child protection. Disadvantaged Childhoods and Humanitarian Intervention: Processes of Affective Commodification. K. Cheney and A. Sinervo. London, Palgrave MacMillan.

[11] https://bettercarenetwork.org/about-bcn/what-we-do/key-initiatives/rethink-orphanages/problem-with-visiting-and-volunteering-in-orphanages

[12] Walker C and Hartley M. (2013) Cambodia's Orphan-Industrial Complex. *The Atlantic.*

[13] Nhep, R. and K. van Doore (2023). Implementing the Legal Framework for the Prosecution of Orphanage Trafficking: A Cambodia Case Study. Brisbane, Griffith University**:** 11.

កុមារមិនគ្រប់គ្រាន់នៅតែបន្តកើតមានយ៉ាងអូសបន្លាយ បើទោះបីជាមាននិយ័តកម្មថ្មីៗរបស់រដ្ឋាភិបាលដែលមានគោលដៅក្នុងការកែលម្អធ្វើឱ្យស្ថានភាពកាន់តែប្រសើរឡើងជាងមុនក្តី។[14] ទំនាក់ទំនងទាំងនេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការអនុវត្តបទដ្ឋាន ដែលត្រូវបានបង្កើតឡើងថ្មី។ នៅចន្លោះចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ ចំនួនកុមារស្ថិតក្នុងការថែទាំដោយស្ថាប័នមានការកើនឡើងទ្វេរដង[15] បើទោះបីជាមានការជំរុញគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ការថែទាំកុមារតាមគ្រួសារយ៉ាងណាក្តី។[16]

ដោយហេតុនេះ អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់បានចាប់ផ្តើមចាត់ចំណាត់ថ្នាក់សកម្មភាពដែលដាក់កុមារ (ជាពិសេសកុមារដែលមានការថែទាំពីឪពុកម្តាយ) ទៅក្នុងមណ្ឌលថែទាំកុមារក្នុងចេតនាកេងប្រវ័ញ្ចទាញយកផលចំណេញថាជាការជួញដូរមនុស្ស ហើយផ្តល់អនុសាសន៍ឱ្យការងារនេះក្លាយជាផ្នែកមួយនៃចំណាត់ប្រភេទសកលដែលមានលក្ខណៈទូលំទូលាយ។[17] យោងតាមការសិក្សារបស់ Nhep និង van Doore បានលើកឡើងថា «ការដាក់បញ្ចូលផលចំណេញជាគោលបំណងមួយសម្រាប់ការនាំយកចេញដោយខុសច្បាប់គឺជាការអភិវឌ្ឍដែលមានភាពជឿនលឿនមួយនៅក្នុងច្បាប់ [ប្រទេសកម្ពុជា]។ ការអនុវត្តនេះត្រួសត្រាយផ្លូវសម្រាប់គ្រប់ទម្រង់ទាំងអស់ ដែលគេស្គាល់នៃការជួញដូរដោយមណ្ឌលកុមារកំព្រាឱ្យក្លាយជាបទល្មើសអាចដាក់ទណ្ឌកម្មបាន រួមទាំងការនាំយកកុមារចេញដោយខុសច្បាប់ពីគ្រួសារ និងការទុកដាក់កុមារនៅក្នុងមណ្ឌលកុមារកំព្រាដើម្បីរកប្រាក់ចំណេញ។»[18] ហេតុដូច្នេះ ប្រទេសកម្ពុជាបានចាត់វិធានការឆ្លើយតបចំពោះបញ្ហានេះ។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេស (HCIA) ក្នុងឆ្នាំ២០០៧ ហើយនៅឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ថ្មីស្តីពីការសុំកូនអន្តរប្រទេស ប៉ុន្តែការអនុវត្តច្បាប់នេះគឺនៅមានភាពយឺតយ៉ាវ អាស្រ័យដោយប្រទេសនៅតែបន្តមានភាពខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ។[19] ក្នុងឆ្នាំ២០១១ ច្បាប់នេះបានចូលជាធរមាន ហើយបានបញ្ឈប់រាល់ការសុំកូនអន្តរប្រទេសពីសំណាក់ជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសកម្ពុជា។ សុំកូនអន្តរប្រទេសត្រូវបានផ្អាកជាបន្ត ប៉ុន្តែអ្នកចូលរួមក្នុងការសិក្សាបានរាយការណ៍អំពីករណីជាច្រើន ដែលពលរដ្ឋបរទេសរស់នៅក្នុងប្រទេសកម្ពុជាបានសុំកូនក្នុងប្រទេសតាមរយៈក្រមរដ្ឋប្បវេណី។[20] បន្ថែមពីលើនេះ ការទាក់ទងឆ្លើយឆ្លងរវាងឯកឧត្តម

[14] Vuković, D. and M. Babović (2018). "The Trap of Neo-patrimonialism: Social Accountability and Good Governance in Cambodia." Asian Studies Review **42**(1): 144-160.

[15] Flanagan K. (2020) Promising Practices —Strengthening Families and Systems to Prevent and Reduce the Institutional Care of Children. In: Cheer JM, Mathews L, van Doore KE, et al. (eds) *Modern Day Slavery and Orphanage Tourism.* Boston: CABI, 63-82. p. 77.

[16] Ministry of Social Affairs Veterans and Youth Rehabilitation. (2006) Policy on Alternative Care for Children. Phnom Penh: Ministry of Social Affairs, Veterans and Youth Rehabilitation 30.

[17] Van Doore KE. (2016) Paper Orphans: Exploring Child Trafficking for the Purpose of Orphanages. *International Journal of Children's Rights* 24(2): 378-407.

[18] Nhep R and van Doore K. (2023) Implementing the Legal Framework for the Prosecution of Orphanage Trafficking: A Cambodia Case Study. Brisbane: Griffith University, 11. p. 2.

[19] Roby, J. L. and T. Maskew (2012). Human Rights Considerations in Intercountry Adoption: The Children and Families of Cambodia and Marshall Islands. Intercountry Adoption: Policies, Practices, and Outcomes. J. Gibbons and K. S. Rotabi. Surrey, Ashgate: 55-66. p. 63.

Fronek, P., R. Common, K. S. Rotabi and J. Statham (2019). "Identifying and Addressing Risk in the Implementation of Alternative Care Policies in Cambodia." Journal of Human Rights and Social Work 4(2): 140-144.

[20] Those expatriates living in Cambodia should have gone through the HCIA but were able to complete domestic adoptions through the courts, under the Civil Code. Because of the ban on ICA, they find that they cannot leave Cambodia with their adopted children.

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតសម្បទា កាលពីឆ្នាំ២០២០ និង ២០២១ បានព្រមព្រៀងឯកភាពជាគោលការណ៍ថានឹងចាប់ផ្តើមបើកឱ្យដំណើរការការសុំកូនអន្តរប្រទេសឡើងវិញ ចាប់ពីដើមឆ្នាំ២០២០។[21] ចាប់តាំងពីពេលនោះមក រាជរដ្ឋាភិបាលកម្ពុជាបានខិតខំគួរជាទីកត់សម្គាល់ក្នុងការពង្រឹងក្របខណ្ឌការងារផ្នែកច្បាប់ និងដំណើរការកិច្ចការពារកុមារ ដើម្បីធានាឱ្យបានថា ប្រសិនបើ/នៅពេលដែលសុំកូនអន្តរប្រទេសត្រូវបានបើកឡើងវិញយ៉ាងពេញលេញ គឺនឹងត្រូវកើតមានដោយអនុលោមតាមច្បាប់របស់កម្ពុជា និងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាដូចមានចែងក្រោមអនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេស។

ទោះយ៉ាងនេះក្តីការសុំកូនអន្តរប្រទេស ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា និងវប្បធម៌អតិថិតានិយម (clientelism) នៅតែបន្តដើរតួជាកត្តាអូសទាញឱ្យកុមារចូលមកនៅក្នុងមណ្ឌល។ ក្នុងរយៈពេលកន្លងទៅថ្មីៗនេះ គិតត្រឹមឆ្នាំ២០១៧ មានការប៉ាន់ប្រមាណថាកុមារចំនួន ៤៨.៧៧៥នាក់ ពោលគឺស្មើនឹងជិតមួយនាក់រៀងរាល់កុមារ១០០នាក់ ក្នុងប្រទេសកម្ពុជាគឺរស់នៅក្នុងមណ្ឌលថែទាំកុមារចំនួន ៦៣៩កន្លែង។[22] កុមារទាំងនោះភាគច្រើន គឺនៅមានឪពុក ឬម្តាយនៅមានជីវិត ហើយពួកគេស្ថិតក្នុងអាយុទៅសាលារៀន ដោយកុមារច្រើនជាងពាក់កណ្តាលស្ថិតក្នុងចន្លោះអាយុចាប់ពី ១៣ ដល់ ១៧ឆ្នាំ។[23] ចំណុចនេះបានបង្កឱ្យមានក្តីកង្វល់ជាប្រចាំចំពោះសុខភាពកុមារ ការការពារកុមារ និងការអភិវឌ្ឍជាតិ។

## ការសមាហរណកម្មកុមារចេញពីមណ្ឌលថែទាំ និងកំណែទម្រង់ការថែទាំ

ក្នុងឆ្នាំ២០១៦ រដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមកម្មវិធីសមាហរណកម្មកុមារចេញពីមណ្ឌលថែទាំ ក្នុងគោលបំណងដើម្បីកាត់បន្ថយចំនួនកុមារស្ថិតក្នុងមណ្ឌលថែទាំឱ្យបានយ៉ាងហោចណាស់ ៣០ភាគរយត្រឹមឆ្នាំ២០១៨។[24] អង្គការសង្គមស៊ីវិល (CSOs) និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (INGOs) ដូចជាអង្គការ Friends International និង Save the Children បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្តផែនការសកម្មភាពស្តីពីការថែទាំជំនួសដើម្បីកាត់បន្ថយចំនួនកុមាររស់នៅក្នុងមណ្ឌលថែទាំ។ គេបានអភិវឌ្ឍឧបករណ៍ ការបណ្តុះបណ្តាល និងគោលការណ៍ណែនាំផ្សេងៗក្នុងការគ្រប់គ្រងករណីសម្រាប់សមាហរណកម្មកុមារ ការគ្រប់គ្រងករណី និងការតាមដានបន្ត។ គិតត្រឹមឆ្នាំ២០២៣ មានកុមារតែប្រមាណ ៧០០០នាក់ ប៉ុណ្ណោះដែលនៅបន្តរស់នៅក្នុងមណ្ឌលថែទាំដែលមានចំនួនប្រមាណ ២៧០កន្លែង។[25] ពួកគេបានឈានទៅសម្រេចបានជោគជ័យលើគោលបំណងនេះ ប៉ុន្តែ «វិធីសាស្ត្រមិនស៊ីសង្វាក់

---

21 Letter dated 15 January 2021 from the Minister of MoSVY to the Deputy Prime Minister and the Minister of Foreign Affairs and International Cooperation

22 Stark L, Rubenstein BL, Pak K, et al. (2017) National estimation of children in residential care institutions in Cambodia: a modelling study. *BMJ Open* 7(1): 1-8. It should be noted that a 2017 MoSVY mapping of RCIs put this number at closer to 26,000–but they noted that 77% of those children had at least one living parent.

23 Stark L, Rubenstein BL, Pak K, et al. (2017) National estimation of children in residential care institutions in Cambodia: a modelling study. *BMJ Open* 7(1): 1-8.

24 https://open.unicef.org/sites/transparency/files/2020-06/Cambodia-TP5-2018.pdf, p. 6.

25 Sources:
https://www.unicef.org/cambodia/media/1341/file/Residential%20care%20facilities%20in%20Cambodia%20Inforgraphic%20English.pdf
https://www.unicef.org/cambodia/press-releases/revised-alternative-care-policy-prioritises-family-based-care-all-children-cambodia

គ្នា និងសមាហរណកម្មពុំបានគិតគូរច្បាស់លាស់ និងធ្វើឡើងរហ័សពេក បានធ្វើឱ្យកុមារត្រូវស្ថិតក្នុងបរិស្ថានប្រកបដោយហានិភ័យខ្ពស់ដោយពុំមានការប៉ាន់ប្រមាណម៉ត់ចត់ និងពុំមានការផ្តល់សេវាដែលត្រូវការ។»[26]

រាជរដ្ឋាភិបាល ក៏សម្រេចបានជោគជ័យយ៉ាងច្រើនផងដែរនៅក្នុងកំណែទម្រង់ការថែទាំ និងកិច្ចការពារកុមារជាទូទៅ រួមទាំងការពង្រឹងច្បាប់ប្រឆាំងការជួញដូរផងដែរ។ ជាលទ្ធផលការសុំកូនដោយខុសច្បាប់ និងការជួញដូរតាមរយៈ មណ្ឌលកុមារកំព្រានាពលបច្ចុប្បន្ននេះគឺ អាចយកទៅជំនុំជម្រះទោសក្រោមច្បាប់កម្ពុជាបាន បើទោះបីជាមកដល់បច្ចុប្បន្ននេះ ការកាត់ទោសនៅមានកម្រិតកំណត់ដោយសារតែមានការលំបាកក្នុងការពិនិត្យរកការប្រតិបត្តិខុសច្បាប់ក្តី។[27]

ឯកសាររបស់ Nhep បានបង្ហាញឱ្យឃើញថាតើ «វប្បធម៌អតិថិតានិយម (clientelism) នៅតែបន្តដើរតួជាកត្តាជំរុញជាពិសេសមួយធ្វើឱ្យមានការយកកុមារទៅដាក់មណ្ឌលថែទាំ ជាពិសេសជួយសម្របសម្រួលដល់ការជ្រើសរើសកុមារ ការនាំយកកុមារចេញដោយខុសច្បាប់ ការទទួលយកកុមារដោយខុសប្រក្រតី ការដាក់កុមារនៅមណ្ឌលថែទាំរយៈពេលយូរ និងរបៀបដែលគេគេចវេះពីការត្រួតពិនិត្យរបស់និយ័តកម្ម» ក្នុងប្រទេសកម្ពុជា ដោយលើកហេតុផលថា បញ្ហានេះចាំបាច់ត្រូវដោះស្រាយ «ក្នុងបរិបទកិច្ចការពារកុមារ និងកំណែទម្រង់ការថែទាំក្នុងប្រទេសកម្ពុជា និងការពង្រឹងអភិបាលកិច្ចសិទ្ធិកុមារ»[28] ដែលរដ្ឋាភិបាលកំពុងបន្តអនុវត្តក្រោមផែនការកំណែទម្រង់ការថែទាំ។

## គោលនយោបាយថ្មីៗស្តីពីកិច្ចការពារកុមារ និងការលើកកម្ពស់សុំកូនក្នុងប្រទេស

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ដើម្បីទប់ស្កាត់អំពីហិង្សា ការមិនអើពើ និងការកេងប្រវ័ញ្ចកុមារ។ គណៈកម្មការជាតិដើម្បីកិច្ចការពារកុមារ (NCPC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ដើម្បីពង្រឹងប្រព័ន្ធកិច្ចការពារកុមារ និងលុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃការរំលោភបំពាន អំពើហិង្សា និងការមិនអើពើចំពោះកុមារ ហើយគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារត្រូវបានអនុម័តក្នុងឆ្នាំ២០១៩។ អនុក្រឹត្យលេខ១១៩ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំ (២០១៥) និងលេខ៣៤ ស្តីពីការផ្ទេរមុខងារសម្រាប់ «ការគ្រប់គ្រងមណ្ឌលថែទាំដំណើរការដោយរដ្ឋ» (២០១៧) ក៏បានផ្តល់ក្របខណ្ឌការងារផ្នែកច្បាប់សម្រាប់កំណែទម្រង់ការថែទាំជំនួសផងដែរ។[29]

It should be noted that the 2023 UNICEF Situation Analysis states that 5,440 children were in residential care in 2021, so the numbers have fluctuated over time, rather than indicating a steady reduction. See https://www.unicef.org/cambodia/reports/analysis-situation-children-and-adolescents-cambodia-2023

[26] Fronek P, Common R, Rotabi KS, et al. (2019) Identifying and Addressing Risk in the Implementation of Alternative Care Policies in Cambodia. *Journal of Human Rights and Social Work* 4(2): 140-144, p. 142.

[27] Nhep R, Deck S, van Doore K, et al. (2024) Detecting orphanage trafficking and exploitation. *Child Abuse & Neglect* 152: 106813.

[28] Nhep R. (2024) Clientelism in Cambodian Residential Care Institutions. *Children's Geographies* 23(1): 16-33. p. 16.

[29] MoSVY. (2023) ACTION PLAN ON IMPROVING ALTERNATIVE CARE FOR CHILDREN 2023-2027. Phnom Penh: Ministry of Social Affairs, Veterans and Youth Rehabilitation, 26. p. 1.

ក្នុងឆ្នាំ២០២៤ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាកិច្ចឆ្លើយតបយ៉ាងច្បាស់លាស់ជាមួយអំពើហិង្សាដែលបានចងក្រងទុកជាឯកសារ បានអនុម័តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារថ្មីមួយដែលជារបត់គួរជាទីកត់សម្គាល់ ទាក់ទងនឹងវិធីសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងការថែទាំកុមារ។ គោលនយោបាយថ្មីនេះចាត់អាទិភាពដល់ការថែទាំតាមគ្រួសារ និងស្មុំកូនក្នុងប្រទេសជាជាងការថែទាំតាមមណ្ឌលថែទាំ និងស្មុំកូនអន្តរប្រទេសដោយអនុលោមតាមអនុសញ្ញាទីក្រុងឡាអេ ស្តីពីការស្មុំកូនអន្តរប្រទេស និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិឆ្នាំ២០១០ ស្តីពីការថែទាំជំនួសចំពោះកុមារ។ គោលនយោបាយនេះមានបំណងកែទម្រង់ប្រព័ន្ធថែទាំដែលមានស្រាប់ ព្រមទាំងពង្រឹងវិធានការការពារកុមារនៅទូទាំងប្រទេស។ ប៉ុន្តែប្រសិទ្ធភាពនៃបទប្បញ្ញត្តិថ្មីៗទាំងនេះ គឺនៅពុំទាន់ច្បាស់លាស់នៅឡើយ ដោយហេតុថាប្រទេសកម្ពុជាត្រូវប្រឈមមុខជាមួយបញ្ហាប្រឈមក្នុងការអនុវត្តអាស្រ័យដោយធនធានមានកម្រិតកំណត់ និងហេដ្ឋារចនាសម្ព័ន្ធសេវាសង្គមពុំទាន់មានការអភិវឌ្ឍគ្រប់គ្រាន់។[30] ថ្វីបើក្របខណ្ឌការងារថ្មីនេះ បង្ហាញនូវសក្តានុពលខ្ពស់ក្នុងការពង្រឹងការអនុវត្តផ្នែកស្មុំកូន និងសុខមាលភាពកុមារក្តី ប៉ុន្តែអ្នកពាក់ព័ន្ធទាំងអស់យល់ស្របគ្នាថា ចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យគោលនយោបាយត្រូវបានយកទៅប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។

## គោលនយោបាយពាក់ព័ន្ធជាមួយស្មុំកូន៖

- *គោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ (២០២៤)*
- *ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស (២០០៩)*
- *ប្រកាសស្តីពីនីតិវិធីដើម្បីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ (២០១១)*
- *ប្រកាសស្តីពីគោលការណ៍ណែនាំដើម្បីអនុវត្តនីតិវិធីស្មុំកូនអន្តរប្រទេសសម្រាប់កុមារដែលមានតម្រូវការការថែទាំពិសេស និងកុមារមានតម្រូវការពិសេស (២០១៤)*
- *ប្រកាសស្តីពីនីតិវិធីដើម្បីផ្តល់សិទ្ធិសម្រាប់ទីភ្នាក់ការស្មុំកូនអន្តរប្រទេស (២០២៣)*
- *សៀវភៅណែនាំស្តីពីការអនុវត្តស្មុំកូនក្នុងប្រទេស(២០២៣)*
- *ស្តង់ដារអប្បបរមាសម្រាប់ការថែទាំជំនួសសម្រាប់កុមារក្នុងមណ្ឌលថែទាំ (២០២៤)*

គោលនយោបាយនាពេលថ្មីៗនេះរបស់រដ្ឋាភិបាល បានសង្កត់ធ្ងន់លើការទុកដាក់អចិន្ត្រៃយ៍ (ដោយធានាឱ្យបានថាកុមារមានស្ថានភាពរស់នៅប្រកបដោយស្ថិរភាព អចិន្ត្រៃយ៍ និងសុវត្ថិភាព) និងការរក្សាកុមារឱ្យនៅជួបជុំគ្រួសារ មានន័យថា**ការស្មុំកូននឹងត្រូវយកមកពិចារណាជា*ជម្រើសចុងក្រោយ***បំផុតក្នុងការឈានទៅទទួលបានការទុកដាក់អចិន្ត្រៃយ៍។ រាជរដ្ឋាភិបាលកម្ពុជាក៏បានខិតខំដើម្បីឱ្យកម្លាំងសេវាសង្គមមានលក្ខណៈវិជ្ជាជីវៈកាន់តែខ្លាំងឡើងតាមរយៈកម្មវិធីទទួលស្គាល់គុណភាព និងផ្តល់អាហារូបករណ៍ដើម្បីជួយដល់កុមារ និងគ្រួសារ ប៉ុន្តែកិច្ចខិតខំនេះគឺស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ។

ស្របពេលគ្នានេះដែរ CSOs និង INGOs បានចាប់ផ្តើមលើកកម្ពស់ការស្មុំកូនក្នុងប្រទេស ជាមធ្យោបាយមួយដើម្បីផ្តល់ឱ្យកុមារដែលមិនមានការថែទាំពីឪពុកម្តាយ។ ក្នុងឆ្នាំ២០១៧ អង្គការ Children in Families

[30] ការសង្កេតឃើញផ្អែកលើការសម្ភាសន៍របស់ពួកយើងជាមួយអ្នកតំណាងរដ្ឋាភិបាល និង NGO ។

បានចាប់ផ្តើមកម្មវិធីស្មុំកូនក្នុងប្រទេសដោយផ្តើមចេញពីកម្មវិធីការថែទាំដោយគ្រួសារធម៌ ហើយមកដល់បច្ចុប្បន្នអង្គការនេះ បានបំពេញការងារស្មុំកូនប្រមាណ ៥០ករណី។ ក្រោយពីគម្រោងអនុវត្តសាកល្បងប្រកបដោយជោគជ័យនៅខេត្តបាត់ដំបង (២០១៩-២១) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងភាពជាដៃគូជាមួយអង្គការ Holt International Children's Services បានពង្រីកការងារស្មុំកូនក្នុងប្រទេសទៅកាន់ខេត្តចំនួនបួនបន្ថែមទៀត។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៤ មានករណីស្មុំកូនក្នុងប្រទេសចំនួន១២ ដែលត្រូវបានអនុញ្ញាតដោយតុលាការ។ គម្រោងនេះក៏បានបង្កើនសមត្ថភាព និងជំនាញជុំវិញនីតិវិធីស្មុំកូនក្នុងប្រទេសសម្រាប់អាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត តុលាការ CSOs និងគ្រឹះស្ថានថែទាំកុមារ ឈានទៅធានាឱ្យការទុកដាក់កុមារតាមរយៈស្មុំកូនបានទទួលជោគជ័យ។ ជាចុងក្រោយ រាជរដ្ឋាភិបាលកម្ពុជាក៏បានលើកកម្ពស់ការយល់ដឹងរបស់សាធារណជនកម្ពុជាអំពីស្មុំកូនក្នុងប្រទេស និងតម្រូវការចាំបាច់ឱ្យមានគ្រួសារអចិន្ត្រៃយ៍សម្រាប់កុមារដែលកំពុងរង់ចាំការទុកដាក់។[31]

ចំណុចគួរជាទីសុទិដ្ឋិនិយមមួយទៀត គឺការអភិវឌ្ឍឱ្យមានប្រព័ន្ធថ្នាក់ជាតិសម្រាប់ការថែទាំដោយគ្រួសារធម៌ និងការថែទាំដោយសាច់ញាតិនៅថ្នាក់ជាតិ ដោយក្នុងនោះមានការបង្កើតគោលនយោបាយ និងនីតិវិធីសម្រាប់គាំទ្រដល់ការថែទាំជំនួសនៅតាមគ្រួសារ។ គំនិតផ្តួចផ្តើមដែលមានឈ្មោះថា ការថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង (Family Care First) បានចងក្រងទុកជាឯកសារអំពីទិដ្ឋភាពនានានៃប្រព័ន្ធដែលកើតមានថ្មីៗ[32] ដោយក្នុងនោះរួមមានទាំងការជ្រើសរើស និងការបណ្តុះបណ្តាលឪពុកម្តាយធម៌ដែលត្រូវបានធ្វើឡើងដោយមានការចង្អុលបង្ហាញពីប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងការថែទាំដោយគ្រួសារធម៌ ឆ្នាំ២០២១ ។ ប៉ុន្តែ បច្ចុប្បន្ននេះជាងមួយភាគបីនៃខេត្តទាំងអស់របស់កម្ពុជានៅខ្វះខាតកម្មវិធីថែទាំដោយគ្រួសារធម៌ ឬកម្មវិធីថែទាំដោយសាច់ញាតិ បើទោះបីជាមានតម្រូវការដើម្បីពង្រីកសេវាទាំងនេះក្តី។ ដោយហេតុថា ការថែទាំដោយគ្រួសារធម៌គឺជាផ្នែកមួយនៃការថែទាំជាលក្ខណៈច្រវាក់នៃការថែទាំគ្រប់ជ្រុងជ្រោយពីដើមទីរហូតទៅ (continuum of care) ដែលជារឿយៗតែងកើតមានមុនពេលស្មុំកូន ការអភិវឌ្ឍនេះ គឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងគម្រោងកិច្ចការពារកុមារទូលំទូលាយសម្រាប់កុមារដែលពុំមានការថែទាំពីឪពុកម្តាយ។

## ក្របខណ្ឌការងារផ្នែកច្បាប់សម្រាប់ស្មុំកូនក្នុងប្រទេសកម្ពុជា

ស្មុំកូនក្នុងប្រទេសកម្ពុជាបច្ចុប្បន្នស្ថិតក្រោមអភិបាលរបស់ក្របខណ្ឌការងារផ្នែកច្បាប់ចម្បងចំនួនពីរ៖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (២០០៧) សម្រាប់ស្មុំកូនក្នុងប្រទេស និងច្បាប់ស្តីពីការស្មុំកូនអន្តរប្រទេស (២០០៩)។ ច្បាប់ទាំងពីរនេះចែងអំពីនីតិវិធី ការតម្រូវ និងដែនកំណត់សម្រាប់ស្មុំកូនក្នុងប្រទេសកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់លើការការពារសិទ្ធិ និងសុខុមាលភាពរបស់កុមារ។

### *ស្មុំកូនក្នុងប្រទេស*

[31] Holt International (2021). EVALUATION REPORT: Pilot project "Promoting Permanency Planning for Children through Domestic Adoption, Cambodia", Holt International Children's Services: 35.

[32] Muney R, Nguon S and Chhim T. (2024) Kinship and Foster Care: Understanding Current Practice in Cambodia. Phnom Penh: Family Care First, 133.

ក្រោមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មានការទទួលស្គាល់សុំកូននៅក្នុងប្រទេសចំនួនពីរប្រភេទ៖ ពោលគឺសុំ**កូនពេញលេញ** និង**សុំកូនសាមញ្ញ**។[33] សុំកូនពេញលេញកាត់ផ្តាច់ចំណងទំនាក់ទំនងផ្នែកច្បាប់ទាំងស្រុងរវាងកូនចិញ្ចឹមជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន ហើយប្រគល់ឱ្យកុមារនូវសិទ្ធិទាំងអស់របស់កូនដែលកើតតាមធម្មជាតិឱ្យមាននៅក្នុងគ្រួសារចិញ្ចឹម។ សុំកូនប្រភេទនេះតម្រូវឱ្យមានការយល់ព្រមពីឪពុកម្តាយ លើកលែងតែឪពុកម្តាយបង្កើតត្រូវបានចាត់ទុកថា ពុំមានលក្ខណៈសម្បត្តិសមស្រប ឬពុំអាចមានវត្តមានផ្តល់ការយល់ព្រមបាន។ បន្ថែមលើនេះ ចាំបាច់ត្រូវមានរយៈពេលសាកល្បងមុនពេលសុំកូនត្រូវបានបញ្ចប់រួចរាល់ ហើយការរំលាយការសុំកូននេះគឺត្រូវបានអនុញ្ញាតតែក្រោមកាលៈទេសៈជាក់លាក់ប៉ុណ្ណោះ។ ផ្ទុយទៅវិញសុំកូនធម្មតារក្សាទំនាក់ទំនងផ្នែកច្បាប់រវាងកុមារជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន ហើយស្របពេលជាមួយគ្នានោះ ក៏បង្កើតឱ្យមានទំនាក់ទំនងរវាងឪពុកម្តាយជាមួយកូនជាមួយឪពុកម្តាយចិញ្ចឹមផងដែរ។ ដូចគ្នាជាមួយសុំកូនពេញលេញដែរ សុំកូនសាមញ្ញតម្រូវឱ្យមានការយល់ព្រម លើកលែងតែឪពុកម្តាយបង្កើតត្រូវបានចាត់ទុកថាមិនមានលក្ខណៈសម្បត្តិសមស្រប ឬមិនមានវត្តមានអាចផ្តល់ការយល់ព្រមបាន ហើយអាចរំលាយវិញបានប្រសិនបើចាំបាច់។ សុំកូនទាំងពីរទម្រង់នេះ គឺទាមទារឱ្យមានការមើលខុសត្រូវយ៉ាងតឹងរឹងពីតុលាការ ហើយមានការតម្រូវស្តីអំពីលក្ខណៈសម្បត្តិជាក់លាក់សម្រាប់ឪពុកម្តាយចិញ្ចឹមជាសក្តានុពល។

ដើម្បីលើកកម្ពស់សុំកូនក្នុងប្រទេសបន្ថែមទៀត ក្នុងពេលដំណាលគ្នាដែលធ្វើការឆ្លើយតបកង្វល់ស្តីពីសុំកូនអន្តរប្រទេស គោលការណ៍ណែនាំថ្មីត្រូវបានដាក់ចេញក្នុងឆ្នាំ២០២៣។ ក្រសួងយុត្តិធម៌ (MoJ) បានអភិវឌ្ឍសេចក្តីពន្យល់សម្រាប់ការអនុវត្តសុំកូនក្នុងប្រទេសដែលមានចែងក្រោមនីតិវិធីក្រមរដ្ឋប្បវេណី ចំណែកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញផ្សាយ*សៀវភៅណែនាំស្តីពីការអនុវត្តសុំកូនក្នុងប្រទេស*។ គោលការណ៍ណែនាំទាំងនេះ ហាមឃាត់យ៉ាងច្បាស់មិនឱ្យពលរដ្ឋបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា អាចសុំកុមារកម្ពុជាតាមរយៈនីតិវិធីសុំកូនក្នុងប្រទេសដូចមានចែងក្នុងក្រមរដ្ឋប្បវេណីឡើយ។ ផ្ទុយទៅវិញ ករណីបែបនេះត្រូវអនុវត្តតាមដំណើរការសុំកូនអន្តរប្រទេសដូចមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩។

## ***សុំកូនអន្តរប្រទេស***

ស្របពេលដែលក្រមរដ្ឋប្បវេណីផ្តល់ក្របខណ្ឌការងារសម្រាប់សុំកូនក្នុងប្រទេស ក្រមរដ្ឋប្បវេណីស្ងៀមស្ងាត់ស្តីពីបញ្ហាសុំកូនអន្តរប្រទេស។ ភាពស្រពេចស្រពិលផ្នែកច្បាប់នេះ ក្នុងពេលកន្លងមកបានអនុញ្ញាតឱ្យជនបរទេសសុំកុមារកម្ពុជាក្រោមនីតិវិធីសុំកូនក្នុងប្រទេស ហើយក្រោយមកបានទទួលទិដ្ឋាការសុំកូនតាមរយៈប្រទេសច្បាប់អន្តោប្រវេសន៍នៃប្រទេសកំណើតរបស់ខ្លួន។ ប៉ុន្តែការប្រតិបត្តិនេះបានរងផលប៉ះពាល់គួរជាទីកត់សម្គាល់ដោយសារការផ្លាស់ប្តូរផ្នែកច្បាប់នាពេលក្រោយៗមកទៀត ធ្វើឡើងនៅក្រោមអនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេសដើម្បីរឹតបន្តឹងសុំកូនអន្តរប្រទេស។

ក្នុងខែធ្នូ ឆ្នាំ២០០៩ ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីសុំកូនអន្តរប្រទេសដើម្បីការពារសិទ្ធិ និងផល

[33] MoSVY. (2011) PRAKAS ON PROCEDURES TO IMPLEMENT THE POLICY ON ALTERNATIVE CARE FOR CHILDREN. Phnom Penh: Ministry of Social Affairs, Veterans and Youth Rehabilitation 23.

ប្រយោជន៍របស់កុមារ ដែលត្រូវបានសុំដោយពលរដ្ឋបរទេសរួមទាំងជនបរទេសដែលកំពុងរស់នៅប្រទេសកម្ពុជាផងដែរ។ ច្បាប់នេះបានចូលជាធរមានក្នុងឆ្នាំ២០១១។ ដូចបានកត់សម្គាល់ខាងលើហើយថា ច្បាប់នេះបានដាក់ចេញឱ្យមានកំណែទម្រង់ធំៗសម្រាប់ការអនុវត្តសុំកូនកន្លងមកនៅក្រោមក្រមរដ្ឋប្បវេណី។ គួរកត់សម្គាល់ថាច្បាប់នេះ បានកំណត់ថាគ្រប់សុំកូនអន្តរប្រទេសទាំងអស់ ចាំបាច់ត្រូវបានទទួលការសម្របសម្រួលពីទីភ្នាក់ងារដែលបានទទួលសិទ្ធិ ហើយហាមឃាត់ក្រុមហ៊ុនឯកជន និងមណ្ឌលកុមារកំព្រាមិនឱ្យចាត់ចែងករណីទាំងនេះដោយផ្ទាល់ឡើយ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានចាត់តាំងជាអាជ្ញាធរកណ្តាលទទួលខុសត្រូវលើសុំកូនអន្តរប្រទេស។ ដើម្បីគាំទ្រដល់តួនាទីនេះ រដ្ឋបាលសុំកូនអន្តរប្រទេស (ICAA) ត្រូវបានស្ថាបនាឡើង ដើម្បីរក្សាឱ្យមានបញ្ជីឈ្មោះដោយមានការរក្សាជាសម្ងាត់នៃកុមារដែលមានលក្ខណៈសម្បត្តិអាចសុំបាន ព្រមទាំងដើម្បីមើលការខុសត្រូវលើការដាក់ពាក្យ។

## អន្តរទំនាក់ទំនងនៅក្នុងនិយ័តកម្មសុំកូន

សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារឆ្នាំ២០២៤ ព្យាយាមធ្វើនិយ័តកម្មបន្ថែមទៀតលើសេវាសុំកូនក្នុងប្រទេសសម្រាប់ប្រទេសកម្ពុជាតាមរយៈការដាក់ភារកិច្ចដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឱ្យបង្កើតសេវាសុំកូននៅទូទាំងគ្រប់បណ្តាខេត្តទាំងអស់។ ទោះយ៉ាងនេះក្តីសេចក្តីព្រាងច្បាប់នេះ ពុំបានញែកឱ្យដាច់ពីគ្នារវាងសុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេសទេ ហើយសេចក្តីព្រាងច្បាប់នេះក៏ពុំមានលើកឡើងពីបទប្បញ្ញត្តិ សម្រាប់ឪពុកម្តាយចិញ្ចឹមជាជនបរទេសរស់នៅក្នុងប្រទេសកម្ពុជាដែលបានបំពេញដំណើរការសុំកូនរួចរាល់កន្លងមកហើយនៅក្រោមក្រមព្រហ្មទណ្ឌនោះទេ។

អន្តរទំនាក់ទំនងគ្នារវាងច្បាប់សុំកូនក្នុងប្រទេសដូចមានចែងក្រោមក្រមរដ្ឋប្បវេណី និងនិយ័តកម្មសុំកូនអន្តរប្រទេស ជាការឆ្លុះបញ្ចាំងឱ្យឃើញអំពី បញ្ហាប្រឈមដែលកំពុងកើតមានជាបន្ត ហើយទាមទារឱ្យមានការពិចារណាយ៉ាងប្រុងប្រយ័ត្ន ដើម្បីរក្សាតុល្យភាពគ្នារវាងសុខុមាលភាពរបស់កុមារជាមួយសេចក្តីត្រូវការរបស់គ្រួសារចិញ្ចឹម។ អ្នកពាក់ព័ន្ធនានាបានលើកឡើងថា ការកែប្រែក្រមរដ្ឋប្បវេណីពុំអាចធ្វើឡើងបានដោយងាយស្រួលនោះទេ ហេតុនេះគឺពុំទំនងជាអាចមានការកែសម្រួលនេះឡើយ។ ហេតុដូច្នេះ ចាំបាច់ត្រូវមានកិច្ចខិតខំបន្ថែមទៀតក្នុងការធានាឱ្យបានថាឪពុកម្តាយចិញ្ចឹមជាសក្តានុពល ជាពិសេសជនបរទេសរស់នៅក្នុងប្រទេសកម្ពុជា និងជនបរទេសដទៃទៀតបានទទួលព័ត៌មានគ្រប់គ្រាន់អំពីដំណើរការសុំកូន។ ចៅក្រម និងមេធាវី ក៏ត្រូវការព័ត៌មាន និងការបកស្រាយបញ្ជាក់អំពីដំណើរការផ្សេងគ្នាសម្រាប់ពលរដ្ឋកម្ពុជា និងពលរដ្ឋបរទេស ក៏ដូចជាអំពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងតួនាទីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការធានាឧត្តមប្រយោជន៍របស់កុមារដែលត្រូវបានរៀបចំ និងបង្ហាញជូនទៅតុលាការ។

## ៣. គំហើញទូទៅ/ផ្នែកសង្គម

ជាទូទៅពួកយើងបានសម្គាល់ឃើញថា សង្គមកម្ពុជាជាទូទៅមានឆន្ទៈ និងមានសមត្ថភាពគាំទ្រកុមារដែលត្រូវបានបំបែកចេញពីគ្រួសារ។ យើងមើលឃើញការថែទាំដោយសាច់ញាតិ គឺជារឿងប្រក្រតី ហើយមានការចង្អុលបង្ហាញឱ្យឃើញថា ការថែទាំដោយគ្រួសារធម៌បែបក្រៅផ្លូវការ និងសុំកូន «តាមបែបប្រពៃណី» (មិនមែនតាមផ្លូវច្បាប់) គឺនៅតែកើតមានបើទោះបីជាមានកិច្ចខិតខំដើម្បីលើកកម្ពស់សុំកូនក្នុងប្រទេសតាមផ្លូវច្បាប់ក្តី។ NGOs ដែលបានផ្តួចផ្តើមគំនិតជំរុញកម្មវិធីថែទាំ តាមធម្មតាគឺមានសមត្ថភាពអាចជ្រើសរើសគ្រួសារធម៌សម្រាប់កុមារដែលត្រូវការការថែទាំជំនួស ហើយគ្រួសារទាំងនោះជាច្រើនចាប់អារម្មណ៍ក្នុងការចិញ្ចឹមកូនធម៌រយៈពេលវែង ដើម្បីបង្កើតការទុកដាក់អចិន្ត្រៃយ៍សម្រាប់កុមារដែលពុំអាចបង្រួបបង្រួមជាមួយគ្រួសារកំណើតរបស់ខ្លួនបាន។ ដូចបានបញ្ជាក់ខាងលើហើយថា អង្គការ Children in Families បានរាយការណ៍ថា គិតមកដល់បច្ចុប្បន្នគឺមានសុំកូនក្នុងប្រទេសចំនួន ៤៩ ករណីពីក្នុងកម្មវិធីថែទាំដោយគ្រួសារធម៌របស់ពួកគេ បូករួមជាមួយបួនករណីទៀតដែលបច្ចុប្បន្នកំពុងដំណើរការ ។

ការសិក្សារបស់យើងសាកសួរអំពីកត្តាដែលនាំឱ្យកុមារបែកចេញពីគ្រួសារ។ ភាពក្រីក្រត្រូវបានកំណត់ថាជាបញ្ហាចម្បងដែលនាំឱ្យមានការបោះបង់ចោលកុមារ ដោយទទួលស្គាល់ថា ភាពក្រីក្រ ក៏ជាកត្តាជំរុញឱ្យមានអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន និងការមិនអើពើផងដែរ ហើយករណីទាំងនោះនីមួយៗ គឺសុទ្ធតែអាចនាំឱ្យមានការបំបែកកុមារពីគ្រួសារ។ ឪពុកម្តាយធ្វើចំណាកទៅធ្វើការងារ ក៏ជាកត្តាដែលគេច្រើនលើកឡើងផងដែរ។ អ្នកផ្តល់ចម្លើយមួយចំនួនក៏បានលើកឡើងអំពីការលែងលះថាជាមូលហេតុនៃការបំបែកកុមារចេញពីគ្រួសារដែរ។

ពួកយើងពុំបានជួបការមាក់ងាយរើសអើងគួរកត់សម្គាល់ណាមួយអំពីសុំកូននោះឡើយ។ ជាក់ស្តែងគ្រួសារចិញ្ចឹមមួយចំនួនដែលពួកយើងបានជជែកជាមួយ បានរាយការណ៍នូវការឆ្លើយតបជាវិជ្ជមានជាខ្លាំងអំពីសហគមន៍របស់ពួកគេ។ ទោះយ៉ាងនេះ មានការមាក់ងាយរើសអើងទាក់ទងជាមួយការក្លាយជាម្តាយដោយមិនមានប្តី/វ័យជំទង់ និងពិការភាព ដែលកត្តាទាំងពីរនេះ ជាមូលហេតុចម្បងនៃការចោល និងបោះបង់ទារក។ ម្តាយវ័យក្មេង (ម្តាយមួយចំនួននៅជាកុមារនៅឡើយ) និងស្ត្រីដែលមានកូនក្រៅចំណងអាពាហ៍ពិពាហ៍មានអារម្មណ៍ភ័យខ្លាចការផាត់ចេញរបស់សង្គម ហេតុដូច្នេះហើយទើបមានការសន្មតថា ពួកគេច្រើនតែបោះបង់ទារកទើបកើតរបស់ខ្លួន មិនថាបោះបង់នៅក្នុងមន្ទីរពេទ្យ ឬនៅក្នុងសហគមន៍ក្តី។ កុមារកើតមកមានពិការភាពផ្នែកអភិវឌ្ឍន៍លូតលាស់ ឬកម្សោយផ្នែករាងកាយ[34] ក៏អាចត្រូវបានមើលឃើញថា ជាបន្ទុកដែលគ្រួសារពុំអាចរ៉ាប់រងបាន ជាពិសេសប្រសិនស្ថានភាពរបស់ទារកនោះអាចធ្វើឱ្យត្រូវចំណាយខ្ពស់ចំពោះថ្លៃព្យាបាល ជាហេតុធ្វើឱ្យកុមារនោះត្រូវប្រឈមហានិភ័យខ្ពស់ចំពោះការបោះបង់ចោល។ ដូចគ្នានេះដែរ កុមារទាំងនោះត្រូវបានគេមើលឃើញថា ជាបន្ទុកដែលមានគ្រួសារចិញ្ចឹមតិចតួចប៉ុណ្ណោះ ដែលមានឆន្ទៈទទួលយកបន្ទុកទាំង

[34] ជនមានពិការភាពរួមទាំងជនដែលមានពិការភាពរាងកាយ ផ្លូវចិត្ត សតិបញ្ញា ឬអង្គវិញ្ញាណរយៈពេលវែងដែលមានអន្តរទំនាក់ទំនងជាមួយឧបសគ្គារាំងផ្សេងៗជាច្រើន អាចជាឧបសគ្គមិនឱ្យពួកគេអាចចូលរួមបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៅក្នុងសង្គមឱ្យបានស្មើភាពជាមួយអ្នកដទៃឡើយ។

នោះ។ NGOs រាយការណ៍ថា អ្នកផ្ដល់ការថែទាំជាគ្រួសារធម៌ និងសាច់ញាតិជាទូទៅមានចិត្តបើកចំហចំពោះការថែទាំកុមារមានតម្រូវការពិសេស ប៉ុន្តែពួកគេជួបឧបសគ្គរាំងដោយសារកត្តាពេលវេលា ថ្លៃចំណាយ ការបណ្ដុះបណ្ដាល និងខ្វះការគាំទ្រពីគ្រួសារ។[35]

ឧបសគ្គរាំងដ៏ធំមួយក្នុងការអនុវត្តនីតិវិធីសុំកូននៅក្រោមគោលនយោបាយ ស្ដីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤ គឺកង្វះចំណេះដឹងរបស់ប្រជាជនទូទៅស្ដីពីដំណើរការសុំកូនតាមផ្លូវច្បាប់ និងការសាយភាយនៃព័ត៌មានខុសដែលក្លាយជាមូលដ្ឋានធ្វើឱ្យកើតមានឥរិយាបថ និងអាកប្បកិរិយាទាំងនោះ។ ពលរដ្ឋកម្ពុជាជាច្រើននៅតែគិតថា ដើម្បីសុំកូនគឺត្រូវចុះឈ្មោះក្នុងបញ្ជីរង់ចាំនៅមន្ទីរពេទ្យ និងការរៀបចំដើម្បីទទួលបានទារកត្រូវគេបោះបង់តាមរយៈបុគ្គលិកមន្ទីរពេទ្យ។ អ្នកផ្ដល់ព័ត៌មានជាច្រើននាក់បានប្រាប់ពួកយើងថា កុមារត្រូវបាន «សុំ» ដោយលួចលាក់តាមរយៈការអនុវត្តបែបនេះ។ ប្រសិនបុគ្គលិកមន្ទីរពេទ្យជូនដំណឹងប្រាប់ទៅឪពុកម្ដាយនៅក្នុងបញ្ជីរង់ចាំរបស់ខ្លួនថា មានទារកទើបកើតត្រូវគេបោះបង់នៅមន្ទីរពេទ្យ ឪពុកម្ដាយទាំងនោះអាចបង់ប្រាក់ «សគុណ» ជូនបុគ្គលិកមន្ទីរពេទ្យដែលបានផ្ដល់ដំណឹងប្រាប់ពួកគេ និងរៀបចំឱ្យយកទារកនោះពីមន្ទីរពេទ្យ។ បន្ទាប់មក ពួកគេយកកុមារទៅសាលាឃុំដើម្បីចុះបញ្ជីក្នុងសៀវភៅគ្រួសាររបស់ខ្លួនក្នុងនាមជាកូនបង្កើតរបស់ខ្លួន។[36]

បន្ថែមលើនេះ ពួកគេច្រើនតែច្រឡំគ្នារវាងការថែទាំដោយគ្រួសារធម៌ និងការសុំកូន ដោយពុំបានដឹងថាពួកគេត្រូវឆ្លងកាត់ដំណើរការផ្នែកច្បាប់សម្រាប់សុំកូន ដើម្បីធានានូវសិទ្ធិរបស់កុមារក្នុងការទទួលបានគ្រួសារ និងអត្តសញ្ញាណ ព្រមទាំងសិទ្ធិ និងបុព្វសិទ្ធិទាំងអស់ពាក់ព័ន្ធជាមួយចំណុចនេះ។ មានមនុស្សតិចតួចប៉ុណ្ណោះដែលបានដឹងអំពីនីតិវិធីច្បាប់ជាការតម្រូវ ហើយនៅពេលពួកគេដឹងហើយ ពួកគេក៏ពុំចូលចិត្តទៅតុលាការនោះដែរ។ ឪពុកម្ដាយចិញ្ចឹមដែលមានសក្ដានុពល រួមទាំងឪពុកម្ដាយធម៌ដែលចង់សុំកុមារស្ថិតក្រោមការថែទាំរបស់ខ្លួន ច្រើនតែមើលឃើញដំណើរការសុំកូនផ្លូវការ (ពោលគឺដំណើរការតុលាការ/តាមផ្លូវច្បាប់) ជាអវិជ្ជមាន៖ ពួកគេយល់ឃើញថា ដំណើរការនេះភាពមានស្មុគស្មាញ និងគួរឱ្យភ័យខ្លាច ដោយជឿជាក់ថា នឹងត្រូវចំណាយពេលយូរ និងអស់ប្រាក់ច្រើន។[37]

ដើម្បីបំបាត់ទស្សនៈខុសឆ្គងដែលកើតមានជាទូទៅទាំងនេះ ជាការល្អគួរអនុវត្តការសិក្សាមួយអំពីទស្សនៈយល់ឃើញ (ខុសឆ្គង) ដែលច្រើនកើតមានស្ដីអំពីសុំកូន។ ការសិក្សានេះអាចផ្ដល់មូលដ្ឋានព័ត៌មានសម្រាប់យុទ្ធនាការលើកកម្ពស់ការយល់ដឹងផ្អែកលើភស្តុតាងមួយដែលអាចជួយធ្វើឱ្យសាធារណជនស្គាល់ច្បាស់ អំពីគោលនយោបាយ និងនីតិវិធីសុំកូន ជាពិសេសស្ដីអំពី**ចំណុចដែលត្រូវទៅសុំកូននៅក្នុងបន្ទាត់នៃដំណើរការថែទាំកុមារដែលមានលក្ខណៈជាច្រវាក់ថែទាំគ្រប់ជ្រុងជ្រោយពីដើមទីរហូតទៅ** (continuum of care) ដូចមាន

[35] Muney R, Nguon S and Chhim T. (2024) Kinship and Foster Care: Understanding Current Practice in Cambodia. Phnom Penh: Family Care First, 133.

[36] កង្វះការចុះបញ្ជីកំណើតនៅមន្ទីរពេទ្យបានជួយសម្រួលដល់ការប្រតិបត្តិនេះ។ សូមមើលបន្ថែមនៅក្នុងផ្នែកការចុះបញ្ជីកំណើតខាងក្រោម។

[37] Muney R, Nguon S and Chhim T. (2024) Kinship and Foster Care: Understanding Current Practice in Cambodia. Phnom Penh: Family Care First, 133.

ចែងក្នុងគោលនយោបាយក្នុងឆ្នាំ២០២៤ ស្តីពីការថែទាំជំនួសចំពោះកុមារ។[38] មានគំរូជាច្រើនដូចជានៅក្នុងរូបភាពទី ១[39] ជាដើម ដែលអាចកែសម្រួលឱ្យត្រូវតាមបរិបទកម្ពុជា។




**រូបភាពទី ១៖** ប្រវាក់នៃថែទាំគ្រប់ជ្រុងជ្រោយពីដើមទីរហូតទៅ (continuum of care) (ប្រភព៖ Faith to Action)

ទោះយ៉ាងនេះក្តី ឧបសគ្គរាំងដ៏ធំបំផុតមួយក្នុងការអនុវត្តគោលនយោបាយស្តីពីការសុំកូនដែលអ្នកចូលរួមរបស់យើងបានកំណត់ឃើញ គឺដោយសារមាន**ច្រកផ្លូវពីរសម្រាប់សុំកូននាពេលបច្ចុប្បន្ន៖** ច្រកផ្លូវទីមួយ គឺគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងនីតិវិធីសម្រាប់អនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយច្រកផ្លូវមួយ គឺតាមរយៈក្រមរដ្ឋប្បវេណី ដែលជាច្រកផ្លូវអាទិភាព ប៉ុន្តែអាចរំលងវិធានការកិច្ចការពារកុមាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាហេតុពុំអាចប្រកាន់ខ្ជាប់តាមគោលនយោបាយស្តីពីកិច្ចការពារកុមារ និងការថែទាំជំនួសរបស់កម្ពុជានាពេលបច្ចុប្បន្នបានទេ។ ឧទាហរណ៍ ថ្វីបើសុំកូនអន្តរប្រទេស ត្រូវបានផ្អាកក៏មែនពិត ប៉ុន្តែ

ចំណុចនេះ ក៏ជាអនុសាសន៍របស់ UNCRC នៅក្នុងមតិសង្កេតសន្និដ្ឋានរបស់ខ្លួនឆ្នាំ ២០២២ ផងដែរ។ សូមមើល United Nations Committee on the Rights of the Child (UNCRC). (2022) Concluding observations on the combined fourth to sixth periodic reports of Cambodia. United Nations, 17.

[39] https://www.faithtoaction.org/coc/

ពលរដ្ឋបរទេសមួយចំនួនដែលមានទីលំនៅក្នុងប្រទេសកម្ពុជាបានសុំកុមារកម្ពុជាតាមនីតិវិធីក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះចន្លោះប្រហោងផ្នែកច្បាប់នេះ បានសាបព្រោះឱ្យមានការភាន់ច្រឡំសម្រាប់ឪពុកម្តាយចិញ្ចឹមជាសក្តានុពល ហើយអាចមានផលវិបាកអវិជ្ជមានសម្រាប់កុមារដែលជាកូនចិញ្ចឹមនៅពេលពួកគេធំឡើង។ យើងនឹងវិលមកជជែកអំពីចំណុចនេះជាថ្មីម្តងទៀតនៅពេលយើងលើកឡើងអំពីចន្លោះខ្វះខាតផ្នែកច្បាប់។

**អនុសាសន៍៖**

→ធ្វើការសិក្សាស្រាវជ្រាវស្តីពីទិដ្ឋភាពផ្សេងៗនៃការបោះបង់ចោលកុមារ ទស្សនៈយល់ឃើញ និងឥរិយាបថអំពីសុំកូន (មុនពេលធ្វើយុទ្ធនាការការលើកកម្ពស់ការយល់ដឹងស្តីពីការសុំកូន) ដើម្បីជាមូលដ្ឋានព័ត៌មានសម្រាប់ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រក្នុងការបង្ការទប់ស្កាត់ការបោះបង់កុមារ និងយុទ្ធនាការការលើកកម្ពស់ការយល់ដឹងអំពីសុំកូន។

→ចាត់បេសកកម្មឱ្យមានយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពីសុំកូន (យុទ្ធនាការដោយផ្ទាល់ និងយុទ្ធនាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម) ដែលលើកទឹកចិត្តគ្រួសារឱ្យធ្វើជាគ្រួសារធម៌ និងសុំកូន (តាមផ្លូវច្បាប់) រួមទាំងសម្រាប់កុមារមានតម្រូវការពិសេស កុមារា កុមារធំ និងកុមារដទៃទៀត ដែលពិបាកទុកដាក់។ ការផ្តល់សារអាចផ្អែកលើការសិក្សាអំពីទស្សនៈយល់ឃើញរបស់សង្គមដូចបានផ្តល់យោបល់ខាងលើ ដើម្បីលុបបំបាត់រាល់ទស្សនៈខុសឆ្គង និងដើម្បីអប់រំពលរដ្ឋកម្ពុជា ក៏ដូចជាពលរដ្ឋបរទេសអំពីផលវិបាកផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមដែលកើតចេញពីការមិនគោរពតាម គោលនយោបាយស្តីពីការសុំកូនផ្លូវការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមកលើកុមារ និងគ្រួសារចិញ្ចឹម។

→ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងកិច្ចសហការជាមួយក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាលអាចដំណើរការកម្មវិធីបញ្ជ្រាបការយល់ដឹងមួយដែលផ្តោតដោយចំពោះសម្រាប់បុគ្គលិកមន្ទីរពេទ្យដើម្បីទប់ស្កាត់ការបោះបង់កុមារ និងការប្រតិបត្តិនៃការសុំកូនក្រៅផ្លូវការតាមរយៈការធ្វើឱ្យពួកគេបានជ្រាបពីផលវិបាកផ្នែកច្បាប់ជាសក្តានុពលសម្រាប់ពួកគេ ក៏ដូចជាគ្រោះថ្នាក់ជាសក្តានុពលដែលអាចកើតមានចំពោះសិទ្ធិ និងសុខុមាលភាពរបស់កុមារ ព្រមទាំងដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្រកផ្លូវស្របច្បាប់សម្រាប់សុំកូន។ សូមមើលបន្ថែមនៅក្នុងផ្នែក***កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលអន្តរក្រសួង*** ខាងក្រោម។

→ធានាឱ្យបានថា តុលាការអនុវត្តក្រមរដ្ឋប្បវេណី (ដែលចាំបាច់ត្រូវកំណត់និយមន័យជាថ្មី ដើម្បីចែងថាក្រមនេះត្រូវអនុវត្តតែចំពោះពលរដ្ឋកម្ពុជាប៉ុណ្ណោះ) ប្រកបដោយសង្គតិភាពឱ្យមានការចូលរួមពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅក្នុងដំណើរការសុំកូនស្របច្បាប់ ដោយធានាឱ្យបានថាសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តស្តីពីកិច្ចការពារកុមារត្រូវបានអនុវត្តតាម ហើយមានលក្ខណៈដាក់លាក់ចំពោះការសុំកូនដោយជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា។

## ៤. គំហើញសម្រាប់រដ្ឋាភិបាល/អង្គការមិនមែនរដ្ឋាភិបាល

យើងបានកត់សម្គាល់ឃើញទិដ្ឋភាពជាច្រើនដែលរាជរដ្ឋាភិបាល និង NGOs គួរឆ្លើយតបដើម្បីពង្រឹងនីតិវិធីសុំកូន៖ ភាពខ្វះចន្លោះផ្នែកចំណេះដឹង ការសម្របសម្រួលនិងកិច្ចសហការអន្តរក្រសួង ភាពខ្វះចន្លោះផ្នែកច្បាប់ ការរក្សាកំណត់ត្រា និងការគ្រប់គ្រងករណី ព្រមទាំងការកសាងសមត្ថភាព។

### ភាពខ្វះចន្លោះផ្នែកចំណេះដឹង

បុគ្គលិករាជរដ្ឋាភិបាលមួយចំនួន ដែលទទួលខុសត្រូវលើការងារសុំកូន ហើយដែលទទួលបន្ទុកទូទៅទាក់ទងជាមួយការថែទាំជំនួស និងកិច្ចការពារកុមារ ទទួលស្គាល់ថា ពួកគេខ្វះចំណេះដឹង និងជំនាញគ្រប់គ្រាន់ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយស្តីពីការសុំកូន ជាពិសេសនៅតាមឃុំ ដែលជាអ្នកអនុវត្តជួរមុខ (គ.ក.ន.ក) និងនៅថ្នាក់ស្រុក (ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមថ្នាក់ស្រុក (SASWO)) ក៏ដូចជានៅថ្នាក់ខេត្ត (មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។ ពេលខ្លះ ពួកគាត់ក៏មានការយល់ឃើញខុសឆ្គងដូចសាធារណជនទូទៅមួយចំនួនដែរទាក់ទងនឹងនីតិវិធីដូចបានកត់សម្គាល់ខាងលើ។ បុគ្គលិកមួយចំនួនត្អូញត្អែរថា ពួកគេពុំបានទទួលព័ត៌មានគ្រប់គ្រាន់ស្តីពីសកម្មភាព និងគំនិតផ្តួចផ្តើមរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាពាក់ព័ន្ធនឹងការងាររបស់ខ្លួនឡើយ។

ពួកយើងក៏បានកត់សម្គាល់ឃើញផងដែរនៅក្នុងពេលចុះទៅតាមមូលដ្ឋានរបស់យើងថា សូម្បីតែមណ្ឌលថែទាំដែលដំណើរការដោយរដ្ឋក៏មានចំណេះដឹងមានកម្រិតកំណត់ ស្តីអំពីការចូលរួមនៅក្នុងការបង្វែរកុមារដែលស្ថិតក្រោមការថែទាំរបស់ពួកគេឱ្យទៅជាការថែទាំដោយសាច់ញាតិ ឬការថែទាំដោយគ្រួសារធម៌វិញ ហើយពួកគេក៏ពុំបានចូលរួមក្នុងការសុំកូនក្នុងប្រទេសនោះដែរ ដោយនោះប្រហែលបណ្តាលមកពីកង្វះបុគ្គលិកជាអ្នកសង្គមកិច្ចដែលមានពេលវេលាអាចធ្វើការលើការងារគ្រប់គ្រងករណី ដែលបច្ចុប្បន្នជាការទទួលខុសត្រូវរបស់ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមថ្នាក់ស្រុក ក្នុងកិច្ចសហប្រតិបត្តិការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង គ.ក.ន.ក។ ចំណុចនេះ ជាការបង្ហាញអំពីភាពធកល្វែងដ៏ធំនៅក្នុងការធ្វើផែនការទុកដាក់កុមារជាអចិន្ត្រៃយ៍សម្រាប់កុមារដែលពុំមានការថែទាំពីឪពុកម្តាយ ដូចបានកំណត់ក្នុងគោលនយោបាយរបស់រដ្ឋាភិបាល។[40]

ដោយហេតុថា មូលហេតុឫសគល់នៃការបំបែកកុមារចេញពីគ្រួសារ គឺកើតមាននៅថ្នាក់សហគមន៍ ហេតុនេះ ជាការចាំបាច់ណាស់ដែលបុគ្គលិកជួរមុខជាអ្នកមានភារកិច្ចក្នុងការដោះស្រាយបញ្ហានេះ គឺបានទទួលព័ត៌មានគ្រប់គ្រាន់ ហើយត្រូវបានបំពាក់ដោយជំនាញចាំបាច់ដើម្បីដោះស្រាយនូវបញ្ហាការបំបែកកុមារចេញពីគ្រួសារ ប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងនេះក្តី ជនបង្គោល គ.ក.ន.ក ជារឿយៗតែងតែមានបន្ទុកការងារច្រើនហួសប្រមាណ ហើយបើទោះជាបានទទួលការបណ្តុះបណ្តាលក្តី ក៏ពួកគេប្រហែលជាមិនចាំ

[40] ចំណុចនេះមានចែងនៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ១០១៣ (អំឡុងពេលសាកល្បងចិញ្ចឹម)៖ "ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំជាគោលការណ៍យ៉ាងតិច ៦ (ប្រាំមួយ) ខែ។"

ព័ត៌មាន ឬមិនអាចនឹកឃើញព័ត៌មានទាំងនោះនៅពេលដែលត្រូវចុះអនុវត្តការងារនោះឡើយ។ ហេតុដូច្នេះ ប្រហែលជាការល្អក្នុងការអនុវត្តកម្មសិក្សា ពោលគឺជាការប្រតិបត្តិដោយមានការជួយចង្អុលបង្ហាញដែលត្រូវបានតាក់តែងឡើងដើម្បីផ្តល់ឱ្យ គ.ក.ន.ក ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមថ្នាក់ស្រុក និងជនបង្គោលមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឱ្យបានទទួលចំណេះដឹងបែបអនុវត្តជាក់ស្តែង និងមានការមើលខុសត្រូវស្តីអំពីនីតិវិធីនៃការធ្វើផែនការទុកដាក់កុមារអចិន្ត្រៃយ៍។ វគ្គកម្មសិក្សាទាំងនេះ គួរតែជាការបង្ហាញពួកគេបែបការអនុវត្តផ្ទាល់នៅក្នុងដំណើរការ នៃការជួយជ្រោមជ្រែងកុមារដែលពុំមានការថែទាំពីឪពុកម្តាយនៅក្នុងដំណើរការទាំងមូលពីដើមដល់ចប់ ដោយក្នុងនោះរួមមានទាំងការប៉ាន់ប្រមាណ និងការទុកដាក់នៅក្នុងការថែទាំជំនួស ហើយប្រសិនពុំមានជម្រើសផ្សេងទៀតទេ គឺគួរតែមានការសុំកូនក្នុងប្រទេសធ្វើឡើង។

ឧបសគ្គរាំងមួយសម្រាប់ការផ្ទេរចំណេះដឹងដែលយើងបានកំណត់ឃើញ គឺ**ការផ្លាស់ប្តូរការងារជាញឹកញាប់របស់បុគ្គលិករដ្ឋ** ដែលជាកត្តារាំងមិនអាចឱ្យឧត្តមានុវត្តន៍មានភាពរឹងពឹងដោយសារតែភាពមានកម្រិតនៃការផ្ទេរចំណេះដឹងពីបុគ្គលិកមួយទៅបុគ្គលិកបន្ទាប់ទៀត ជាពិសេសទាក់ទងនឹងយន្តការជារចនាសម្ព័ន្ធសម្រាប់សុំកូននៅថ្នាក់ក្រោមជាតិ។ បន្ថែមលើនេះ កិច្ចខិតខំចំពោះការធ្វើវិមជ្ឈការបានផ្តល់លទ្ធផលធ្វើឱ្យមានមនុស្សថ្មីៗចូលមកកាន់មុខតំណែងបុគ្គលិកសំខាន់ៗ ដោយពុំមានជំនាញចាំបាច់ជាមុន ហេតុនេះពួកគេត្រូវការការជួយមើលខុសត្រូវ និងការបង្វឹកដើម្បីកសាងសមត្ថភាព និងទំនុកចិត្តលើខ្លួនឯង ក្នុងការឈានទៅបំពេញភារកិច្ចរបស់ខ្លួនទាក់ទងនឹងកិច្ចការពារកុមារ។ ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសក៏ដូចជាមុខតំណែងក្នុងរចនាសម្ព័ន្ធបំពេញបន្ថែម ពិតជាអាចជួយកាត់បន្ថយចំណុចខ្វះចន្លោះនេះបាន។

### អនុសាសន៍៖

→រៀបចំ*កម្មសិក្សា* សម្រាប់បុគ្គលិកថ្នាក់ស្រុក និងបុគ្គលិកថ្នាក់មូលដ្ឋាន ដើម្បីបង្ហាញការអនុវត្តជាក់ស្តែងដល់ពួកគេអំពីនីតិវិធីទាំងមូលសម្រាប់ការចាត់ចែងការងារជាមួយកុមារដែលពុំមានការថែទាំពីឪពុកម្តាយ រហូតដល់ដំណាក់កាលសុំកូនផងដែរប្រសិនបើមាន។

→ធានាឱ្យបានថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់អ្នកពាក់ព័ន្ធអំពីការអភិវឌ្ឍ និងការផ្លាស់ប្តូរថ្មីៗនៅក្នុងគោលនយោបាយយ៉ាងច្បាស់លាស់ និងទាន់ពេលវេលា។

→បង្កការចូលរួមពីមណ្ឌលថែទាំកុមារនៅក្នុងការធ្វើកម្មវិធីបង្រួបបង្រួមគ្រួសារ ការថែទាំដោយគ្រួសារធម៌ និងសុំកូន ដើម្បីបង្កើតច្រកនៃការថែទាំពីស្ថាប័នថែទាំកុមារទៅជាការថែទាំកុមារតាមគ្រួសារ។

## ការសម្របសម្រួល ភាពសហការ និងនិរន្តរភាព

ដូចបានបញ្ជាក់ខាងដើមហើយថា រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្ហាញសុឆន្ទៈ និងគំនិតផ្តួចផ្តើមជាវិជ្ជមាននៅក្នុងកំណែទម្រង់ការថែទាំក្នុងអំឡុងពេលជាងមួយទសវត្សរ៍កន្លងមក។ អង្គការមិនមែនរដ្ឋាភិបាលបានឈានចូលមកគាំទ្រការអនុវត្តឧត្តមានុវត្តន៍អន្តរជាតិ និងបទដ្ឋានអន្តរជាតិរបស់រដ្ឋាភិបាល។ អង្គការទាំងនោះក៏បានជួយត្រួសត្រាយផ្លូវលើកម្មវិធីកិច្ចការពារកុមារ និងកម្មវិធីថែទាំជំនួសជាច្រើនផងដែរ ដូចជាកម្មវិធីថែទាំដោយគ្រួសារធម៌ និងសុំកូនក្នុងប្រទេសជាដើម។

ហេតុដូច្នេះ មន្ត្រីថ្នាក់មូលដ្ឋាន ជារឿយៗតែងងាកទៅរកពួកគេចំពោះសេចក្តីត្រូវការសម្រាប់ការថែទាំចាំបាច់នានារបស់កុមារដែលត្រូវបានទុកចោលដោយពុំមានការថែទាំពីឪពុកម្តាយ។ ទោះយ៉ាងនេះក្តី ការអនុវត្តនេះប្រហែលពុំមាននិរន្តរភាពសម្រាប់រយៈពេលវែងនោះទេ បើគិតទៅលើការប្រែប្រួលយ៉ាងរហ័សនៃទិដ្ឋភាពមូលនិធិរបស់ម្ចាស់ជំនួយ។

ដើម្បីឱ្យមាននិរន្តរភាព ជាការសំខាន់ដែលត្រូវ**បង្កើនការវិនិយោគរបស់រដ្ឋាភិបាលនៅក្នុងកម្មវិធីការថែទាំជំនួស**។ នាពេលបច្ចុប្បន្ន មានវិបត្តិមូលនិធិនៅទូទាំងពិភពលោកដែលញ៉ាំងឱ្យកើតមានដោយសារតែការដកជំនួសបរទេសភ្លាមៗពីសំណាក់ USAID និងម្ចាស់ជំនួសដទៃទៀត ហើយមានអង្គការជាច្រើនដែលត្រូវបញ្ឈប់ការងារបុគ្គលិក។ នៅពេល NGOs ដែលបច្ចុប្បន្នជាអ្នកទទួលខុសត្រូវចម្បងចំពោះកម្មវិធីនានាដូចជាកម្មវិធីថែទាំដោយគ្រួសារធម៌ត្រូវអស់មូលនិធិ នោះពួកគេប្រហែលជាអាចចាកចេញពីប្រទេសកម្ពុជាដោយពុំបានផ្ទេរជំនាញចាំបាច់នានានៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីអាចបន្ត និងធ្វើជឿនលឿនបាននូវកម្មវិធីដ៏មានភាពចាំបាច់ទាំងនេះឱ្យដំណើរការទៅមុខទៀតបាន។ ដើម្បីអាចត្រៀមខ្លួនរួចរាល់ ជាពិសេសសម្រាប់ការអនុវត្តនៅថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ) ភាពខ្វះចន្លោះនានានៅក្នុងកិច្ចសហការ ជាពិសេសគម្លាតរវាងថ្នាក់ស្រុក និងថ្នាក់ឃុំ គឺជាបញ្ហាដែលចាំបាច់ត្រូវដោះស្រាយ។

ហេតុដូច្នេះ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការនានា ដើម្បីធ្វើការប្រគល់សេវាសារវន្តែមកឱ្យកម្លាំងសេវាសង្គមថ្នាក់មូលដ្ឋាន/ថ្នាក់ជាតិ។ មូលនិធិរបស់អង្គការ គឺអាចបន្តយកទៅប្រើប្រាស់ដើម្បីកសាងសមត្ថភាព ប៉ុន្តែការដកចេញនូវការគាំទ្ររបស់អង្គការអាចផ្តល់ភាពជឿទុកចិត្តទៅឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតស៊ូមតិឱ្យមានការចាត់កញ្ចប់ថវិកាបន្ថែម ដើម្បីបន្សុីកម្មវិធីនានា ដូចជា សេវារក្សាគ្រួសារឱ្យនៅជួបជុំគ្នា ការថែទាំដោយសាច់ញាតិតាមផ្លូវការ ការថែទាំដោយគ្រួសារធម៌ និងសេវាសុំកូនក្នុងប្រទេសជាដើម នៅក្រោមឆ័ត្រការងាររបស់រាជរដ្ឋាភិបាល។ ការធ្វើបែបនេះ អាចបង្កើតឱ្យមានកម្លាំងសេវាសង្គមរបស់កម្ពុជាកាន់តែរឹងមាំថែមទៀត ដែលជាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចសម្រាប់ប្រទេស៖ តាមរយៈការបានទទួលការបណ្តុះបណ្តាលស្តីពីនីតិវិធីសុំកូន អ្នកផ្តល់សេវាសង្គមកិច្ច អាចមានជំហររឹងមាំ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះសេចក្តីត្រូវការផ្នែកសុំកូន ហើយស្របពេលជាមួយគ្នានោះ ក៏អាចជំរុញសមត្ថភាពឱ្យអ្នកផ្តល់សេវាសង្គមកិច្ចឆ្លើយតបបានសព្វគ្រប់ជ្រៅជ្រះចំពោះបញ្ហាប្រឈមជាច្រើនផ្នែកកិច្ចការពារកុមារ។ បន្ថែមលើនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចដើរតួនាទីជាឆ្មាំទ្វារឃ្លាំមើលបានកាន់តែប្រសើរ ដូចជានៅក្នុងដំណើរការនៃការផ្តល់អាជ្ញាប័ណ្ណសម្រាប់មណ្ឌលថែទាំកុមារ ការថែទាំដោយគ្រួសារធម៌ និងកម្មវិធីសុំកូនក្នុងប្រទេស ខណៈដែលអាចច្របាច់បញ្ចូលសេវាទាំងនេះផងដែរ ដើម្បី**បង្កើតទៅជាតារាងការងារសម្រាប់ការទុកដាក់អចិន្ត្រៃយ៍**ចំពោះកុមារដែលត្រូវការការថែទាំពីឪពុកម្តាយ។ បន្ថែមលើនេះ សេវាទាំងនេះអាចត្រូវបានច្របាច់បញ្ចូលជាមួយកម្មវិធីពិការភាព ដូចជា ការគាំទ្រដល់ឪពុកម្តាយដើម្បីបង្ការទប់ស្កាត់ការបោះបង់កុមារចោល ការយកភ័ស្តុតាងមកអនុវត្ត ដើម្បីបង្ហាញថាតើកុមារដែលមានពិការភាពអាចទទួលបានលទ្ធផលកាន់តែប្រសើរនៅក្នុងការថែទាំតាមគ្រួសារ។

ដោយសារបុគ្គលិកនៅថ្នាក់ឃុំមានបន្ទុកការងារហួសប្រមាណ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍ក្នុងការពិចារណា**បង្កើតប្រព័ន្ធគណៈកម្មាធិការថែទាំជំនួស** ដោយមើលទៅតាមគំរូរបស់ប្រទេសយូហ្គង់ដា។[41] គណៈកម្មាធិការថែទាំជំនួសយូហ្គង់ដាដែលបានបង្កើតឡើងក្នុងឆ្នាំ២០១២ ត្រូវបានអនុវត្តសាកល្បងក្នុងនាមជាយន្តការរដ្ឋបាលថ្នាំទ្វារ ដើម្បីដំណើរការលើនីតិវិធីទុកដាក់ក្នុងការថែទាំដោយគ្រួសារធម៌ និងគ្រួសារចិញ្ចឹម ដោយគិតទៅលើឧត្តមប្រយោជន៍របស់កុមារ។ យោងតាម Fronek et al លើកឡើងថា៖

> *គោលបំណងនៃគណៈកម្មាធិការថែទាំជំនួសដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ គឺដើម្បីផ្តល់ការពិគ្រោះយោបល់ដោយអ្នកវិជ្ជាជីវៈជំនាញ និងការធ្វើផែនការនៅក្នុងករណីស្មុគស្មាញផ្សេងៗ...ក្នុងបំណងដើម្បីដាក់ឱ្យដំណើរការគណៈកម្មាធិការនេះនៅទូទាំងប្រទេសកម្ពុជា។ តួនាទីជាថ្នាំឃ្លាំមើលរបស់គណៈកម្មាធិការនេះ គឺសង្កត់ធ្ងន់លើសារៈសំខាន់នៃអន្តរាគមន៍ដែលមានជំនាញ ដែលផ្តោតការយកចិត្តទុកដាក់ជាចម្បងលើកុមារ និងការប៉ាន់ប្រមាណគ្រួសារ ការរក្សាកុមារឱ្យនៅជាមួយគ្រួសារ និងការពង្រឹងគ្រួសារ និងគាំទ្រដល់ការថែទាំដោយសាច់ញាតិអនុលោមតាមបទដ្ឋានជាតិ និងអន្តរជាតិ។*[42]

បច្ចុប្បន្នមានរចនាសម្ព័ន្ធសម្រាប់ពិនិត្យឡើងវិញលើការសុំកូននៅថ្នាក់ជាតិ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ប៉ុន្តែគណៈកម្មាធិការថែទាំជំនួសនៅថ្នាក់ស្រុកដែលរួមមានសមាសភាពអ្នកប្រកបវិជ្ជាជីវៈថែទាំនានា គឺនឹងអាចបង្កើតឱ្យមានការចូលរួមពីសហគមន៍ជួរមុខក្នុងការធ្វើផែនការទុកដាក់អចិន្ត្រៃយ៍សម្រាប់កុមារដែលត្រូវការការថែទាំពីឪពុកម្តាយ។[43] ហេតុដូច្នេះ គណៈកម្មាធិការនេះអាចទុកឱ្យមានចន្លោះសម្រាប់ទទួលធាតុចូលពីអ្នកពាក់ព័ន្ធនានា (សាច់ញាតិ អ្នកសង្គមកិច្ច ចៅក្រម បុគ្គលិកមន្ទីរពេទ្យ គ.ក.ន.ក មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអ្នកពាក់ព័ន្ធដទៃទៀតទាំងអស់) សម្រាប់សេចក្តីត្រូវការការថែទាំជំនួសទូលំទូលាយ។ ពួកគេក៏នឹងចែករំលែកការទទួលខុសត្រូវដែលបច្ចុប្បន្នជាបន្ទុកទាំងស្រុងដាក់មកលើជនបង្គោល គ.ក.ន.ក ដែលមានបន្ទុកការងារច្រើនហួសប្រមាណ ហើយមានការបណ្តុះបណ្តាលតិចតួច និងអត្រាលាឈប់ពីការងារខ្ពស់។ ការអនុវត្តការប៉ាន់ប្រមាណដើម្បីពិនិត្យថាតើគួររៀបចំគំរូគណៈកម្មាធិការនេះយ៉ាងដូចម្តេចដើម្បីឱ្យមានប្រសិទ្ធភាពបំផុត និងឱ្យអនុលោមតាមគោលនយោបាយរបស់កម្ពុជា រចនាសម្ព័ន្ធដែលមានស្រាប់ និងបទដ្ឋានអន្តរជាតិ គឺពិតជានឹងអាចចូលរួមចំណែកជួយបានជាច្រើន។

## សហប្រតិបត្តិការ និងការសម្របសម្រួលអន្តរក្រសួង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានបង្ហាញថា ក្រសួងចង់បង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួងដទៃទៀតរួមមានដូចជាក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ

[41] https://www.futurelearn.com/info/courses/alternative-care/0/steps/29813

[42] Fronek P, Common R, Rotabi KS, et al. (2019) Identifying and Addressing Risk in the Implementation of Alternative Care Policies in Cambodia. *Journal of Human Rights and Social Work* 4(2): 140-144, p. 142.

[43] ការងារនេះ ចាំបាច់ត្រូវអនុលោមតាមសៀវភៅណែនាំសម្រាប់ការអនុវត្តសុំកូនក្នុងប្រទេសដែលមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបង្កើតគណៈកម្មាធិការដើម្បីផ្គូផ្គងកុមារជាមួយគ្រួសារ។

ដើម្បីអាចអនុវត្តនីតិវិធីសុំកូន និងនីតិវិធីការពារកុមារដទៃទៀតឱ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងនោះអាចរួមមានដូចជា៖

- ក្រសួងយុត្តិធម៌៖ ដើម្បីបញ្ជ្រាបការយល់ដឹងដល់ចៅក្រម និងមេធាវីស្តីអំពីដំណើរការសុំកូន ពិនិត្យមើលអំពីអ្វីដែលពួកគេអាចធ្វើបានដើម្បីពន្លឿនដំណើរការសុំកូនក្នុងប្រទេស និងបិទ «ចន្លោះប្រហោងក្នុងក្រមរដ្ឋប្បវេណី»។ ថ្វីបើដំណើរការនេះ អាចជាដំណើរការវែងឆ្ងាយ និងស្មុគស្មាញក្តី ប៉ុន្តែជាការចាំបាច់ខ្លាំងណាស់ដែលត្រូវធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី ដើម្បីឆ្លុះបញ្ចាំងនឹងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារថ្មី ដោយរួមមានទាំងភាពច្បាស់លាស់ស្តីពីនីតិវិធីសុំកូនផងដែរ។ ដោយផ្តោតជាក់លាក់ទៅលើការគួរមានការបញ្ជាក់ឱ្យច្បាស់ថា ក្រមរដ្ឋប្បវេណីគឺអាចយកមកអនុវត្តតែសម្រាប់ពលរដ្ឋកម្ពុជាប៉ុណ្ណោះ ពោលគឺពុំមែនសម្រាប់ពលរដ្ឋបរទេសនោះឡើយ។
- ក្រសួងសុខាភិបាល៖ ដើម្បីបញ្ជ្រាបការយល់ដឹងដល់បុគ្គលិកមន្ទីរពេទ្យស្តីអំពីច្រកបណ្តាញសមស្របសម្រាប់ការទុកដាក់ទារកដែលត្រូវបានគេបោះបង់ឱ្យទទួលបានការថែទាំពីគ្រួសារ អភិវឌ្ឍគោលការណ៍ណែនាំស្តីអំពីការបោះបង់ទារកនៅមន្ទីរពេទ្យ ដាក់ពង្រាយបុគ្គលិកសង្គមកិច្ចឱ្យអន្តរាគមន៍ ក្នុងករណីមានការបោះបង់កុមារ និងចុះបញ្ជីរាល់កំណើតរស់ទាំងអស់។
- ក្រសួងមហាផ្ទៃ៖ ដើម្បីបញ្ជ្រាបការយល់ដឹងដល់ គ.ក.ន.ក និងបុគ្គលិកដទៃទៀតនៅក្រោមក្រសួងអំពីបញ្ហាពាក់ព័ន្ធជាមួយនីតិវិធីសុំកូន រួមទាំងការចេញសំបុត្រកំណើត និងការចុះបញ្ជីកំណើត (សូមមើលខាងក្រោម)

ពួកយើងយល់ស្របថា ជាការសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលអន្តរក្រសួងបន្ថែមទៀត ដើម្បីបិទភ្ជិតគម្លាតដ៏សំខាន់នៅក្នុងការអនុវត្តការងារសុំកូន។ **ការបណ្តុះបណ្តាលពហុវិស័យសម្រាប់អ្នកប្រកបវិជ្ជាជីវៈ** (ចៅក្រម មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បុគ្គលិកក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល) ស្តីអំពីនីតិវិធីប្រកបដោយតម្លាភាព និងយកកុមារជាគោលចម្បង រួមទាំងការសម្រេចចិត្តយ៉ាងទាន់ពេលវេលា និងភាពអនុលោមតាមច្បាប់សុំកូនយ៉ាងខ្ជាប់ខ្ជួន គឺមានសារៈសំខាន់យ៉ាងចាំបាច់ខ្លាំងណាស់។ នីតិវិធីទាំងអស់ចាំបាច់ត្រូវយកឧត្តមប្រយោជន៍របស់កុមារជាអាទិភាព ដោយត្រូវមានការវាយតម្លៃជាប្រចាំឈានទៅជានាឱ្យមានការបន្សុីជាមួយបទដ្ឋានអន្តរជាតិ។ ការងារនេះអាចជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រទូទៅ។

### អនុសាសន៍៖

→បង្កើនការវិនិយោគរបស់រដ្ឋាភិបាលនៅក្នុងការថែទាំជំនួស និងការធ្វើកម្មវិធីសុំកូនសម្រាប់និរន្តរភាពរយៈពេលវែង

→ស្វែងយល់អំពីលទ្ធភាពនៃការបង្កើតគំរូគណៈកម្មាធិការថែទាំជំនួសសម្រាប់ប្រទេសកម្ពុជាតាមរយៈការវាយតម្លៃថាតើធ្វើយ៉ាងណាដើម្បីឱ្យគំរូនេះ មានលក្ខណៈសមស្របតាមបរិបទរបស់កម្ពុជានៅក្នុងប្រព័ន្ធនាពេលបច្ចុប្បន្ន។

→បង្កើតផែនការយុទ្ធសាស្ត្រដែលផ្តល់អាទិភាពដល់ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួងបន្ថែមទៀតរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ រួមទាំងវគ្គបណ្តុះបណ្តាលពហុវិស័យស្តីពីច្បាប់ និងនីតិវិធីស្មុំកូន។ ការបណ្តុះបណ្តាលសម្រាប់កម្លាំងសេវាសង្គម នឹងផ្តល់អត្ថប្រយោជន៍បន្ថែមដល់ប្រទេសកម្ពុជាសម្រាប់យកទៅប្រតិបត្តិមិនត្រឹមតែក្នុងការងារស្មុំកូនតែប៉ុណ្ណោះទេ ដោយហេតុថាអ្នកផ្តល់សេវាសង្គមអាចហ្វឹកហាត់ធ្វើឱ្យជំនាញការប្រតិបត្តិទូទៅរបស់ខ្លួនកាន់តែមានលក្ខណៈប្រសើរថែមទៀត។

## គម្លាតផ្នែកច្បាប់

### *ស្មុំកូនក្នុងប្រទេស*

ដូចបានបញ្ជាក់ខាងលើមកហើយថា ស្មុំកូនក្នុងប្រទេសសម្រាប់ប្រទេសកម្ពុជា បច្ចុប្បន្នគឺស្ថិតក្រោមការអភិបាលរបស់ក្របខណ្ឌការងារផ្នែកច្បាប់ចំនួនពីរសំខាន់ៗ ជាហេតុបង្កើតឱ្យមានការភាន់ច្រឡំ និងចន្លោះប្រហោងដែលអាចបង្កការគំរាមកំហែងដល់សិទ្ធិរបស់កុមារ។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាមានចន្លោះខ្វះខាតជាច្រើនទាក់ទងនឹងនីតិវិធីស្មុំកូនក្នុងប្រទេស។ ដោយឡែកក្រមនេះ ខ្វះបទប្បញ្ញត្តិលម្អិតសម្រាប់៖

- ការជ្រើសរើស និងការប៉ាន់ប្រមាណគ្រួសារចិញ្ចឹមដែលមានសក្តានុពល៖ ក្រមរដ្ឋប្បវេណីពុំមានចែងថាតើធ្វើដូចម្តេចដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃគ្រួសារចិញ្ចឹមដែលមានសក្តានុពលនោះទេ ដែលចំណុចនេះ គឺមានសារៈសំខាន់ណាស់ក្នុងការធានាឱ្យបានថា កុមារត្រូវបានដាក់ទុកនៅក្នុងផ្ទះដែលមានលក្ខណៈសមស្រប។
- នីតិវិធីផ្គូផ្គង៖ ពុំមានគោលការណ៍ណែនាំស្តីពីវិធីដើម្បីផ្គូផ្គងកុមារជាមួយគ្រួសារចិញ្ចឹមសមស្របនោះទេ ដែលបញ្ហានេះអាចធ្វើឱ្យមានការផ្គូផ្គងខុសឆ្គង និងអាចមានសក្តានុពលបង្កគ្រោះថ្នាក់ដល់កុមារ។ មានតែកុមារដែលត្រូវបានប្រកាសតាមផ្លូវច្បាប់ថា មានលក្ខណសម្បត្តិអាចដាក់ឱ្យស្មុំបានប៉ុណ្ណោះ (បន្ទាប់ពីបានប្រើប្រាស់ជម្រើសតាមគ្រួសារអស់លទ្ធភាពរួចហើយ) ដែលគួរមានលក្ខណសម្បត្តិដាក់ឱ្យស្មុំបាន។
- ការគាំទ្រក្នុងអំឡុងពេលសាកល្បង៖ ក្រមរដ្ឋប្បវេណីពុំមានចែងអំពីយន្តការគាំទ្រក្នុងអំឡុងពេលការថែទាំសាកល្បង ឬការថែទាំដោយគ្រួសារធម៌មុនពេលស្មុំកូនអចិន្ត្រៃយ៍ត្រូវបានបញ្ចប់រួចរាល់នោះទេ។ ការគាំទ្រនេះ គឺចាំបាច់ណាស់ដើម្បីជួយដល់កុមារផង និងជួយដល់គ្រួសារចិញ្ចឹមដែលមានសក្តានុពលផង ក្នុងការសម្របខ្លួនជាមួយតួនាទីថ្មីរបស់ពួកគេ។
- រយៈពេលអន្តរកាលទៅកាន់ស្មុំកូនអចិន្ត្រៃយ៍៖ ដំណើរការនៃការធ្វើអន្តរកាលចេញពីការទុកដាក់ក្រោមការថែទាំសាកល្បង ឬការថែទាំដោយគ្រួសារធម៌ទៅដល់ស្មុំកូនអចិន្ត្រៃយ៍ គឺពុំទាន់កំណត់បានច្បាស់លាស់នៅឡើយ ជាហេតុទុកឱ្យមានចន្លោះធ្វើឱ្យមានភាពភាន់ច្រលំ និងអាចមានសក្តានុពលជួបនឹងបញ្ហាផ្នែកច្បាប់។

ចន្លោះខ្វះខាតទាំងនេះ ត្រូវបានដោះស្រាយមួយផ្នែកតាមរយៈប្រកាសស្តីពីនីតិវិធីនៃការថែទាំជំនួស ដូចមានចែងមានបញ្ជាក់ខាងលើ។ ថ្វីបើដូច្នេះក្តី លិខិតបទដ្ឋានគតិយុត្តសព្វថ្ងៃផ្តោតជាក់លាក់ទៅលើការសុំកូនក្នុងប្រទេស និងចំណងទំនាក់ទំនងជាមួយគោលនយោបាយស្តីពីសុខុមាលភាពសង្គម គឺនៅតែមានភាពចាំបាច់ដើម្បីអាចដោះស្រាយចន្លោះខ្វះខាតផ្នែកនីតិវិធីនេះឱ្យបានពេញលេញ។ ប្រព័ន្ធនាពេលបច្ចុប្បន្ននៅខ្វះខាតភាពច្បាស់លាស់ និងភាពស៊ីសង្វាក់គ្នាដែលជាហេតុធ្វើឱ្យមានចន្លោះខ្វះខាតនៅក្នុងការការពារផ្នែកច្បាប់ និងការផ្តល់ការថែទាំ។ ចន្លោះខ្វះខាតទាំងនោះរួមមានដូចជា៖

### នីតិវិធីមិនច្បាស់លាស់សម្រាប់ការមើលថែការពារ

- សមត្ថកិច្ច និងដំណើរការផ្នែកច្បាប់៖ នីតិវិធីដើម្បីផ្តល់ការថែទាំការពារគ្រាអាសន្នសម្រាប់កុមារ គឺនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ជាពិសេសទាក់ទងជាមួយថាតើអាជ្ញាធរមួយណាដែលមានអាណត្តិចម្បងក្នុងករណីអំពើហិង្សាក្នុងគ្រួសារ។ មាត្រា ៧ របស់ប្រកាសស្តីពីនីតិវិធីនៃការថែទាំជំនួស បានផ្តល់អំណាចដល់ គ.ក.ន.ក ដើម្បី «ធ្វើការទុកដាក់ជាបណ្តោះអាសន្ននៅក្នុងបរិយាកាសមានសុវត្ថិភាពជាមួយសាច់ញាតិ ឬនៅក្នុងការថែទាំដោយគ្រួសារចិញ្ចឹមមានមូលដ្ឋានក្នុងសហគមន៍» ប៉ុន្តែ *ច្បាប់ស្តីពីកិច្ចការពារពីអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ* ផ្តល់អំណាចដល់ក្រសួងកិច្ចការនារីដើម្បីអន្តរាគមន៍ (មាត្រា ១០) ហើយ «អាជ្ញាធរ» ថ្វីបើពុំបានបញ្ជាក់ជាក់លាក់ក្តី ប៉ុន្តែត្រូវបានចាត់ទុកថាជានគរបាលយុត្តិធម៌ក្នុងការផ្តល់ «ជម្រកបណ្តោះអាសន្ន» (មាត្រា ១៣)។ សមត្ថកិច្ចអាជ្ញាធរខុសៗគ្នាបែបនេះ អាចនាំឱ្យមានការភាន់ច្រឡំអំពី ថាតើនរណាជាអ្នកអនុវត្តអាណាព្យាបាលភាពតាមផ្លូវច្បាប់បណ្តោះអាសន្នមុនពេលបានដាក់សំណុំរឿងនៅតុលាការ។
- កុមារត្រូវគេបោះបង់៖ បញ្ហាសមកវិញ មានភាពច្បាស់លាស់សម្រាប់កុមារត្រូវគេបោះបង់ ដោយក្នុងនោះប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (DoSVY) ត្រូវបានប្រគល់អាណាព្យាបាលភាពតាមផ្លូវច្បាប់បណ្តោះអាសន្ន។ ទោះយ៉ាងនេះក្តី ភាពច្បាស់លាស់នេះ គឺពុំបានគ្របដណ្តប់ទៅលើស្ថានភាពដទៃទៀតឡើយ។

### សមត្ថកិច្ចរបស់មណ្ឌលថែទាំ

- ភាពមិនច្បាស់លាស់ផ្នែកច្បាប់៖ ច្បាប់ពុំបានបានចែងច្បាស់អំពីសមត្ថកិច្ចរបស់គ្រឹះស្ថានថែទាំកុមារក្នុងការផ្តល់ជាជម្រកគ្រាអាសន្ន និងការថែទាំសម្រាប់កុមារជាជនរងគ្រោះនៃការមិនអើពើ ការរំលោភបំពាន ការជួញដូរ ឬការកេងប្រវ័ញ្ចនោះឡើយ។ ថ្វីបើប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការការពារជនរងគ្រោះដោយការជួញដូរ អនុញ្ញាតឱ្យជម្រកសុវត្ថិភាពអាចរក្សាទុកជនរងគ្រោះជាកុមារក្តី ប៉ុន្តែប្រកាសនេះនៅខ្វះភាពជាក់លាក់ស្តីពីទំហំនៃសមត្ថកិច្ចនេះ ជាពិសេសក្នុងករណីការរក្សាទុកកុមារ គឺផ្ទុយពីឆន្ទៈរបស់កុមារ ឬរបស់ឪពុកម្តាយ។
- ភាពងាយរងគ្រោះចំពោះការចោទប្រកាន់៖ ភាពមិនច្បាស់លាស់នេះ ធ្វើឱ្យមណ្ឌលសុវត្ថិភាពអាចមានភាពងាយរងគ្រោះចំពោះការចោទប្រកាន់អំពីបទបង្ខាំងមនុស្សដោយខុសច្បាប់ និងការចាប់ជំរិតជាហេតុចាំបាច់ដែលត្រូវធ្វើឱ្យមានបទប្បញ្ញត្តិច្បាស់លាស់ជាងនេះ។

## ការចុះបញ្ជី និងការពិនិត្យតាមដានលើមណ្ឌលថែទាំ

- គោលការណ៍ណែនាំសម្រាប់ការចុះបញ្ជី៖ គោលការណ៍ណែនាំសម្រាប់ការបើកមូលដ្ឋានមណ្ឌលថែទាំ គឺនៅពុំទាន់បានកំណត់ច្បាស់លាស់នៅឡើយ។ អង្គការជាច្រើនបានចុះបញ្ជីពុំទាន់ត្រឹមត្រូវ ហេតុដូច្នេះធ្វើឱ្យនៅពុំទាន់មានការពិនិត្យតាមដានសមស្រប។ ការចុះបញ្ជីអាចកើតមាននៅតាមក្រសួងផ្សេងៗ ប៉ុន្តែនៅពុំទាន់មានការតម្រូវផ្នែកច្បាប់ឱ្យចុះបញ្ជីជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅឡើយ។
- កង្វះនីតិវិធីបទដ្ឋាន៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានបទដ្ឋានអប្បបរមាសម្រាប់ការឆ្លើយតបចំពោះពាក្យបណ្ដឹងអំពីការរំលោភបំពាន និងការមិនអើពើនៅមណ្ឌលថែទាំ ប៉ុន្តែបទដ្ឋានទាំងនេះនៅមានភាពទន់ខ្សោយ ហើយទាមទារឱ្យមានការពង្រឹងបន្ថែមទៀត ដើម្បីធានាឱ្យបានថាការឆ្លើយតបចំពោះបញ្ហានេះពុំមែនធ្វើឡើងក្នុងលក្ខណៈចំពោះកិច្ច ឬទៅតាមករណីនីមួយៗនោះទេ។

## មិនមានសង្គតិភាពក្នុងភាពជាអាណាព្យាបាល

- ក្រមរដ្ឋប្បវេណី និងបទដ្ឋានអប្បបរមា៖ នៅពុំទាន់មានសង្គតិភាពរវាងក្រមរដ្ឋប្បវេណី និងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួស។ ក្រមរដ្ឋប្បវេណី (មាត្រា ១០១៣) តម្រូវឱ្យមានការអនុញ្ញាតពីតុលាការសម្រាប់សុំកូនក្រោយរយៈពេលស្ថិតក្នុងការថែទាំអប្បបរមា ៦ខែ ចំណែកប្រកាសស្ដីពីនីតិវិធីដើម្បីអនុវត្តការថែទាំដោយសាច់ញាតិ និងការថែទាំដោយគ្រួសារធម៌ (២០២១) អនុញ្ញាតឱ្យ គ.ក.ន.ក អាចកំណត់អត្តសញ្ញាណ និងជ្រើសរើសអ្នកថែទាំជាសាច់ញាតិ និងជាឳពុកម្ដាយធម៌បាន។[44] ហេតុដូច្នេះ គ.ក.ន.ក អាចសម្រេចចិត្តថាតើកុមារអាចទៅរស់នៅទីណា ហើយសុំកូន គឺជាលទ្ធផលកើតចេញពីដំណើរការនោះ។

### អនុសាសន៍៖

→អនុស្សរណៈយោគយល់គ្នារវាងក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបញ្ជាក់ឱ្យមានភាពច្បាស់លាស់ និងសុខដុមនីយកម្ម ក្របខណ្ឌការងារផ្នែកច្បាប់ដែលអភិបាលលើនីតិវិធីការពារកុមារគ្រោះអាសន្នក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ។ ក្នុងនោះ គួររួមមានការកំណត់ឱ្យច្បាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ន.ក ក្រសួងកិច្ចការនារី និងនគរបាលយុត្តិធម៌ ព្រមទាំងបង្កើតឱ្យមាននីតិវិធីឯកភាពគ្នាដើម្បីកំណត់អាណាព្យាបាលភាពផ្នែកច្បាប់បណ្ដោះអាសន្នមុនពេលអន្តរាគមន៍របស់តុលាការ។

→ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបង្កើតឱ្យមានសៀវភៅជំនួយស្មារតីផ្នែកតុលាការស្ដីពីសុំកូនសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាផ្អែកលើ *ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ៖ សៀវភៅណែនាំការអនុវត្តសម្រាប់សុំកូន* ដែលផ្ដល់ការចង្អុលបង្ហាញស្ដីពីការយកច្បាប់នេះទៅអនុវត្តក្នុងនោះរួមមាន៖

[44] Article 14.1.

- ការចែងថា ច្បាប់ស្មុំកូន គឺត្រូវយកទៅអនុវត្តសម្រាប់នីតិវិធីចំពោះតែរដ្ឋកម្ពុជាប៉ុណ្ណោះ ពោលគឺពុំមែនសម្រាប់ពលរដ្ឋបរទេសនៅក្នុងប្រទេសកម្ពុជា ឬពលរដ្ឋនៅបរទេសដទៃទៀតដែលមានបំណងស្មុំកុមារកម្ពុជានោះទេ (អ្នកទាំងនោះ គួរយោងទៅលើច្បាប់ស្មុំកូនអន្តរប្រទេស)។
- តួនាទីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅក្នុងគ្រប់ករណីស្មុំកូនទាំងអស់។ ចាំបាច់ត្រូវមានការចង្អុលបង្ហាញពីក្រសួងមហាផ្ទៃ ជូនទៅចៅក្រមទាំងអស់ ដោយផ្តល់យោបល់ថាការសម្រេចចិត្តនានាអំពីស្មុំកូន គឺពុំអាចធ្វើឡើងដោយមានវត្តមានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងឯកសាររបស់បុគ្គលិកសង្គមកិច្ចវិជ្ជាជីវៈនោះឡើយ។
- បញ្ជីត្រួតពិនិត្យការអនុវត្តសម្រាប់គ្រប់ដំណាក់កាលទាំងអស់នៃដំណើរការទាំងមូល។
- ការតម្រូវឱ្យប្រមូលទិន្នន័យ និងផ្សព្វផ្សាយទិន្នន័យ។
- ការបង្កើតឱ្យមានប្រព័ន្ធ ដើម្បីឱ្យឪពុកម្តាយចិញ្ចឹមដែលមានសក្តានុពល អាចចុះឈ្មោះការដាក់ពាក្យសុំស្មុំកូនរបស់ខ្លួន។

→អភិវឌ្ឍកញ្ចប់ព័ត៌មានសហគមន៍សម្រាប់មណ្ឌលថែទាំដែលពន្យល់យ៉ាងច្បាស់លាស់អំពីដំណើរការនៃស្មុំកូនក្នុងប្រទេស។

→ក្រសួងយុត្តិធម៌ គួរជម្រាបប្រាប់ទៅចៅក្រម ហើយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) គួរជម្រាបប្រាប់ទៅមេធាវីអំពីនីតិវិធីស្មុំកូនរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីធ្វើឱ្យក្រមរដ្ឋប្បវេណីមានសង្គតិភាពជាមួយនីតិវិធីស្មុំកូន និងនីតិវិធីការពារកុមារដទៃទៀតដែលបានធ្វើបច្ចុប្បន្នភាព។

### ***ស្មុំកូនអន្តរប្រទេស***

ក្របខណ្ឌការងារផ្នែកច្បាប់សម្រាប់ស្មុំកូនអន្តរប្រទេស ជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទីមួយ គឺដូចបានបញ្ជាក់ខាងលើហើយថា នៅពុំទាន់មានភាពច្បាស់លាស់ថាតើបទប្បញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីស្តីពីការស្មុំកូនអាចយកទៅអនុវត្តចំពោះស្មុំកូនដែលជាកុមារកម្ពុជាដោយជនបរទេសដែលស្នាក់នៅជាបណ្តោះអាសន្ន ឬជាប្រចាំក្នុងប្រទេសកម្ពុជាបានឬទេ ឬថាតើច្បាប់ស្មុំកូនអន្តរប្រទេសគួរយកទៅអនុវត្តចំពោះពួកគេដែរ។ ស្របពេលជាមួយគ្នានោះដែរ បទប្បញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីសម្រាប់ស្មុំកូនក្នុងប្រទេស គឺនៅត្រូវបានប្រើប្រាស់សម្រាប់ស្មុំកូនដោយពលរដ្ឋបរទេសដែលមានលំនៅក្នុងប្រទេសកម្ពុជា ហើយជាលទ្ធផលបានបង្កើតឱ្យមានចន្លោះប្រហោងជុំវិញការហាមឃាត់ស្មុំកូនអន្តរប្រទេស។ ចំណុចនេះ បង្កើតឱ្យមានផលប៉ះពាល់គួរជាទីកត់សម្គាល់៖ នៅពេលដែលជនបរទេសរស់នៅក្នុងប្រទេសកម្ពុជាដែលបានស្មុំកុមារកម្ពុជាទៅចិញ្ចឹមតាមវិធីនេះបានបញ្ចប់បេសកកម្មរបស់ខ្លួនក្នុងប្រទេសកម្ពុជាហើយ ពួកគេជាច្រើនមិនអាចនាំកូនចិញ្ចឹមរបស់ខ្លួនទៅជាមួយ ដោយសារតែមានភាពស្មុគស្មាញផ្នែកទិដ្ឋាការ។ ជាលទ្ធផលធ្វើឱ្យប្រទេសកំណើតរបស់ពួកគេតម្រូវឱ្យពួកគេត្រូវផ្តួចផ្តើមដំណើរការស្មុំកូនអន្តរប្រទេសដូចមានចែងនៅក្រោមច្បាប់ អនុសញ្ញាទីក្រុងឡាអេស្តីពីការស្មុំកូនអន្តរប្រទេសដែលបានផ្អាកនៅក្នុងប្រទេសកម្ពុជា ជាហេតុធ្វើឱ្យពួកគេទៅណាក៏ពុំរួច។ ដោយហេតុដូច្នេះ ជាការចាំបាច់ណាស់ដែលបុគ្គលិករបស់តុលាការ មេធាវី និងជាពិសេសចៅក្រម សូមកុំបន្តមានសវនា

ការស្តាប់សំណុំរឿងទាំងអស់នេះ។ **ករណីដែលជាប់ពាក់ព័ន្ធជាមួយពលរដ្ឋបរទេស រួមទាំងអ្នកដែលតាំងលំនៅក្នុងប្រទេសកម្ពុជា គឺគួរបញ្ជូនឱ្យស្ថិតនៅក្រោមច្បាប់អនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេស។**

ការសិក្សាបានបង្ហាញពីកង្វះនៃភាពច្បាស់លាស់របស់អ្នកចូលរួមក្នុងការសិក្សានេះ អំពីស្ថានភាពការសុំកូនអន្តរប្រទេសនៅកម្ពុជា។ ក្នុងអំឡុងពេលសម្ភាសន៍សម្រាប់ការសិក្សានេះ មានមន្ត្រីរដ្ឋាភិបាលជាច្រើនរូបបានជឿ និងលើកឡើងថា កម្មវិធីសុំកូនអន្តរប្រទេសនៅតែត្រូវបានផ្អាកជាផ្លូវការ។ ប៉ុន្តែ ការឆ្លើយឆ្លងអន្តរក្រសួងបានបង្ហាញថា នៅខែកុម្ភៈ ឆ្នាំ២០២០ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានស្នើសុំការអនុញ្ញាតពីឯកឧត្តមឧបនាយករដ្ឋមន្ត្រីក្នុងការបើកឱ្យដំណើរការឡើងវិញនូវការសុំកូនអន្តរប្រទេស ជាពិសេសផ្តោតគោលដៅលើកុមារដែលមានពិការភាព កុមារដែលមានតម្រូវការពិសេស និងកុមារមកពីស្ថានភាពងាយរងគ្រោះ។[45] ជាការឆ្លើយតប ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានផ្តល់នូវការអនុម័តដោយមានលក្ខខណ្ឌក្នុងការចាប់ផ្តើមឡើងវិញនូវកម្មវិធីសុំកូនអន្តរប្រទេស ដែលមាននៅក្នុងការអនុវត្តរបស់ខ្លួន ដែលស្របនឹងគោលការណ៍ និងការការពារសុវត្ថិភាពដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងឡាអេស្តីពីការសុំកូនអន្តរប្រទេស។[46] ការអនុញ្ញាតនេះបានផ្តល់សញ្ញាជាការអនុម័តឱ្យមានការសុំកូនអន្តរប្រទេសឡើងវិញ តែក្នុងលក្ខខណ្ឌដែលលទ្ធភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងការធានាឱ្យបានថាដំណើរការនេះអនុលោមបានយ៉ាងខ្ជាប់ខ្ជួនតាមបទដ្ឋានអន្តរជាតិ និងចាត់អាទិភាពទៅលើឧត្តមប្រយោជន៍របស់កុមារ។

នៅក្នុងឆ្នាំ២០២៤ លិខិតដែលបានរៀបចំសរសេរដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[47] ដើម្បីឆ្លើយតបទៅនឹងការតម្រូវទាមទារពីអាជ្ញាធរកណ្តាលរបស់ប្រទេសអេស្ប៉ាញ ក្រសួងបានទទួលស្គាល់ថា *«កម្ពុជា ពុំទាន់ [បាន] សម្រេចទៅដល់កម្រិតដែលត្រៀមខ្លួនរួចរាល់ក្នុងការចាប់ផ្តើមអនុវត្តការងារសុំកូនអន្តរប្រទេសឡើងវិញបានប្រកបដោយសុវត្ថិភាព និងក្រមសីលធម៌នៅឡើយទេ។»* លិខិតនេះក៏បានកំណត់រកនូវក្តីបារម្ភសំខាន់ៗមួយចំនួន រួមទាំងកង្វះប្រព័ន្ធការពារកុមារដ៏រឹងមាំមួយ យន្តការត្រួតពិនិត្យតាមដានការអនុវត្ត និងយន្តការអនុវត្តដែលមិនមានលក្ខណៈពេញលេញ ព្រមទាំងភាពមានកម្រិតនៃសមត្ថភាពក្នុងការធានាថាឧត្តមប្រយោជន៍របស់កុមារត្រូវបានអនុលោមតាមយ៉ាងខ្ជាប់ខ្ជួន។ ក៏មានការផ្តល់យោបល់បន្ថែមទៀតផងដែរថា *«ការបើកឡើងវិញឱ្យមានការសុំកូនអន្តរប្រទេស នឹងត្រូវបានពិចារណា ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថា លក្ខខណ្ឌសំខាន់ៗចាំបាច់សម្រាប់កិច្ចការងារនេះ គឺមានរៀបចំឡើងរួចជាស្រេចក្នុងការធានាឱ្យមានសុវត្ថិភាព ការគោរពសិទ្ធិ និងមានសុខុមាលភាពរបស់កុមារ ប៉ុណ្ណោះ។»*

សកម្មភាពជាច្រើនដែលត្រូវបានបន្តអនុវត្ត បានបង្ហាញថា ការត្រៀមខ្លួនគឺកំពុងតែធ្វើហើយ ដើម្បីបើកឡើងវិញនូវការសុំកូនអន្តរជាតិ នៅក្នុងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ សកម្មភាពទាំងនេះរួមមានទាំងការធ្វើសេចក្តីព្រាងអនុស្សារណៈយោគយល់គ្នាសម្រាប់សុំកូនអន្តរប្រទេស ដែលមួយគឺជាមួយប្រទេសអ៊ីតាលី និងមួយទៀតគឺត្រូវបានរាយការណ៍ថាកំពុងតែធ្វើជាមួយខាងម៉ាល់តា (Malta) ក៏ដូចជាការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារសុំកូនបរទេស។ គួរជាទីកត់សម្គាល់ មានទីភ្នាក់ងារអ៊ីតាលីចំនួនបីដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណ

[45] Letter dated 18 February 2020 from MoSVY to the Deputy Prime Minister
[46] Letter dated 20 February 2020 from the Deputy Prime Minister to MoSVY
[47] Letter dated 14 June 2024 from MoSVY to the Central Authority of the Kingdom of Spain

ជូនរួចរាល់ហើយ ក្នុងការអនុវត្តការសុំកូនអន្តរប្រទេស។ អាជ្ញាធរកម្ពុជាក៏បានទទួលពាក្យស្នើសុំពីឪពុកម្តាយចិញ្ចឹមដែលមានសក្តានុពល ហើយយ៉ាងហោចណាស់មានពាក្យស្នើសុំមួយដែលកំពុងតែស្ថិតនៅក្នុងដំណើរការដែលប្រតិបត្តិដោយអាជ្ញាធរសុំកូនអន្តរប្រទេសនាពេលបច្ចុប្បន្ន។ អ្នកចូលរួមផ្តល់ព័ត៌មាននៃការសិក្សានេះបានចង្អុលបង្ហាញថា ការប៉ាន់ប្រមាណគឺកំពុងតែធ្វើ ដើម្បីកំណត់នូវភាពមានលក្ខណៈគ្រប់គ្រាន់សម្រាប់ធ្វើការសុំកូនអន្តរប្រទេសចំពោះកុមារយ៉ាងហោចណាស់ចំនួនប្រាំមួយនាក់។ ការអភិវឌ្ឍនទាំងនេះបានបណ្តាលទីភ្នាក់ងារដែលមានអាជ្ញាប័ណ្ណសន្និដ្ឋានថា ការសុំកូនអន្តរប្រទេសត្រូវបានដាក់ឱ្យមានប្រតិបត្តិការហើយនៅក្នុងការអនុវត្តជាក់ស្តែងនៅកម្ពុជា។

គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ(២០២២) បានបន្ទរពីក្តីបារម្ភស្រដៀងគ្នានេះដែរ ជាពិសេសពាក់ព័ន្ធនឹងចំនួនដ៏គួរឱ្យកត់សម្គាល់នៃការសុំកូនអន្តរជាតិដែលមិនស្របច្បាប់ ដែលកើតមាននៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ២០០០ និងកង្វះនៃការកែប្រែកំហុសឆ្គងឱ្យបានគ្រប់គ្រាន់។ គណៈកម្មាធិការបានជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាៈ

- *ស៊ើបអង្កេត និងជំរុំជម្រះបុគ្គលទាំងឡាយណាដែលជាប់ពាក់ព័ន្ធក្នុងសុំកូនខុសច្បាប់ និងការជួញដូរកុមារជាការសុំកូន។*
- *ធានាឱ្យបានថា កុមារទាំងអស់ដែលបានសុំកាលរួចហើយ ទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីស្គាល់ដើមកំណើតរបស់ខ្លួន។*
- *លើកកម្ពស់ការសុំកូនក្នុងប្រទេស តាមរយៈកម្មវិធីលើកកម្ពស់ការយល់ដឹង។*
- *អភិវឌ្ឍប្រព័ន្ធរក្សាទិន្នន័យថ្នាក់ជាតិមួយអំពីកុមារដែលមានលក្ខណសម្បត្តិសម្រាប់សុំបាន ព្រមទាំងគ្រួសារដែលបានប្រកាសថាមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូន និង*
- *បណ្តុះបណ្តាលអ្នកប្រកបវិជ្ជាជីវៈ ដើម្បីធានាឱ្យមានដំណើរការសុំកូនដែលប្រកបដោយតម្លាភាព ទាន់ពេលវេលា និងមានក្រមសីលធម៌។*[48]

ដើម្បីឆ្លើយតបចំពោះបញ្ហានេះ ប្រទេសកម្ពុជាចាំបាច់ត្រូវ**ពង្រឹងក្របខណ្ឌការងារផ្នែកច្បាប់** (ក្រមព្រហ្មទណ្ឌ និងច្បាប់សុំកូនអន្តរប្រទេស) **ដើម្បីដាក់ឱ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌតឹងរ៉ឹងជាងមុនសម្រាប់បទល្មើសពាក់ព័ន្ធជាមួយសុំកូន** រួមទាំងការទទួលបានហិរញ្ញវត្ថុមិនសមស្របផងដែរ។ អនុលោមតាមអនុសាសន៍របស់គណៈកម្មាធិការ ប្រទេសកម្ពុជានៅតែត្រូវការកែលម្អតម្លាភាព និងប្រសិទ្ធផលនៅក្នុងដំណើរការសុំកូនតាមរយៈការបង្កើត និងរក្សាឱ្យមានកំណត់ត្រាស្តីពីសុំកូនឱ្យបានសុក្រឹត រួមទាំងព័ត៌មានលម្អិតអំពីឪពុកម្តាយបង្កើតចំពោះគ្រប់ករណីដែលមាន ហើយត្រូវធានាឱ្យបានថារាល់កុមារសុំទាំងអស់ គឺមានលទ្ធភាពអាចចូលទៅរកព័ត៌មានស្តីពីកំណើតរបស់ខ្លួន។

ការសិក្សានេះគូសបញ្ជាក់ពីតម្រូវការឱ្យរដ្ឋាភិបាលកម្ពុជាពង្រឹង និងចាត់អាទិភាពទៅលើការសុំកូន**ក្នុងប្រទេស** ដើម្បីធានាឱ្យបានថាកុមារទាំងអស់មានសុវត្ថិភាព និងបានទទួលផ្ទះអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា។

[48] United Nations Committee on the Rights of the Child (UNCRC). (2022) Concluding observations on the combined fourth to sixth periodic reports of Cambodia. United Nations, 17.

ការលើកទឹកចិត្តការថែទាំដោយគ្រួសារធម៌ និងសុំកូនក្នុងប្រទេស គឺជាគន្លឹះដ៏ចម្បងដើម្បីកាត់បន្ថយតម្រូវការសុំកូនអន្តរប្រទេស និងសកម្មភាពខុសច្បាប់ដែលពាក់ព័ន្ធជាសក្តានុពល។ ការលើកកម្ពស់ការសុំកូនក្នុងប្រទេសតាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹង ការធ្វើបមាណីកម្មដំណើរការ និងការដាក់ប្រព័ន្ធរក្សាទិន្នន័យសុំកូននៅថ្នាក់កណ្ដាលរួម អាចជួយផ្តល់ការទុកដាក់អចិន្ត្រៃយ៍សម្រាប់កុមារកំពុងមានតម្រូវការនៃការថែទាំពីឪពុកម្ដាយដោយពុំចាំបាច់ងាកទៅប្រើការសុំកូនអន្តរប្រទេស ដែលជាការនាំមកវិញនូវហានិភ័យកាន់តែខ្ពស់ក្នុងការធ្វើសកម្មភាពខុសច្បាប់។

ការសុំកូនអន្តរប្រទេសបានថយចុះនៅទូទាំងសាកលលោកក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែមានអំពើពុករលួយក្នុងទម្រង់ប្រហាក់ប្រហែលនេះ បានកើតមានច្រំដែលៗនៅទូទាំងពិភពលោក ថ្វីបើមានសន្ធិសញ្ញាអន្តរជាតិ និងការផ្អាកជាបណ្ដោះអាសន្ន ដែលបានតាក់តែងឡើងដើម្បីបង្ក្រាបការជួញដូរក្នុងការសុំកូនក្តី។[49] បណ្ដាប្រទេសផ្សេងៗដែលមានប្រវត្តិសាស្ត្រដ៏យូរមកហើយបនៃការសុំកូនអន្តរប្រទេស ដូចជាប្រទេសចិនជាដើម ថ្មីៗនេះបានបិទកម្មវិធីសុំកូនអន្តរប្រទេសរបស់ខ្លួន ដើម្បី «អនុលោមតាម» បទដ្ឋានអន្តរជាតិឱ្យបានខ្ជាប់ខ្ជួន។[50] ប្រទេសកូរ៉េខាងត្បូងទើបតែបានចេញផ្សាយរបាយការណ៍របស់គណៈកម្មាធិការសច្ចភាព និងការផ្សះផ្សា (Truth and Reconciliation Commission) ដែលមានគំហើញស្តីអំពីការរំលោភបំពានដ៏សាយភាយនៅក្នុងការសុំកូនអន្តរប្រទេស។[51] សូម្បីតែប្រទេសទាំងពីរ ដែលកម្មវិធីសុំកូនអន្តរប្រទេសរបស់ពួកគេត្រូវបានលើកស្ទួយថាមានបទដ្ឋានខ្ពស់ខ្លាំង ក៏នៅតែបានឈានមកសេចក្ដីសន្និដ្ឋានថា ការប្រតិបត្តិខុសច្បាប់ គឺពុំអាចបញ្ចៀសបាន ហើយបង្កផលប៉ះពាល់ដល់សិទ្ធិកុមារ (និងសិទ្ធិមនុស្សពេញវ័យដែលបានធំចេញពីកុមារទាំងនោះ)។ បន្ថែមលើនេះ ប្រទេសទទួល ដូចជាប្រទេសប៊ែលហ្ស៊ិក ហូឡង់ ប្រទេសស្វ៊ីសជាដើម បានដាក់ការផ្អាកជាបណ្ដោះអាសន្នស្តីពី ការសុំកូនអន្តរប្រទេស ដោយសារតែមិនមានសមត្ថភាពលុបបំបាត់ការប្រតិបត្តិខុសច្បាប់។[52]

ការផ្អាកជាបណ្ដោះអាសន្នទាំងនេះ ភាគច្រើនគឺបណ្ដាលមកពីកិច្ចខិតខំយ៉ាងសកម្មរបស់កូនចិញ្ចឹមដែលក្លាយជាមនុស្សពេញវ័យហើយ ព្យាយាមជំរុញរដ្ឋាភិបាលឱ្យទទួលស្គាល់នូវការរំលោភបំពានជាប្រព័ន្ធដែលមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅមកលើសិទ្ធិ និងសុខុមាលភាពរបស់ពួកគេពេញមួយជីវិត។ ការរំលោភបំពានទាំងនេះ គឺបានស្តែងចេញយ៉ាងច្បាស់ថា**សុំកូនអន្តរប្រទេសពុំអាចជានានូវឧត្តមប្រយោជន៍របស់កុមារបានទេ។**[53] បណ្ដាប្រទេសបញ្ជូន និងទទួលដទៃទៀត ក៏បានអនុវត្តការស៊ើបអង្កេតប្រហាក់ប្រហែលគ្នានេះដែរ ហើយក៏ទំនងជានឹងឈានទៅអនុវត្តសកម្មភាពស្រដៀងៗគ្នានេះដែរ។[54]

---

[49] Wittner KM. (2003) Curbing Child-Trafficking in Intercountry Adoptions: Will International Treaties and Adoption Moratoriums Accomplish the Job in Cambodia? *Pacific Rim Law & Policy Journal* 12(2): 595-630.
Cheney KE. (2023) Why The Hague Convention Is Not Enough: Addressing Enabling Environments for Criminality in Intercountry Adoption. In: Nelen H and Siegel D (eds) *Organized Crime in the 21st Century.* Cham, Switzerland: Springer Nature, 191-206.
[50] https://www.reuters.com/world/china/china-stops-foreign-adoptions-its-children-after-three-decades-2024-09-06/
[51] https://apnews.com/article/south-korea-adoptions-responsibility-fraud-abuse-67970ea6e153e7cbb63d5b4bc29325f4
[52] https://www.swissinfo.ch/eng/foreign-affairs/why-countries-are-banning-international-adoptions/88858045
[53] Committee Investigating Intercountry Adoption. (2021) Committee on the Investigation of Intercountry Adoption Report [‘Joustra Report’, unofficial translation]. The Hague: Ministry of Justice and Security, 29.
[54] Child Identity Protection. (2025) Advocacy note: Need to reinforce efforts to respond to systemic illicit intercountry adoption practices. Child Identity Protection. https://www.child-identity.org/wp-content/uploads/2025/02/Advocacy-note-ICAs-final-10-Feb-2025.pdf

បន្ថែមលើនេះទៀត ថ្វីបើមានការបោះជំហានយ៉ាងធំធេងនៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការដោះស្រាយភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធសុំកូនអន្តរប្រទេសក្តី ប៉ុន្តែអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា គឺលោក Vitit Muntarbhorn ថ្មីៗនេះបានបង្ហាញនូវក្តីកង្វល់ជាបន្តអំពីការបើកការសុំកូនអន្តរប្រទេសឡើងវិញ។[55] ការស្រាវជ្រាវបានបង្ហាញពីកង្វល់ថា ប្រសិនប្រទេសកម្ពុជាចាប់ផ្តើមកម្មវិធីសុំកូនអន្តរប្រទេសជាថ្មីឡើងវិញនៅពេលនេះ រាជរដ្ឋាភិបាលអាចបាត់បង់យ៉ាងហោចណាស់នូវវឌ្ឍនភាពទាំងអស់ដែលសម្រេចបានក្នុងការការពារកុមារពីការរំលោភបំពានពាក់ព័ន្ធនឹងសុំកូន។ ដើម្បីបន្តអនុលោមតាមបទដ្ឋានអន្តរជាតិ និងបន្សុីជាមួយគោលជំហរថ្នាក់តំបន់ រដ្ឋាភិបាលគួរពិចារណាជាអាទិភាពក្នុងការពង្រឹង និងវិនិយោគទៅក្នុងកម្មវិធីក្នុងប្រទេសរបស់ខ្លួន ហើយធានាឱ្យបានថា កុមារទាំងអស់បានទទួលគ្រួសារប្រកបដោយសុវត្ថិភាព និងអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលរាជរដ្ឋាភិបាលអាចធ្វើការក្នុងពេលដំណាលគ្នា និងប្រកបដោយវឌ្ឍនភាពឆ្ពោះទៅការធ្វើអន្តរកាលចាកចេញពីសកម្មភាពសុំកូនអន្តរប្រទេស ដោយអនុលោមតាមនិន្នាការសកល និងនិន្នាការតំបន់។

អ្នកផ្តល់ចម្លើយក្នុងការសិក្សានៅតែមានក្តីកង្វល់ថា **សេចក្តីព្រាងអនុសារណៈយោគយល់គ្នា ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារ ការទទួលយកពាក្យសុំពីឪពុកម្តាយចិញ្ចឹមដែលមានសក្តានុពល និងការកំណត់លក្ខណសម្បត្តិអាចចូលរួមក្នុងការសុំកូនអន្តរប្រទេសសម្រាប់កុមារជាបុគ្គលរូបវន្ត** អាចបង្កើត និងលើកទឹកចិត្តឱ្យមានប្រព័ន្ធថ្មីមួយ ដែលធ្វើឱ្យការសុំកូនអន្តរប្រទេសកើតមានជាប្រក្រតី និងមានសក្តានុពលបង្កើនការសុំកូនអន្តរប្រទេស នៅក្នុងពេលវេលាមួយដែលនៅតែបន្តមានភាពចន្លោះប្រហោងផ្នែកច្បាប់គួរជាទីកត់សម្គាល់ ដូចបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីមួយឆ្នាំមុន ក៏ដូចជាការប្រតិបត្តិប្រកបដោយបញ្ហាមានភស្តុតាងជាឯកសារជាក់លាក់ដែលបានកំណត់ឃើញ ទាំងនៅក្នុងការសុំកូនក្នុងប្រទេស និងក្នុងការសុំកូនអន្តរប្រទេស។

ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការសុំកូនអន្តរប្រទេសឆ្នាំ២០០៩ ដើម្បីឱ្យមានភាពអនុលោមតាមលិខិតបទដ្ឋានគតិយុត្តថ្មីៗស្តីពីសុំកូន។ មកដល់ត្រឹមនេះ ពួកយើងសូមផ្តល់អនុសាសន៍ថា ជាការសមគួរ និងទាន់ពេលវេលាក្នុងការចាប់ផ្តើមការពិនិត្យឡើងវិញជាថ្មីម្តងទៀតដើម្បីកំណត់ថាតើចាំបាច់ ឬទេក្នុងការបើកដំណើរការកម្មវិធីសុំកូនអន្តរប្រទេសឡើងវិញ ដើម្បីធានាឱ្យមានការទុកដាក់អចិន្ត្រៃយ៍សម្រាប់កុមារកម្ពុជា ថាតើមធ្យោបាយនេះ អាចជួយធានាឧត្តមប្រយោជន៍របស់កុមារដែលត្រូវបានសុំទៅចិញ្ចឹមឬទេ និងថាតើការអនុវត្តនេះអនុលោមតាមបទដ្ឋានអន្តរជាតិនាពេលបច្ចុប្បន្នឬទេ។

## អនុសាសន៍៖

→តាមរយៈសេចក្តីថ្លែងការណ៍ផ្លូវការ បកស្រាយបញ្ជាក់ពីស្ថានភាពសុំកូនអន្តរប្រទេសបច្ចុប្បន្ន និងកាលៈទេសៈដែលអនុញ្ញាតឱ្យមានការសុំកូន។

55 Special Rapporteur on the situation of human rights in Cambodia. (2024) Report of the Special Rapporteur on the situation of human rights in Cambodia. Geneva: UNHRC, 26.

→បកស្រាយបញ្ជាក់ថាក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តតែចំពោះពលរដ្ឋកម្ពុជា ដែលមានបំណងសុំកូនប៉ុណ្ណោះ។ ជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ហើយមានបំណងសុំកុមារកម្ពុជាទៅចិញ្ចឹម ចាំបាច់ត្រូវយោងទៅលើច្បាប់ស្ដីពីការសុំកូនអន្តរប្រទេស។

→កិច្ចខិតខំរដ្ឋបាលដោយផ្ទាល់ឆ្ពោះទៅបង្កើតឱ្យមានការអនុវត្តភាពអនុលោមតាមច្បាប់ ដែលប្រកបដោយគុណភាពខ្ពស់សម្រាប់ការថែទាំដោយគ្រួសារចិញ្ចឹម និងសុំកូនក្នុងប្រទេសជំនួសឱ្យការបង្កើត អនុស្សរណៈយោគយល់គ្នា គោលនយោបាយ និងនីតិវិធីដែលនឹងលើកទឹកចិត្តឱ្យសុំកូនអន្តរប្រទេស បើទោះបីជាការលើកទឹកចិត្តទាំងនោះធ្វើឡើងដោយអចេតនាក្តី។

## ការរក្សាកំណត់ត្រា និងការគ្រប់គ្រងករណី

ការងារសុំកូនប្រកបដោយប្រសិទ្ធភាព និងសីលធម៌ ទាមទារឱ្យមានការរក្សាកំណត់ត្រាឱ្យបានខ្ជាប់ខ្ជួន និងសង្គតិភាព។ ឯកសារទាំងនោះ គឺរួមមានទាំងកំណត់ត្រាទាំងអស់ដូចជាអន្តរទំនាក់ទំនងផ្នែកអាកប្បកិរិយារវាងអ្នកសង្គមកិច្ចជាមួយកុមារ/គ្រួសារ ក៏ដូចជាបមាណីកម្មទម្រង់ផ្សេងៗ ដូចជាទម្រង់សម្រាប់ការគ្រប់គ្រងករណីនៅពេលទទួលកុមារចូល និងការប៉ាន់ប្រមាណជាដើម។ កំណត់ត្រសំខាន់ៗដទៃទៀត រួមមានដូចជាខ្លឹមសារសង្ខេបអំពីប្រវត្តិផ្នែកសង្គមរបស់កុមារ កំណត់ត្រាវេជ្ជសាស្ត្រដែលពាក់ព័ន្ធ ក៏ដូចជាចំណុចដទៃទៀតពាក់ព័ន្ធនឹងគ្រួសារដែលមានសក្តានុពល ក្នុងការយកការសិក្សាអំពីផ្ទះពួកគេមករួមបញ្ចូលផងដែរ ដែលចាំបាច់សម្រាប់គោលបំណងក្នុងការផ្គូផ្គងរវាងគ្រួសារនិងកុមារ។ ឯកសារទាំងនេះ គួរមានតែត្រូវបានធ្វើបមាណីយកម្មសម្រាប់គ្រប់ករណីទាំងអស់ ហើយត្រូវគ្រប់គ្រងក្នុងទម្រង់អេឡិចត្រូនិច ធ្វើយ៉ាងណាឱ្យអាចចូលទៅបើកមើលបាននៅក្នុងប្រព័ន្ធរក្សាទិន្នន័យបាន ហើយជាលទ្ធផលរាល់អ្នកប្រកបវិជ្ជាជីវៈ *ទាំងអស់* ដែលចូលរួមពាក់ព័ន្ធក្នុងករណី គឺអាចសាកសួរទៅក្នុងប្រព័ន្ធតាមការចាំបាច់។ ការពិភាក្សាអំពីការគ្រប់គ្រងករណីនៅផ្នែកខាងក្រោមរៀបរាប់បន្ថែមទៀតអំពីការរក្សាកំណត់ត្រាអេឡិចត្រូនិច។

យើងឃើញថា បច្ចុប្បន្នក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រើប្រាស់ទម្រង់ជាក្រដាសចំនួនជាង ២០ទម្រង់។ ការបន្សីទម្រង់ទាំងអស់នោះឱ្យរួមបញ្ចូលគ្នាដោយរលូន ហើយផ្លាស់ទៅដាក់ឱ្យប្រើប្រាស់នៅក្នុងប្រព័ន្ធអនឡាញនៅក្នុងប្រព័ន្ធរក្សាទិន្នន័យវិញ គឺស្របតាមការប្រតិបត្តិអន្តរជាតិ។ ចំណុចនេះក៏គួរផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS) ដែលទើបបានបង្កើតឡើងនាពេលថ្មីៗនេះផងដែរ ដើម្បីធានាឱ្យមានប្រវត្តិករណីពេញលេញសម្រាប់កុមារជាបុគ្គលម្នាក់ៗ។

## *ការចុះបញ្ជីកំណើត និងការរក្សាអត្តសញ្ញាណ*

ការវិភាគមួយធ្វើឡើងនៅឆ្នាំ២០១៩ អំពីលិខិតបទដ្ឋានគតិយុត្តស្ដីពីកិច្ចការពារកុមារធ្វើឡើងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) បានបង្ហាញឱ្យឃើញថា លិខិតបទដ្ឋានគតិយុត្តកម្ពុជាខ្វះបទបញ្ញត្តិច្បាស់លាស់ដើម្បីធានាឱ្យមានការរក្សាកំណត់ត្រាឱ្យបានសុក្រឹត និងការរក្សាអត្តសញ្ញាណឪពុកម្តាយបង្កើតរបស់កុមារ ជាពិសេសក្នុងករណីសុំកូនក្នុងប្រទេស។[56] ប្រទេសកម្ពុជាបានទទួលសមិទ្ធផលមួយចំនួនក្នុងការ

[56] Cambodia National Council for Children (CNCC). (2019) Report on Gap Analysis of Child Protection Legislation in the Kingdom of Cambodia. Phnom Penh: CNCC, 41.

ការពារអត្តសញ្ញាណកុមារតាមរយៈលិខិតបទដ្ឋានគតិយុត្ត និងវិធានការគោលនយោបាយជាច្រើន។ ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មឆ្នាំ២០២៤ ព្រមទាំងកិច្ចខិតខំជាបន្តដើម្បីកែលម្អការចុះបញ្ជីកំណើត និងប្រព័ន្ធអត្តសញ្ញាណតាមផ្លូវច្បាប់ គឺជាជំហានដ៏វិជ្ជមាន។ ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម មានបំណងដើម្បីធានាឱ្យមានការចុះបញ្ជីអត្តសញ្ញាណស្របច្បាប់ជាសកល និងការចុះបញ្ជីកំណើត និងមរណភាពឱ្យបានពេញលេញសម្រាប់គ្រប់បុគ្គលទាំងអស់ក្នុងប្រទេសកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធវិមជ្ឈការសម្រាប់ការិយាល័យអត្រានុកូលដ្ឋាននៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋមានលទ្ធភាពចូលទៅរកសេវានេះបានកាន់តែប្រសើរ លុបចោលថ្លៃសេវាចុះបញ្ជី ហើយសំខាន់ជាងនេះ គឺការដាក់ឱ្យមានលេខកូដអត្តសញ្ញាណដែលមានតែមួយគត់សម្រាប់បុគ្គលម្នាក់ៗដែលត្រូវចេញឱ្យនៅពេលចុះបញ្ជីកំណើត ហើយលេខកូដសម្រាប់បុគ្គលនីមួយៗនេះនឹងត្រូវយកមកប្រើជាលេខកូដអត្តសញ្ញាណបុគ្គលពេញមួយជីវិត។[57] ការដាក់ឱ្យមានច្បាប់នេះនឹងជួយដល់ការប្រឹងប្រែងដើម្បីដោះស្រាយការប្រតិបត្តិខុសច្បាប់នៃការផ្តល់សំបុត្រកំណើតក្លែងក្លាយដែលអាចជំរុញឱ្យមានការជួញដូរកុមារនៅក្នុងការងារសុំកូន។

ទោះយ៉ាងណាក្តី ដើម្បីអាចបន្ស៊ីជាមួយបទដ្ឋានអន្តរជាតិឱ្យបានពេញលេញ និងដើម្បីធានាឱ្យមានការគ្របដណ្តប់ជាសកលសម្រាប់គ្រប់កុមារទាំងអស់ដែលកើតក្នុងប្រទេសកម្ពុជា (មិនថាឪពុកម្តាយរបស់ពួកគេមានស្ថានភាពយ៉ាងណាក្តី) យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យមានលិខិតបទដ្ឋានគតិយុត្ត និងការផ្លាស់ប្តូរគោលនយោបាយមួយចំនួនថែមទៀត។ លិខិតបទដ្ឋានគតិយុត្តិបច្ចុប្បន្ន ខ្វះនីតិវិធីគ្រប់គ្រាន់ក្នុង**ការការពារអត្តសញ្ញាណរបស់កុមារដែលត្រូវគេបោះបង់ ឬកុមារសុំ** ជាហេតុធ្វើឱ្យពួកគេមានភាពងាយរងគ្រោះចំពោះការរំលោភបំពានផ្សេងៗដូចជាការជួញដូរកុមារ និងការសុំកូនខុសច្បាប់ជាដើម។ ឧទាហរណ៍ មានតែឪពុកម្តាយ សាច់ញាតិ ឬអ្នកជិតខាងដែលជាសាក្សីនៃកំណើតប៉ុណ្ណោះដែលអាចដាក់ពាក្យសុំចុះបញ្ជី។ អ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រឬឆ្មប គឺពុំមានសិទ្ធិសុំចុះបញ្ជីកំណើតនោះទេ ដែលជាការដាក់ដែនកំណត់សម្រាប់ជម្រើសនៃការចុះបញ្ជី ប្រសិនពុំមានវត្តមានបុគ្គលដែលមានសិទ្ធិ។ ចំណុចនេះបានជួយសម្រួលឱ្យមានការប្រតិបត្តិខុសច្បាប់មួយចំនួនទាក់ទងនឹងសុំកូនក្នុងស្រុកនៅតាមមន្ទីរពេទ្យមួយចំនួនដូចបានបញ្ជាក់ខាងដើម។

### ***ការគ្រប់គ្រងករណីការងារសង្គម***

ការសិក្សារបស់យើងបានបង្ហាញថា មានចំណុចខ្វះចន្លោះមួយចំនួនទាក់ទងនឹងការគ្រប់គ្រងករណីសម្រាប់កុមារប្រឈមហានិភ័យនៃការបំបែកចេញពីគ្រួសារ ឬកុមារមានតម្រូវការការថែទាំពីឪពុកម្តាយ។ បញ្ហានេះកើតមានដោយសារ**មានការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីផ្សេងគ្នា** ពីសំណាក់តួអង្គការពារកុមារ ខុសៗគ្នា៖ ដោយក្នុងនោះភាគច្រើនអង្គការមិនមែនរដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណី និងការរក្សាកំណត់ត្រាបែបប្រភពចំហ (OSCaR) ចំណែកកម្មវិធី Primero គឺត្រូវបានប្រើប្រាស់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គាំទ្របច្ចេកទេសដោយយូនីសេហ្វ។[58] ជាការសំខាន់ដែលត្រូវកត់សម្គាល់

[57] https://www.biometricupdate.com/202503/crvs-law-reshapes-governance-and-social-protection-in-cambodia
[58] Primero has been funded by USAID, raising questions about its sustainability in the current funding environment. This funding dilemma should be assessed and considered when deciding which system is most useful and sustainable for the continuum of child permanency planning.

ផងដែរថា ប្រព័ន្ធ Primero គឺជាប្រព័ន្ធគ្រប់គ្រងករណីដែលទើបបង្កើតថ្មី ត្រូវបានប្រើប្រាស់ជាសកលដោយទីភ្នាក់ងារអង្គការសហប្រជាជាតិដទៃទៀត និងអង្គការអន្តរជាតិ ហើយនៅពុំទាន់មានប្រព័ន្ធគ្រប់គ្រងព័ត៌មានសកលដទៃទៀតនៅឡើយ។ម្យ៉ាងទៀតថ្វីបើកម្មវិធីនេះពុំត្រូវបានអភិវឌ្ឍឡើងដោយផ្តោតជាពិសេសសម្រាប់ការងារសង្គមកិច្ចផ្នែកសុំកូនក្តី ប៉ុន្តែកម្មវិធីនេះមានសក្តានុពលអាចយកមកប្រើប្រាស់សម្រាប់ការងារនេះបាន ដោយហេតុថាគេអាចពង្រីកបន្ថែមកម្មវិធីនេះសម្រាប់ការងារសុំកូនបាន។

ទោះយ៉ាងនេះក្តីខាងអង្គការបានលើកឡើងថា OSCaR ងាយស្រួលប្រើប្រាស់ជាង ដោយហេតុថាពួកគេបានរាយការណ៍ថា គេអាចរក្សាកំណត់ត្រាព័ត៌មានលម្អិតនៅទីនោះបាន។ រាជរដ្ឋាភិបាលនិយាយថា Primero មានភាពងាយស្រួលជាង បើទោះបីជារយៈពេលប៉ុន្មានឆ្នាំមុន ពួកគេជួបការលំបាកក្នុងការប្រើប្រាស់ប្រព័ន្ធ Primero ក្តី៖ ប្រព័ន្ធ (ឧបករណ៍ interfacing) គាំង ហើយពួកគាត់ត្រូវបាត់បង់ព័ត៌មាន ជាហេតុធ្វើឱ្យពួកគាត់ងាកទៅកត់ត្រាលើក្រដាសជំនួសវិញ។ បើយើងមើលទៅម្យ៉ាង ការកត់ត្រាលើក្រដាសគឺពុំសូវងាយស្រួលទេ ប៉ុន្តែការកត់ត្រាលើក្រដាសមានលក្ខណៈអំណោយផលសម្រាប់ធ្វើការជាមួយតុលាការ ដោយហេតុថាតុលាការតែងតែប្រើប្រាស់ឯកសារលើក្រដាស ហេតុដូច្នេះហើយ គឺនៅពុំទាន់អាចប្រាប់បញ្ចូលព័ត៌មានឌីជីថលបានទទួលពី Primero ឡើយ។ ទោះយ៉ាងនេះក្តី អង្គការមិនមែនរដ្ឋាភិបាលនិយាយថា រាជរដ្ឋាភិបាលពុំបានកត់ត្រាបានល្អឡើយ ហើយជាលទ្ធផលអាចធ្វើឱ្យការទុកដាក់កុមារដែលកំពុងមានតម្រូវការទៅក្នុងការទុកដាក់អចិន្ត្រៃយ៍មានភាពយឺតយ៉ាវ។ បន្ថែមលើនេះ កម្មវិធី Primero ពុំបានដាក់បញ្ចូលការធ្វើផែនការនិងការទុកដាក់អចិន្ត្រៃយ៍ទេ ហេតុដូច្នេះប្រហែលជានៅពុំទាន់គ្រប់គ្រាន់សម្រាប់ករណីសុំកូននៅឡើយ។ អ្នកចូលរួមក្នុងការសិក្សាបានលើកឡើងថា ប្រព័ន្ធទាំងពីរនេះ*ពុំទាន់*មានប្រព័ន្ធណាដែលដាក់បញ្ចូលឯកសារទាំងអស់ដែលចាំបាច់ដើម្បីបំពេញនីតិវិធីសុំកូនបច្ចុប្បន្នទាំងអស់នៅឡើយ។ ពួកគាត់ក៏បានលើកឡើងផងដែរថា នៅខ្វះខាតការការពារទិន្នន័យ ដោយហេតុថាពេលខ្លះមន្ត្រីផ្ញើឯកសារតាមតេលេក្រាម (ប្រព័ន្ធផ្ញើសារមិនមានសន្តិសុខដែលគេប្រើប្រាស់ជាទូទៅនៅកម្ពុជា)។ ថ្វីបើប្រព័ន្ធទាំងពីរនេះអាចមានអន្តរកម្មផ្ទៃមុខ (interface) ក្តី ប៉ុន្តែមានការរាយការណ៍ថាការបញ្ជូនដោយរាជរដ្ឋាភិបាលទៅកាន់អង្គការ ភាគច្រើនតែងតែធ្វើឡើងក្នុងទម្រង់លើក្រដាស។ ជាលទ្ធផលការប្រើប្រាស់ប្រព័ន្ធទាំងពីរនេះ នៅពុំទាន់បានប្រសើរបំផុតដើម្បីធ្វើការបញ្ជូនករណីប្រកបដោយប្រសិទ្ធផលពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតនៅឡើយ។ មិនថាប្រព័ន្ធណាត្រូវបានប្រើប្រាស់ក្តី គឺចាំបាច់ត្រូវមានភាពសមស្របជាមួយបរិបទក្នុងស្រុក ដោយគិតរួមទាំងសមត្ថភាព និងចំណេះដឹងបច្ចេកទេសរបស់កម្លាំងសេវាសង្គមផងដែរ។

បញ្ហាដែលធំជាងនេះ គឺនៅត្រង់ថា ដំណើរការលំហូរការងារការថែទាំជំនួស ដែលគ្រប់គ្រងលើការងារនេះ**ពុំពិចារណាពីសុំកូន ឬការពិនិត្យតាមដាន ការតាមដានបន្ត ឬការគាំទ្រក្រោយសុំកូននោះឡើយ**។ ដោយហេតុនេះ ជាការប្រសើរគួរពិចារណារកប្រព័ន្ធគ្រប់គ្រងករណីតែមួយដែលអាចបន្សីដំណើរការដោយរលូនចាប់តាំងពីចំណុចនៃអន្តរាគមន៍របស់សេវាសង្គម ចាប់តាំងពីការបំបែកកុមារចេញពីគ្រួសារ និងជាបន្តបន្ទាប់រហូតដល់លំហូរទាំងមូលនៃច្រវាក់នៃការថែទាំគ្រប់ជ្រុងជ្រោយចាប់ពីដើមទីរហូតទៅ (care continuum) ឈានទៅដល់សុំកូន និងការតាមដានបន្តក្រោយសុំកូន។ ពួកយើងសូមផ្តល់អនុសាសន៍ជូនអ្នកពាក់ព័ន្ធទាំងឡាយសូមឱ្យមករួមគ្នា ដើម្បីកំណត់ថាតើមានធាតុផ្សំអ្វីខ្លះដែលចាំបាច់សម្រាប់ការគ្រប់គ្រងករណីសុំកូនដ៏ល្អ

(អនុលោមតាមច្បាប់ គោលនយោបាយ និងនីតិវិធីដែលមានបច្ចុប្បន្ន) និងផ្តល់អនុសាសន៍អំពីថាតើគេអាចប្របាច់បញ្ចូលធាតុផ្សំផ្សេងៗនៃប្រព័ន្ធនានានាពេលបច្ចុប្បន្ននេះ ទៅជាប្រព័ន្ធតែមួយបានល្អបំផុតដោយរបៀបណា ដោយអនុលោមតាមចង្វាក់នៃការថែទាំគ្រប់ជ្រុងជ្រោយពីដើមទីរហូតទៅ (continuum of care)។ ការងារនេះអាចផ្តល់លទ្ធផលធ្វើឱ្យប្របាច់បញ្ចូលប្រព័ន្ធទាំងពីរនេះចូលគ្នាទៅជាប្រព័ន្ធតែមួយ ដែលទាំងអង្គការ និងរាជរដ្ឋាភិបាលអាចយកទៅប្រើប្រាស់ ឬអាចមានន័យថា ជាការបង្កើត ឬទទួលយកមកនូវប្រព័ន្ធផ្សេងមួយទៀតទាំងស្រុងតែម្តង។

**អនុសាសន៍៖**

→ បង្កើតអនុស្សារណៈនៃការយោគយល់គ្នារវាងក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ដើម្បីអនុវត្តនីតិវិធីដែលការពារអត្តសញ្ញាណរបស់កុមារត្រូវគេបោះបង់ ឬកុមារដែលបានសុំ តាមរយៈការជានាឱ្យមានការចុះបញ្ជីកំណើតជាកាតព្វកិច្ច រួមទាំងការចុះបញ្ជីដោយបុគ្គលិកវេជ្ជសាស្ត្រផងដែរ។

→ ធ្វើការសិក្សាស្រាវជ្រាវស៊ីជម្រៅ ដើម្បីកំណត់ថាតើធ្វើយ៉ាងណាដើម្បីបន្សីការគ្រប់គ្រងករណីឱ្យបានប្រសើរបំផុតសម្រាប់ការថែទាំជំនួស និងសុំកូន (មតិយោបល់បឋមមួយចំនួន គឺមាននៅទីនេះ)។

→កំណត់ថាតើមានប្រព័ន្ធគ្រប់គ្រងករណីថ្មី ឬទើបកើតមានដទៃណាមួយដែលត្រូវបានប្រើប្រាស់ដោយក្រសួង ស.អ.យ និង/ឬអង្គភាពការពារកុមារដទៃទៀតនៅទូទាំងសកលលោកឬទេ។

→បន្សីគ្នាចូលទៅក្នុងប្រព័ន្ធតែមួយដែលមានលក្ខណៈប្រសើរបំផុត សម្រាប់ការធ្វើផែនការទុកដាក់អចិន្ត្រៃយ៍។ តាមដានកុមារបន្តនៅក្នុងដំណើរការទាំងមូលតាំងពីដើមដល់ចប់នៃការធ្វើផែនការទុកដាក់អចិន្ត្រៃយ៍ ជាពិសេសនៅពេលមានការពិចារណាយកការសុំកូនមកប្រើប្រាស់ គឺមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តក្នុងការគ្រប់គ្រងករណី ដែលរួមមានជំហានទាំងអស់ដែលត្រូវបានធ្វើឡើងសម្រាប់ការសម្រេចចិត្តទៅលើលក្ខណសម្បត្តិអាចដាក់ឱ្យសុំបាន។

→អភិវឌ្ឍផែនទីបង្ហាញផ្លូវ ដើម្បីភ្ជាប់ផ្នែកផ្សេងៗទាំងអស់របស់ប្រព័ន្ធកិច្ចការពារកុមារ ឱ្យមានទំនាក់ទំនងជាមួយគ្នា ក្នុងនោះគឺរួមមានទាំងការពង្រឹងកម្លាំងសេវាសង្គម ដោយពង្រឹងការបណ្តុះបណ្តាលជាក់លាក់ស្តីអំពីប្រព័ន្ធ Primero, ប្រព័ន្ធ OSCaR, ឬប្រព័ន្ធដែលបានព្រមព្រៀងគ្នាដទៃទៀត។ បន្តកិច្ចសហការរវាងយូនីសេហ្វជាមួយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចបានការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីឱ្យបានពេញលេញបំផុត រួមទាំងការបណ្តុះបណ្តាលនៅទូទាំងប្រទេសកម្ពុជា ដើម្បីលើកទឹកចិត្តឱ្យកម្លាំងសេវាសង្គម អាចប្រើប្រាស់ប្រព័ន្ធយ៉ាងស៊ីសង្វាក់ និងប្រើប្រព័ន្ធតែមួយមុខគត់។

→ប្រព័ន្ធដែលត្រូវបានយកមកប្រើប្រាស់ ចាំបាច់ត្រូវគ្របដណ្តប់លើដំណើរការទាំងមូលនៃច្រវាក់នៃការថែទាំពីដើមទីរហូតទៅ (continuum of care) ដោយក្នុងនោះ សុំកូន គឺជាជម្រើសចុងក្រោយបំផុត ហើយការគាំទ្រក្រោយសុំកូន គឺជាទិដ្ឋភាពមួយនៃការថែទាំនោះ។

## ការកសាងសមត្ថភាព

យើងបានកត់សម្គាល់ឃើញថា ថ្វីបើមានវឌ្ឍនភាពគួរជាទីកត់សម្គាល់នៅក្នុងការថែទាំដោយគ្រួសារចិញ្ចឹម និងសុំកូនក្នុងប្រទេសក្តី ប៉ុន្តែការបំបែកកុមារចេញពីគ្រួសារ គឺអាចទប់ស្កាត់បានយ៉ាងងាយស្រួល ប្រសិនបើមានសេវា និងមានលទ្ធភាពទទួលបានសេវាប្រសើរជាងនេះ ដូចជាសេវាអប់រំ និងវេជ្ជសាស្ត្រ ក៏ដូចជាការគាំទ្រសម្រាប់គ្រួសារកុមារមានពិការភាព។

គួរផ្តល់ការកសាងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋានដូចជាអាជ្ញាធរភូមិនិងឃុំជាដើម ហើយគួរផ្តោតការយកចិត្តទុកដាក់ឱ្យបានច្បាស់ទៅលើតួនាទី និងការទទួលខុសត្រូវរបស់ថ្នាក់មូលដ្ឋាននៅក្នុងដំណើរការបន្តផ្តល់ការថែទាំ។[59] គួរបន្តផ្តល់ការបណ្តុះបណ្តាលសម្រាប់ថ្នាក់មូលដ្ឋានបានជ្រាប និងបានត្រៀមខ្លួនទុកជាមុនក្នុងការគាំទ្រដល់ការងាររបស់អ្នកផ្តល់សេវាសង្គម នៅក្នុងការគ្រប់គ្រងករណីសម្រាប់ការធ្វើផែនការទុកដាក់អចិន្ត្រៃយ៍ ដោយមានការពិចារណាជាពិសេសទៅលើសុំកូនក្នុងប្រទេសជាជម្រើសចុងក្រោយ។ ជាតុទាំងឡាយនៅក្នុងការបណ្តុះបណ្តាលនេះ គួរត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលដែលបានធ្វើបមាណីកម្ម ហើយសម្រាប់ផ្តល់ការណែនាំដល់បុគ្គលិកផ្នែកសង្គមកិច្ចដែលទើបចូលធ្វើការងារថ្មីៗ។ បន្ថែមលើនេះ គួរផ្តល់វគ្គសិក្សាកម្រិតខ្ពស់បន្ថែមទៀតក្នុងពេលបំពេញការងារ ដើម្បីស្ថាបនាបន្ថែមលើមូលដ្ឋានដែលមានស្រាប់រួចហើយ ព្រមទាំងដើម្បីពង្រឹងបន្ថែមនៅក្នុងគោលបំណងវគ្គបណ្តុះបណ្តាលឱ្យមានការចូលរួមប្រកបដោយសីលធម៌ជាមួយកុមារ និងគ្រួសារដែលប្រឈមហានិភ័យនៃការបំបែកចេញពីគ្រួសារ ដោយផ្តោតការយកចិត្តទុកដាក់លើសុំកូន និងបញ្ហាប្រឈមជាក់លាក់ដែលអាចកើតមានសម្រាប់សុំកូន។ បន្ថែមលើនេះ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវជននីតិសម្បទា អាចចុះសិក្សាអំពីផ្ទះរបស់ឪពុកម្តាយចិញ្ចឹមដែលមានសក្តានុពល (PAPs) ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលត្រៀមខ្លួនសម្រាប់ឪពុកម្តាយចិញ្ចឹមដែលមានសក្តានុពល ដើម្បីធានាឱ្យបាននូវការប្រតិបត្តិប្រកបដោយសីលធម៌ក្នុងការងារសុំកូនក្នុងប្រទេស។ វិស័យជាទស្សនាទានទាំងអស់នេះ ក៏គួរត្រូវបានពង្រឹងបន្ថែមនៅក្នុងកម្មវិធីសិក្សារបស់ថ្នាក់សាកលវិទ្យាល័យ ជាពិសេសទៅលើប្រធានបទ ការថែទាំជំនួស និងសុំកូន ដែលជាវិស័យសិក្សាឯកទេស ក្នុងនោះគឺរួមមានទាំងការប្រឹក្សាយោបល់មុនពេលសុំកូន និងការគាំទ្រក្រោយពេលសុំកូន។

ជាចុងក្រោយ អ្នកសង្គមកិច្ច ចាំបាច់បានទទួលមូលនិធិគ្រប់គ្រាន់ដើម្បីអនុវត្តការងាររបស់ខ្លួននៅក្នុងសហគមន៍ ជាពិសេសគឺការងារចុះផ្សព្វផ្សាយដើម្បីស្វែងរកគ្រួសារកំណើត ឬគ្រួសារចិញ្ចឹម។ គោលនយោបាយ និងនីតិវិធីរដ្ឋបាលដែលមានទិសដៅឆ្ពោះទៅរកការគ្រប់គ្រងករណីសម្រាប់ការការពារកុមារ គឺមានភាពចាំបាច់ខ្វះមិនបាន។ គោលនយោបាយនិងនីតិវិធី គឺចាំបាច់ត្រូវរួមបញ្ចូលនូវបទដ្ឋានស្តីពីសមត្ថភាពការប្រតិបត្តិសម្រាប់អ្នកសង្គមកិច្ច និងបទដ្ឋានសម្រាប់អង្គការផ្តល់សេវាសង្គម ដែលជាមូលដ្ឋានព័ត៌មានសម្រាប់ការប្រតិបត្តិដោយផ្ទាល់ជាក់ស្តែងក្នុងក្របខណ្ឌការងារផ្តល់សេវា។

[59] Holt International. (2021) EVALUATION REPORT: Pilot project "Promoting Permanency Planning for Children through Domestic Adoption, Cambodia". Holt International Children's Services, 35. p. 14.

## អនុសាសន៍៖

→បន្តកសាង**ភាពមានវិជ្ជាជីវៈរបស់កម្លាំងសេវាសង្គម** ដោយដាក់ពួកគេឱ្យធ្វើការនៅក្នុងទីតាំង និងមុខតំណែងសមស្រប ហើយផ្តោតការយកចិត្តទុកដាក់ជាអាទិភាពក្នុងការរក្សាបុគ្គលិកទាំងនោះដើម្បីទ្រទ្រង់ឱ្យមានភាពគង់វង្សផ្នែកចំណេះដឹងនៅក្នុងរដ្ឋាភិបាល។

→ការបណ្តុះបណ្តាលសម្រាប់អ្នកសង្គមកិច្ច ដែលធ្វើការនៅថ្នាក់ឃុំ និងថ្នាក់ភូមិ គឺជាការងារដ៏ចាំបាច់ដើម្បីគាំទ្រដល់កម្លាំងការងារ ជាពិសេសការបណ្តុះបណ្តាលផ្តោតដាក់លាក់លើសុំកូនស្តីពីធាតុទាំងឡាយនៅក្នុងដំណើរការទាំងមូលពីការថែតាំងពីដើមទីរហូតទៅនៃការធ្វើផែនការទុកដាក់អចិន្ត្រៃយ៍ ដោយពិចារណាជាពិសេសលើការចូលរួមប្រកបដោយសីលធម៌។ ការបណ្តុះបណ្តាលគួររួមមានទាំងការស៊ើបអង្កេតប្រវត្តិផ្នែកសង្គម ការកំណត់ភាពសមស្របដើម្បីសុំកូន ការផ្គូផ្គងជាមួយឪពុកម្តាយដែលមានសក្តានុពល និងជំនាញប្រឹក្សាយោបល់ សម្រាប់ធ្វើការជាមួយកុមារ និងគ្រួសារនៅក្នុងដំណើរការសុំកូន។ ម្យ៉ាងទៀត ការសហការជាមួយអាជ្ញាធរមូលដ្ឋាន (*របៀបដើម្បី/ជំនាញប្រាស្រ័យទាក់ទង*) ក៏គួរសង្កត់ធ្ងន់ផងដែរ។

→**ការចែករំលែកព័ត៌មាន៖** អង្គការមិនមែនរដ្ឋាភិបាលដែលមានភារកិច្ចជួយជ្រោមជ្រែងរដ្ឋាភិបាល ពុំមែនសុទ្ធតែបានទទួលព័ត៌មានគ្រប់គ្រាន់អំពីការសម្រេចចិត្ត និងវិធានការដែលបានធ្វើឡើង ដែលអាចប៉ះពាល់ដល់ការងាររបស់ពួកគេ ដូចជាការប៉ាន់ប្រមាណដែលត្រូវបានធ្វើឡើង និងការកែប្រែគោលនយោបាយនោះឡើយ។ ស្ថានភាពនេះបង្កើតឱ្យមានចន្លោះប្រហោងដែលមិនគួរកើតមាននៅក្នុងការផ្តល់សេវា ជាហេតុបង្កឱ្យមានភាពប្រទាំងប្រទើស និងប៉ះពាល់ដល់ដំណើរការក្នុងលក្ខណៈមួយដែលពុំអំណោយផលដល់ការបន្តការថែទាំ និងគុណភាពថែទាំជាទូទៅនោះឡើយ។

→ផ្តល់ការគាំទ្រដល់អ្នកចាកចេញពីការថែទាំ និងការគាំទ្រក្រោយពេលសុំកូន។

→ដាក់ឱ្យមានធនធានផ្នែកហិរញ្ញវត្ថុ និងផ្នែកកស្តុភារ ដើម្បីធានាឱ្យបានថា អ្នកផ្តល់សេវាសង្គមបានទទួលការគាំទ្រគ្រប់គ្រាន់ ដើម្បីអនុវត្តសកម្មភាពចុះផ្សព្វផ្សាយ និងការចុះសួរសុខទុក្ខតាមគ្រួសារតាមការចាំបាច់។

→សិក្សាស្វែងយល់ដើម្បីអភិវឌ្ឍឱ្យមានវគ្គសិក្សាដែលអាចបង្រៀនមួយវគ្គៗដាច់តែឯង ស្តីពីការថែទាំដោយគ្រួសារធម៌ និងសុំកូននៅក្នុងកម្មវិធីផ្តល់វិញ្ញាបនបត្រផ្នែកសង្គមកិច្ចរបស់សាកលវិទ្យាល័យនៅក្នុងស្រុក។

## ការចូលរួមរបស់កុមារ

ការសិក្សារបស់យើងបានកត់សម្គាល់ឃើញថា ថ្វីបើចេតនាក្នុងការបញ្ជ្រាបការចូលរួម គឺពិតជាមានវត្តមានដូចដែលបានលើកឡើងខាងលើក្តី ប៉ុន្តែគួរចាត់អាទិភាពបន្ថែមទៀតឱ្យមានការ**ចូលរួមរបស់កុមារជាលក្ខណៈប្រព័ន្ធ**។ ចំណុចនេះ គឺមានសារៈសំខាន់ជាពិសេសនៅក្នុងការសម្រេចចិត្តរបស់តុលាការស៊ីវិលនៅពេលកុមារដែលត្រូវសុំគួរមានការចូលរួម យោងទៅតាមសមត្ថភាពដែលមានការវិវត្តរបស់ពួកគេ ក្នុងនាមពួកគេជាអ្នកពាក់ព័ន្ធចម្បង។

ប្រសិនរាជរដ្ឋាភិបាលកម្ពុជាមានបំណងចាត់អាទិភាពលើការចូលរួមរបស់កុមារ ពួកយើងសូមផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលថាត្រូវ**អភិវឌ្ឍផែនការការចូលរួមរបស់កុមារ**។ ផែនការនេះអាចផ្តោតទៅលើការ

ថែទាំជំនួស និងសុំកូន ប៉ុន្តែក៏អាចពង្រីកបន្ថែមដើម្បីរួមបញ្ចូលនូវការងារកិច្ចការពារកុមារជាទូទៅ ក៏ដូចជាវិស័យផ្សេងៗដូចជាច្បាប់ជាដើមផងដែរ។ ជំហានទី១ គឺអាចជាលំហាត់ធ្វើផែនទី និងការសាកសួរដើម្បីទទួលស្គាល់ការអនុវត្តល្អនៅ ស្តីពីការចូលរួមរបស់កុមារនៅក្នុងដំណើរការសុំកូនដែលអាចពង្រីកបន្ថែមទៀតបាន។ ឬម្យ៉ាងទៀត ក៏អាចរួមបញ្ចូលនូវការបញ្ជ្រាបការយល់ដឹងសម្រាប់អ្នកពាក់ព័ន្ធជាមនុស្សពេញវ័យ រួមទាំងការណែនាំស្តីពីវិធីដើម្បីឱ្យកុមារតាមវ័យផ្សេងៗអាចចូលរួមបាន។ ការងារនេះអាចជួយគាំទ្រក្នុងការបង្កើតលំហឱ្យកុមារបញ្ចេញទស្សនៈយល់ឃើញរបស់ខ្លួន រួមទាំងនៅក្នុងការសម្រេចចិត្តទុកដាក់កុមារជាអចិន្ត្រៃយ៍នៅក្នុងតុលាការ និងក្រៅតុលាការផងដែរ។ ម្យ៉ាងទៀត ក៏ជាការប្រសើរផងដែរក្នុងការព្យាយាមទទួលបានគំនិតជាអ្នកជំនាញពីសំណាក់កុមារ និងយុវជនដូចជាអ្នកចាកចេញពីការថែទាំ និងកុមារក្នុងការថែទាំដោយគ្រួសារធម៌នៅក្នុងតួនាទីការតស៊ូមតិ និងប្រឹក្សាយោបល់។ អនុសាសន៍ទាំងនេះនឹងអាចជួយស្ថាបនាកម្មវិធីបញ្ជ្រាបការចូលរួមរបស់កុមារឱ្យកាន់តែរឹងមាំ និងប្រកបដោយចេតនាបន្ថែមទៀត។

**អនុសាសន៍៖**

→អនុវត្តការធ្វើផែនទីការចូលរួមរបស់កុមារនៅក្នុងគោលនយោបាយ។

→អភិវឌ្ឍផែនការការចូលរួមរបស់កុមារ ដោយក្នុងនោះក៏មានរួមបញ្ចូលនូវការបញ្ជ្រាបការយល់ដឹងសម្រាប់មនុស្សពេញវ័យ និងការបង្កលទ្ធភាពចូលរួមសម្រាប់កុមារ/មនុស្សវ័យក្មេងនៅក្នុងតួនាទីការតស៊ូមតិ និងប្រឹក្សាយោបល់។

## ៥. សន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានការជួយជ្រោមជ្រែងពីអង្គការមិនមែនរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគួរជាទីកត់សម្គាល់ក្នុងការធានាឱ្យមានសិទ្ធិ និងការការពារកុមារ ពាក់ព័ន្ធនឹងការថែទាំជំនួសតាមគ្រួសារ ជាពិសេសគឺការថែទាំដោយគ្រួសារធម៌ និងសុំកូនក្នុងប្រទេស ហើយកំពុងឈានជំហានឆ្ពោះទៅពង្រឹងគោលនយោបាយអនុលោមតាមបទដ្ឋានអន្តរជាតិ។ ប្រសិនប្រទេសកម្ពុជា បន្តកសាងកម្លាំងសេវាសង្គម និងសមត្ថភាពក្នុងការផ្តល់សេវារបស់ខ្លួនបន្ថែមទៀត នោះប្រទេសកម្ពុជាពិតជាអាចមានសមត្ថភាពថែទាំកុមាររបស់ខ្លួនបាន។

### សុំកូនក្នុងប្រទេស

នៅក្នុងការប៉ាន់ប្រមាណនេះ យើងបានពិចារណាលើកត្តានានានៅក្នុងក្របខណ្ឌការពារកុមារ និងមាគ៌ានៃខ្សែប្រវាក់នៃការថែទាំពីដើមទីរហូតទៅ (care continuum spectrum) យ៉ាងទូលំទូលាយ ដែលអាចជះឥទ្ធិពលលើសមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការអនុវត្តគោលនយោបាយសុំកូនយ៉ាងត្រឹមត្រូវ អនុលោមតាមឧត្តមានុវត្តន៍ អន្តរជាតិផ្នែកគោលនយោបាយនាពេលបច្ចុប្បន្ន។ ច្បាស់ណាស់ថា កត្តាដ៏សំខាន់បំផុតសម្រាប់ជោគជ័យក្នុងការអនុវត្តគោលនយោបាយសុំកូនអនុវត្តតាមបទដ្ឋានអន្តរជាតិ គឺ*ការបង្ការទប់ស្កាត់*ជៀសជាង*ការពង្រីក*សេវាសុំកូន ពោលគឺជាការកាត់បន្ថយតម្រូវការសុំកូនតាមរយៈការឆ្លើយតបចំពោះបញ្ហាឫសគល់ដែលនាំឱ្យមានការបោះបង់ចោលកុមារ។ ពួកយើងសូមផ្តល់អនុសាសន៍ឱ្យប្រទេសកម្ពុជា**បន្តពង្រឹងការថែទាំជំនួស និងការប្រតិបត្តិនៃសុំកូនក្នុងប្រទេស ព្រមទាំងបិទគម្លាតចន្លោះប្រហោងផ្នែកច្បាប់សម្រាប់សុំកូនក្នុងប្រទេស** (ព្រមទាំងចន្លោះប្រហោងនៅក្នុងក្រមរដ្ឋប្បវេណី)។ ការងារទាំងនេះហើយ នោះពិតជាអាចកាត់បន្ថយតម្រូវការដើម្បីសុំកូន (ទាំងសុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស) **ហើយទុកជម្រើសសុំកូននេះជាជម្រើសចុងក្រោយបំផុតដើម្បីផ្តល់ការទុកដាក់អចិន្ត្រៃយ៍សម្រាប់កុមារ។**

### សុំកូនអន្តរប្រទេស

ភាពប្រុងប្រយ័ត្នដែលកម្ពុជាបានប្រើប្រាស់ចំពោះការសុំកូនអន្តរប្រទេស គឺជារឿងគួរឱ្យស្ងើចសរសើរ បើគិតទៅលើប្រវត្តិប្រកបដោយបញ្ហារបស់ការសុំកូនអន្តរប្រទេសនាពេលអតីតកាលកន្លងមក។ ប៉ុន្តែបើគិតទៅលើស្ថានភាពបច្ចុប្បន្នដែលប្រព័ន្ធនៅខ្វះខាតតម្លាភាព នៅមានភាពមិនច្បាស់លាស់ផ្នែកច្បាប់ និងមានចន្លោះខ្វះខាតដែលអាចគំរាមកំហែងដល់សិទ្ធិ និងសុខុមាលភាពរបស់កុមារ ហើយក៏ដូចជាគោលជំហរផ្លូវការរបស់រដ្ឋាភិបាលស្តីពីស្ថានភាពនៃសុំកូនអន្តរប្រទេសនៅពុំទាន់ច្បាស់លាស់ ***យើងខ្ញុំសូមផ្តល់យោបល់យ៉ាងមុតមាំថា សូមកុំទាន់ប្រើប្រាស់ការសុំកូនអន្តរប្រទេសនាពេលឥឡូវនេះ។*** លុះត្រាណាតែភាពចន្លោះប្រហោងទាំងអស់នេះត្រូវបានដោះស្រាយ ដើម្បីធានាសុវត្ថិភាព និងសិទ្ធិរបស់កុមារដែលមិនមានការថែទាំពីឪពុកម្តាយ គឺនៅតែមានហានិភ័យដ៏ធ្ងន់ធ្ងរដែលកម្ពុជាអាចជួបប្រទះបញ្ហាដដែលពាក់ព័ន្ធនឹងការប្រតិបត្តិច្បាប់ដូចអ្វីដែលធ្លាប់មាននាពេលអតីតកាល។

ជំនួសមកវិញ ពួកយើងសូមលើកទឹកចិត្តប្រទេសកម្ពុជាឱ្យចាប់យកឱកាស ដើម្បី**ត្រួសត្រាយផ្លូវក្នុងចំណោមបណ្តាប្រទេសជាប្រជាជាតិអាស៊ានតាមរយៈការប្រកាន់ជំហរច្បាស់លាស់ប្រឆាំងនឹងការសុំកូនអន្តរប្រទេស** មិនត្រឹមតែអនុលោមតាមបទដ្ឋានដ៏ល្អបំផុតកម្រិតអន្តរជាតិក្នុងវិស័យសុំកូន និងកិច្ចការពារកុមារតែប៉ុណ្ណោះទេ ប៉ុន្តែក៏អនុលោមតាមកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្សដែលប្រទេសកម្ពុជា និងប្រទេសនៃប្រជាជាតិអាស៊ានដទៃទៀតបានអនុវត្តផងដែរ។

## អនុសាសន៍ទូទៅ

អាស្រ័យដោយមានអនុសាសន៍ជាក់លាក់ជាច្រើននៅតាំងពីផ្នែកខាងដើមរហូតដល់ផ្នែកខាងចុង នៃរបាយការណ៍នេះ យើងខ្ញុំជឿជាក់ថា អាចជាការមានប្រយោជន៍ក្នុង**ការធ្វើផែនទីនីតិវិធីសុំកូន**ដែលអាចយកមកប្រើប្រាស់ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីដំណើរការជូនសម្រាប់អ្នកពាក់ព័ន្ធនានា។

ម្យ៉ាងទៀត ជាការល្អផងដែរក្នុងការអភិវឌ្ឍ**ផែនការយុទ្ធសាស្ត្រសម្រាប់ការអនុវត្ត និងការកសាងសមត្ថភាព** ផ្អែកលើអនុសាសន៍លម្អិតដូចមានលើកឡើងក្នុងរបាយការណ៍នេះទាំងមូល។ ផែនការយុទ្ធសាស្ត្រនេះ គួរចាប់ផ្តើមដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីបង្កើតអាទិភាពច្បាស់លាស់តាមការព្រមព្រៀងគ្នា។

## ធនធាន

ជាការពិតណាស់ កិច្ចខិតខំនេះទាមទារធនធានដែលជារឿយៗ នៅមានភាពខ្វះខាតសម្រាប់គំនិតផ្តួចផ្តើមស្តីពីកិច្ចការពារកុមារ។ ដើម្បីបានទទួលជោគជ័យនៅក្នុងមហិច្ឆិតាក្នុងការថែទាំជំនួសរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាត្រូវការមូលនិធិបន្ថែមទៀតនៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីពង្រឹងយន្តការឆ្មាំទ្វារដែលចាំបាច់ផ្សេងៗ។ ហេតុដូច្នេះ យើងខ្ញុំសូមផ្តល់អនុសាសន៍ជូនយូនីសេហ្វឱ្យគាំទ្រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីកៀរគរការគាំទ្រឱ្យមានការចាត់ចែងថវិកាបន្ថែមទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈ**វគ្គបណ្តុះបណ្តាលការស្វែងរកការគាំទ្រផ្អែកលើភស្តុតាង**។ ការងារនេះអាចរួមមានការពិនិត្យឡើងវិញលើព័ត៌មានដែលមានបច្ចុប្បន្ន ប៉ុន្តែបន្ថែមលើនោះក៏អាចរួមមានការវិភាគចរន្តមូលនិធិ ការធ្វើផែនទីសព្វជ្រុងជ្រោយ និងការវិភាគថ្លៃចំណាយផងដែរ។

## សន្និដ្ឋាន

យើងខ្ញុំសូមអបអរប្រទេសកម្ពុជាចំពោះវឌ្ឍនភាពក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមក ដើម្បីធានានូវសុវត្ថិភាព និងសិទ្ធិសម្រាប់កុមារកម្ពុជាគ្រប់រូប ហើយយើងខ្ញុំគាំទ្រកិច្ចខិតខំដើម្បីបិទភ្ជិតចន្លោះប្រហោងដែលនៅសេសសល់ក្នុងនីតិវិធីសុំកូន ដើម្បីអាចពង្រឹងប្រព័ន្ធការពារកុមារឱ្យកាន់តែរឹងមាំថែមទៀត។

## ឧបសម្ព័ន្ធ៖ ឯកសារទទួលបានពីការពិភាក្សានៅក្នុងសិក្ខាសាលាពិនិត្យផ្ទៀងផ្ទាត់

### ក្រុមទី១៖ ការបិទភ្ជិតគម្លាតផ្នែកច្បាប់នៅក្នុងដំណើរការសុំកូន

*អនុសាសន៍សំខាន់ៗ*

→ បិទភ្ជិតគម្លាតរវាងគោលនយោបាយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយក្រមរដ្ឋប្បវេណីដែលចាំបាច់ត្រូវកំណត់ឡើងវិញ (ដើម្បីបញ្ជាក់ថាចំណុចនេះគឺត្រូវអនុវត្តសម្រាប់តែពលរដ្ឋកម្ពុជាប៉ុណ្ណោះ) ដើម្បីបន្ទឹដំណើរការសុំកូនតាមផ្លូវច្បាប់ឱ្យរលូន ដោយធានាឱ្យបានថាសេចក្តីព្រាងច្បាប់ការពារកុមារមានការចែងជាក់លាក់អំពីសុំកូនដោយជនបរទេស។

→ ក្នុងកិច្ចសហការជាមួយក្រសួងយុត្តិធម៌ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ត្រូវអភិវឌ្ឍន៍ (និងផ្សព្វផ្សាយតាមអនឡាញ) នូវសៀវភៅជំនួយស្មារតីសម្រាប់ផ្នែកយុត្តិធម៌ស្តីពីសុំកូន សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ដោយផ្អែកលើ *ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យការពារកុមារ៖ គោលការណ៍ណែនាំបែបប្រតិបត្តិសម្រាប់សុំកូន* ដែលផ្តល់ការចង្អុលបង្ហាញស្តីពីការអនុវត្តច្បាប់ ក្នុងនោះរួមមានទាំង៖

- ចែងឱ្យច្បាស់ថាច្បាប់សុំកូន គឺអនុវត្តចំពោះតែដំណើរការផ្សេងៗសម្រាប់ជនជាតិកម្ពុជាប៉ុណ្ណោះ គឺពុំមែនសម្រាប់ជនបរទេស ឬពលរដ្ឋប្រទេសផ្សេងដែលមានបំណងសុំកុមារកម្ពុជានោះទេ (ពួកគេត្រូវយោងទៅកាន់ច្បាប់ស្តីពីសុំកូនអន្តរប្រទេស)
- តួនាទីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងគ្រប់ករណីសុំកូនទាំងអស់។ សេចក្តីណែនាំចេញដោយក្រសួងយុត្តិធម៌ សម្រាប់ចៅក្រមទាំងអស់ គឺចាំបាច់ត្រូវមានការផ្តល់យោបល់ថាការសម្រេចអំពីសុំកូនពុំអាចធ្វើឡើងដោយពុំមានវត្តមានរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងឯកសាររបស់បុគ្គលិកសង្គមកិច្ចអាជីពនោះឡើយ។
- បញ្ជីត្រួតពិនិត្យបែបប្រតិបត្តិសម្រាប់គ្រប់ដំណាក់កាលទាំងអស់នៃដំណើរការ
- ការតម្រូវដែលទាមទារឱ្យមានការប្រមូលទិន្នន័យវិភាគទិន្នន័យ ដកព័ត៌មានដែលអាចធ្វើឱ្យស្គាល់អត្តសញ្ញាណរួចធ្វើការបោះពុម្ពផ្សាយ
- ការបង្កើតឱ្យមានប្រព័ន្ធមួយដែលឪពុកម្តាយចិញ្ចឹមជាសក្តានុពលទាំងអស់ចាំបាច់ត្រូវចុះបញ្ជីការដាក់ពាក្យសុំកូនរបស់ខ្លួន
- ឯកសារពិគ្រោះដើម្បីភ្ជាប់ទំនាក់ទំនងរវាងទេសចរណ៍មណ្ឌលកុមារកំព្រានឹងការជួញដូរមនុស្សដោយមណ្ឌលកុមារកំព្រា។តំណភ្ជាប់ទៅកាន់សូចនាករសំខាន់ៗនៃការជួញដូរមនុស្សដោយមណ្ឌលកុមារកំព្រា។
- ផ្នែកដាច់ដោយឡែកមួយនៅក្នុងសុំកូនអន្តរប្រទេស និងតួនាទីរបស់អ្នកពាក់ព័ន្ធនានា ព្រមទាំងដំណើរការដែលចាំបាច់ត្រូវអនុវត្តតាម (រួមទាំងលទ្ធផលដែលអាចកើតមានសម្រាប់កុមារ និងពលរដ្ឋបរទេសប្រសិនដំណើរការទាំងនោះពុំត្រូវបានអនុវត្តតាម)។

→ ក្រសួងយុត្តិធម៌គួរជំរាបប្រាប់ដល់ចៅក្រម ហើយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) គួរជំរាបប្រាប់ទៅមេធាវីអំពីនីតិវិធីសុំកូនរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយត្រូវសហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីធ្វើឱ្យក្រមរដ្ឋប្បវេណីមានភាពស្របគ្នាជាមួយនីតិវិធីសុំកូនបច្ចុប្បន្នភាព និងនីតិវិធីការពារកុមារដទៃទៀត។

→ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងកិច្ចសហការជាមួយក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាលត្រូវអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹង ដោយផ្តោតជាក់លាក់សម្រាប់បុគ្គលិកមន្ទីរពេទ្យដើម្បីទប់ស្កាត់ការអនុវត្តសុំកូនក្រៅផ្លូវការតាមរយៈការផ្តល់ព័ត៌មានឱ្យពួកគាត់បានជ្រាបអំពីផលវិបាកផ្នែកច្បាប់ជាសក្តានុពលសម្រាប់ពួកគេ ក៏ដូចជាគ្រោះថ្នាក់ជាសក្តានុពលចំពោះសិទ្ធិ និងសុខុមាលភាពរបស់កុមារ និងត្រូវលើកកម្ពស់ការយល់ដឹងអំពីច្រកផ្លូវស្របច្បាប់សម្រាប់សុំកូន។

→ ពង្រឹងនីតិវិធីដើម្បីការពារអត្តសញ្ញាណរបស់កុមារត្រូវគេបោះបង់ ឬកុមារដែលត្រូវបានសុំតាមរយៈការចុះបញ្ជីកំណើតជាកាតព្វកិច្ច រួមទាំងការចុះបញ្ជីកំណើតដោយបុគ្គលិកវេជ្ជសាស្ត្រ

→ ការបង្កើតផែនការយុទ្ធសាស្ត្រដែលចាត់អាទិភាពដល់ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួងបន្ថែមទៀតរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយក្រសួងយុត្តិធម៌, ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ រួមទាំងវគ្គបណ្តុះបណ្តាលពហុវិស័យស្តីពីច្បាប់សុំកូន និងនីតិវិធីសុំកូន។

### *សំណួរមគ្គុទ្ទេសក៍សម្រាប់ការពិភាក្សា*

តើវិសោធនកម្មច្បាប់អ្វីខ្លះដែលចាំបាច់ដើម្បីបិទភ្ជិតគម្លាតផ្នែកច្បាប់ និងបន្ស៊ីដំណើរការសុំកូនស្របច្បាប់ឱ្យបានរលូនទៅជាប្រព័ន្ធតែមួយ ? តើនរណាជាអ្នកដឹកនាំ ?

តើធ្វើដូចម្តេចទើបយើងអាចឱ្យក្រសួងពាក់ព័ន្ធ ( យុត្តិធម៌ សុខាភិបាល មហាផ្ទៃ ) ចូលរួមដើម្បីបិទភ្ជិតគម្លាតនៅក្នុងប្រព័ន្ធ រួមទាំងគម្លាតដូចមានរៀបរាប់ខាងលើ ? ឧ. តើយើងអភិវឌ្ឍសៀវភៅជំនួយស្មារតីក្នុងផ្នែកយុត្តិធម៌លើការងារសុំកូនសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាដោយរបៀបណា ?

តើយើងអាចពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួងរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ រួមទាំងការបណ្តុះបណ្តាលពហុវិស័យស្តីពីច្បាប់សុំកូន និងនីតិវិធីសុំកូនឱ្យបានកាន់តែប្រសើរថែមទៀតដោយរបៀបណា ? តើធ្វើដូចម្តេចទើបយើងអាចពង្រឹងកិច្ចសហការអន្តរក្រសួងដើម្បីអាចផ្តល់ព័ត៌មាន/បញ្ជ្រាបការយល់ដឹងឱ្យកាន់តែប្រសើរសម្រាប់អន្តរការីពាក់ព័ន្ធ ( ឧ. ចៅក្រម, មេធាវី, បុគ្គលិកមន្ទីរពេទ្យ ) អំពីតួនាទីរបស់ពួកគេក្នុងការធានាឱ្យមាននីតិវិធីសុំកូនយ៉ាងល្អត្រឹមត្រូវ ?

តើធ្វើដូចម្តេចទើបយើងអាចធានាតម្លាភាព និងគណនេយ្យភាពនៅក្នុងគ្រប់ដំណើរការសុំកូនទាំងអស់បាន ? តើនរណាជាអ្នកទទួលខុសត្រូវប្រសិនមានបញ្ហានាពេលអនាគតពាក់ព័ន្ធជាមួយកុមារដែលជាកម្មវត្ថុនៃសុំកូន ?

*កំណត់សម្គាល់ការពិភាក្សា៖*

- ក្រមរដ្ឋប្បវេណីពុំបានចែងអំពីតួនាទីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។
- មិនមានដំណើរការនីតិវិធីសុំកូនក្នុងប្រទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅក្នុងក្រមរដ្ឋប្បវេណីទេ ដូចជាការប៉ាន់ប្រមាណអំពីកុមារ ការសិក្សាអំពីផ្ទះរបស់ PAP ។ល។

**អនុសាសន៍៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌ត្រូវដាក់ដំណើរការការងារ/រដ្ឋបាលផ្នែកសង្គមកិច្ចចូលទៅក្នុងសុំកូនក្នុងប្រទេស។

**យោបល់៖**

- ធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីសម្រាប់មាត្រាពាក់ព័ន្ធជាមួយសុំកូនក្នុងប្រទេស។ វិភាគគម្លាតចន្លោះខ្វះខាតនៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន។ ផែនការសកម្មភាព៖ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបញ្ជូនការវិភាគចន្លោះគម្លាតខ្វះខាតនៅក្នុងក្រមរដ្ឋប្បវេណីទៅឱ្យក្រសួងយុត្តិធម៌។** ស្របពេលជាមួយគ្នានេះដែរ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌គួរអភិវឌ្ឍឱ្យមានប្រកាសអន្តរក្រសួងស្តីពីសុំកូនក្នុងប្រទេស។**
- ធ្វើការជាមួយមន្ទីរពេទ្យដើម្បីបង្ការទប់ស្កាត់សុំកូនក្រៅផ្លូវការនៅក្នុងមន្ទីរពេទ្យនៅពេលមានកុមារត្រូវគេបោះបង់។ **ផែនការសកម្មភាព៖ ប្រកាសអន្តរក្រសួងជាមួយក្រសួងសុខាភិបាល។**
    - មន្ទីរពេទ្យចេញលិខិតបញ្ជាក់កំណើត (ក្លែងក្លាយ) សម្រាប់គូស្រករដែលមានបំណងចង់សុំកូន រួចហើយឪពុកម្តាយអាចចុះបញ្ជីកំណើតកុមារនៅក្រុមប្រឹក្សាឃុំដោយពុំអនុវត្តតាមដំណើរការផ្នែកច្បាប់។
    - ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យពលរដ្ឋបរទេសសុំកុមារកម្ពុជាតាមនីតិវិធីសុំកូនក្នុងប្រទេស។ ក្នុងករណីជាច្រើនឪពុកម្តាយចិញ្ចឹមពុំអាចនាំយកកូនចិញ្ចឹមទៅកាន់ប្រទេសកំណើតរបស់ខ្លួនឡើយ។
    - ការរក្សាកំណត់ត្រា = ស្វែងយល់បន្ថែមទៀតថាតើធ្វើរបៀបណាដើម្បីកត់ត្រាករណីសុំកូនក្នុងប្រទេស **(ការរក្សាកំណត់ត្រាសុំកូនក្នុងប្រទេស)។**
- យោបល់ = **ពង្រឹងកិច្ចសហប្រតិបត្តិការរវាងតុលាការខេត្ត និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។** ចាត់តាំងជនបង្គោលរបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីសហប្រតិបត្តិការជាមួយតុលាការ។ ស្វែងយល់បន្ថែមទៀតអំពី**គណកម្មាធិការថែទាំជំនួស** ដែលក្នុងនោះរួមមានសមាសភាពមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តុលាការ។ល។)

- ផែនការសកម្មភាព៖ អ្នកតំណាងរបស់ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ត្រូវបញ្ជូនលទ្ធផលនៃការពិភាក្សាទៅកាន់ថ្នាក់ដឹកនាំក្រសួង
- ផែនការសកម្មភាព៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងបញ្ជូនលិខិតផ្លូវការទៅកាន់ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល។

## ក្រុមទី២៖ យុទ្ធនាការលើកកម្ពស់ការយល់ដឹង

### *អនុសាសន៍សំខាន់ៗ*

→ ធ្វើការសិក្សាអំពីទិដ្ឋភាពនានានៃការបោះបង់កុមារ ទស្សនៈយល់ឃើញ និងឥរិយាបថអំពីសុំកូន (យុទ្ធនាការលើកកម្ពស់ការយល់ដឹងមុនពេលសុំកូន)។

→ ចាត់បេសកកម្មឱ្យមានយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសុំកូន (យុទ្ធនាការដោយផ្ទាល់ និងយុទ្ធនាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម) ដែលលើកទឹកចិត្តគ្រួសារឱ្យក្លាយជាគ្រួសារធម៌ និងគ្រួសារចិញ្ចឹម (ដោយស្របច្បាប់) រួមទាំងសម្រាប់កុមារមានតម្រូវការពិសេស កុមារា កុមារធំ និងកុមារដទៃទៀតដែលមានការលំបាកក្នុងការទុកដាក់។ ការផ្ដល់សារគឺអាចផ្អែកលើការសិក្សាអំពីទស្សនៈយល់ឃើញរបស់សង្គមដូចបានស្នើឡើងខាងដើម ដើម្បីប្រយុទ្ធប្រឆាំងចំពោះទស្សនៈយល់ឃើញខុសឆ្គង ព្រមទាំងដើម្បីអប់រំប្រជាជនកម្ពុជា និងជនបរទេសផងដែរ អំពីផលវិបាកផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមដែលអាចកើតមានដោយសារការមិនអនុលោមតាមគោលនយោបាយសុំកូនផ្លូវការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីអំពីកុមារ និងគ្រួសារចិញ្ចឹម។

### *សំណួរមគ្គុទ្ទេសក៍សម្រាប់ការពិភាក្សា*

តើព័ត៌មានជាក់លាក់អ្វីខ្លះដែលពួកយើងដឹង/ត្រូវដឹង/ត្រូវយល់ឱ្យកាន់តែប្រសើរអំពីការបោះបង់កុមារ និងទស្សនៈយល់ឃើញ ព្រមទាំងឥរិយាបថអំពីសុំកូនដើម្បីជាមូលដ្ឋានព័ត៌មានសម្រាប់យុទ្ធនាការលើកកម្ពស់ការយល់ដឹង? តើមានការពិចារណាផ្នែកវប្បធម៌ ជំនឿអ្វីខ្លះដែលយើងគួរយកមកពិចារណាដាក់បញ្ចូលទៅក្នុង (ជំនឿ) អ្វីខ្លះដែលគួរគិតគូរដាក់បញ្ចូលទៅក្នុងផែនការទីផ្សារ/លើកកម្ពស់ការយល់ដឹង ឧទាហរណ៍ដូចជា ជំនឿអំពីពិការភាព ឬអំពីភាពសមស្របរបស់បុគ្គលវ័យចំណាស់ ឬបុគ្គលនៅលីវក្នុងនាមជាឪពុកម្ដាយដែលមានលក្ខណៈសមស្រប?

តើធ្វើដូចម្ដេចទើបយើងអាចធ្វើឱ្យគំនិតស្ដីពីសុំកូនតាមគ្រួសារក្លាយជាគំនិតមានប្រជាប្រិយភាព ដោយលើកទឹកចិត្តគ្រួសារឱ្យទទួលជាគ្រួសារធម៌ និងសុំកូន (ស្របច្បាប់) រួមទាំងកុមារមានតម្រូវការពិសេស កុមារា កុមារធំ និងកុមារដទៃទៀតដែលពិបាកទុកដាក់?

តើធ្វើដូចម្ដេចទើបយើងអាចលើកកម្ពស់ការយល់ដឹងឱ្យបានប្រកបដោយប្រសិទ្ធភាពអំពីដំណើរការសុំកូនក្នុងស្រុកដែលសមស្របដើម្បីប្រយុទ្ធប្រឆាំងជាមួយការបកស្រាយខុសឆ្គង និងដើម្បីអប់រំប្រជាជនកម្ពុជា និងជនបរទេសផងដែរ អំពីផលវិបាកផ្នែកច្បាប់ សេដ្ឋកិច្ច និងសង្គមមកលើកុមារ និងគ្រួសារចិញ្ចឹមបណ្ដាលមកពីការមិនអនុលោមតាមគោលនយោបាយសុំកូនផ្លូវការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា?

### ***<u>កំណត់សម្គាល់បានទទួលពីការពិភាក្សា៖</u>***

#### ១. យុទ្ធនាការលើកកម្ពស់ការយល់ដឹងស្ដីពីការបោះបង់ចោលកុមារ

- ផ្សព្វផ្សាយជាសាធារណៈតាមរយៈមណ្ឌលសុខភាព អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ
- ផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយសង្គម (វិទ្យុ និងហ្វេសប៊ុក)
- ផ្សព្វផ្សាយជាសាធារណៈ និងអប់រំអំពីនីតិវិធីដើម្បីឧត្តមប្រយោជន៍របស់កុមារ

**២. មូលហេតុនៃការបោះបង់**

- ភាពក្រីក្រ
- ស្រឡាញ់គ្នាខុសប្រពៃណី
- ចំណាកស្រុក
- ជំនឿ និងសាសនា
- អ្នកប្រកបរបរផ្លូវភេទមានផ្ទៃពោះដោយចៃដន្យ
- កុមារ/ទារកមានពិការភាព

**គ្រួសារធម៌ ឬសុំកូនពេញលេញ និងសុំកូនសាមញ្ញ**

- គុណសម្បត្តិនៃការថែទាំតាមបែបវប្បធម៌ និងប្រពៃណី
  - មិនមាននីតិវិធីច្បាប់ស្មុគស្មាញ
  - កុមារ/ទារកមានអារម្មណ៍កក់ក្តៅដែលបានទទួលបានការថែទាំងពីសាច់ញាតិរបស់ខ្លួន ហើយបន្តរស់នៅក្នុងសហគមន៍របស់ខ្លួន
  - បានចូលរៀន និងរស់នៅមានជីវិតប្រៀបបីដូចជាពួកគេរស់នៅក្នុងគ្រួសារតូចធម្មតា
- គុណវិបត្តិ
  - មិនមានសិទ្ធិទទួលស្នងមរតកដូចកូនបង្កើត (ដូចមានចែងនៅក្នុងច្បាប់)

**គុណសម្បត្តិនៃការថែទាំដោយគ្រួសារធម៌**

- កុមារ/ទារកទទួលការថែទាំបណ្តោះអាសន្នសម្រាប់មួយរយៈពេលខ្លី
- អាចនាំទៅរកសុំកូនក្នុងស្រុក

**គុណវិបត្តិនៃការថែទាំដោយគ្រួសារធម៌**

- ការថែទាំដោយគ្រួសារធម៌មានរយៈពេលកំណត់
- មិនមានសិទ្ធិទទួលស្នងមរតកដូចកូនបង្កើត (ដូចមានចែងនៅក្នុងច្បាប់)
- មានហានិភ័យខ្ពស់ចំពោះការផិតក្បត់។

លើកទឹកចិត្តឱ្យបង្កើតគណកម្មាធិការទទួលបន្ទុកការថែទាំដោយឪពុកម្តាយធម៌អន្តរក្រសួងនៅថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនានា (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងយុត្តិធម៌ និង ក្រសួងមហាផ្ទៃ)។

ផលវិបាកនៃនីតិវិធីសុំកូនក្នុងស្រុក៖

- កម្មវិធីសុំកូនអន្តរប្រទេសត្រូវបានដំណើរការផ្អែកលើដំណើរការសុំកូនក្នុងប្រទេស។ ចាំបាច់ត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាពសម្រាប់សុំកូនក្នុងប្រទេសជាមុនសិន អនុលោមតាមនីតិវិធីជាធរមានមុននឹងដាក់ឈ្មោះកុមារ/ទារកទៅកាន់នាយកដ្ឋានការពារកុមារ ដើម្បីឱ្យកុមារ/ទារកអាចមានលក្ខណៈសម្បត្តិចូលរួមក្នុងកម្មវិធីសុំកូនអន្តរប្រទេស។

កម្មវិធីដែលស្ថាប័នទទួលបន្ទុក និងដៃគូ NGOs ពាក់ព័ន្ធផ្តល់អនុសាសន៍ឱ្យប្រើប្រាស់៖

- ការអនុវត្តចាំបាច់ត្រូវតែអនុលោមតាមច្បាប់ និងនីតិវិធី
- បញ្ហាសុខភាពត្រូវធ្លាក់ជាបន្ទុករបស់អាណាព្យាបាលដែលជាឪពុកម្តាយ

## ក្រុមទី៣៖ ការបន្សុីការគ្រប់គ្រងករណីស្មុំកូនឱ្យមានភាពរលូន

### *អនុសាសន៍សំខាន់ៗ*

→ អនុវត្តការសិក្សាស៊ីជម្រៅដើម្បីកំណត់ថាតើធ្វើរបៀបណាដើម្បីអាចបន្សុីការគ្រប់គ្រងករណីឱ្យបានរលូនសម្រាប់ការថែទាំជំនួស និងស្មុំកូន។

→ កំណត់ថាតើមានប្រព័ន្ធគ្រប់គ្រងករណីថ្មីៗ ឬទើបកើតមានណាខ្លះដែល UNICEF និង/ឬអង្គភាពការពារកុមារដទៃទៀតប្រើប្រាស់នៅទូទាំងសាកលលោក។

→ បន្សុីចូលទៅក្នុងប្រព័ន្ធដែលមានលក្ខណៈប្រសើរបំផុតសម្រាប់ធ្វើផែនការអចិន្ត្រៃយ៍ឱ្យបានរលូន។ តាមមើលកុមារនៅក្នុងដំណើរការទាំងមូលនៃការធ្វើផែនការទុកដាក់អចិន្ត្រៃយ៍ ជាពិសេសនៅពេលស្មុំកូនត្រូវបានយកមកពិចារណា គឺមានភាពចាំបាច់ណាស់សម្រាប់ការប្រតិបត្តិក្នុងការគ្រប់គ្រងករណីដែលរួមបញ្ចូលជំហានទាំងអស់ដែលត្រូវបានយកមកជាមូលដ្ឋាននៃការសម្រេចចិត្តក្នុងការកំណត់លក្ខណៈសម្បត្តិអាចដាក់ឱ្យស្មុំបាន។

→ អភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវ ដើម្បីផ្សារភ្ជាប់ផ្នែកទាំងឡាយនៃប្រព័ន្ធការពារកុមារ រួមទាំងការពង្រឹង SSWF ដោយផ្តល់ការបណ្តុះបណ្តាល ជាពិសេសការបណ្តុះបណ្តាលស្តីអំពីប្រព័ន្ធ Primero, ប្រព័ន្ធ OSCaR, ឬប្រព័ន្ធដែលបានព្រមព្រៀងគ្នាដទៃទៀត។ បន្តកិច្ចសហការរវាង UNICEF ជាមួយរដ្ឋាភិបាល និង NGO ដើម្បីឈានទៅសម្រេចបានការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីឱ្យបានពេញលេញបំផុត រួមទាំងការបណ្តុះបណ្តាលនៅទូទាំងប្រទេសកម្ពុជាដើម្បីលើកទឹកចិត្តឱ្យមានការប្រើប្រាស់ប្រព័ន្ធយ៉ាងស៊ីសង្វាក់ និងការប្រើប្រាស់តែប្រព័ន្ធប៉ុណ្ណោះដោយ SSWF ។

→ មិនថាប្រព័ន្ធណាដែលត្រូវបានយកមកប្រើប្រាស់ក្តី ប្រព័ន្ធនោះចាំបាច់ត្រូវគ្របដណ្តប់លើសង្វាក់ទាំងមូលនៃការថែទាំ ដោយក្នុងនោះស្មុំកូនគឺជាជម្រើសចុងក្រោយបំផុត ហើយការគាំទ្រក្រោយពីស្មុំកូន គឺជាទិដ្ឋភាពមួយនៅក្នុងការថែទាំនោះដែរ។

### *សំណួរមគ្គុទ្ទេសក៍សម្រាប់ការពិភាក្សា*

តើចាំបាច់ត្រូវមានអ្វីខ្លះដើម្បីចាប់ផ្តើមអភិវឌ្ឍផែនទីបង្ហាញផ្លូវដើម្បីភ្ជាប់ផ្នែកទាំងអស់នៃប្រព័ន្ធការពារកុមារ?

តើធ្វើដូចម្តេចទើបយើងអាចអនុវត្តការសិក្សាស៊ីជម្រៅដើម្បីកំណត់រកវិធីប្រសើរបំផុតដើម្បីបន្សុីការការគ្រប់គ្រងករណីឱ្យរលូនសម្រាប់ការថែទាំជំនួស និងស្មុំកូន? តើមានប្រព័ន្ធគ្រប់គ្រងករណីថ្មីៗ ឬទើបកើតមានដែលយូនីសេហ្វ និង/ឬអង្គភាពការពារកុមារដទៃទៀតនៅក្នុងសាកលលោកប្រើប្រាស់ឬទេ?

តើប្រព័ន្ធមួយចាំបាច់ត្រូវមានសមាសធាតុអ្វីខ្លះដើម្បីក្លាយជាប្រព័ន្ធប្រសើរបំផុតសម្រាប់ការធ្វើផែនការទុកដាក់អចិន្ត្រៃយ៍ និងគ្របដណ្តប់លើដំណើរការទាំងមូលនៃការថែទាំ ដោយក្នុងនោះស្មុំកូនគឺជាជម្រើសចុងក្រោយបំផុត ហើយការគាំទ្រក្រោយពេលស្មុំកូនគឺជាទិដ្ឋភាពមួយនៃការថែទាំនោះ?

តើការប្រែប្រួលនាពេលថ្មីៗនេះពាក់ព័ន្ធជាមួយមូលនិធិម្ចាស់ជំនួយមានប៉ះពាល់ទៅលើលទ្ធភាពអាចប្រើប្រាស់ប្រព័ន្ធ Primero ឬប្រព័ន្ធ OSCaR នៅក្នុងពេលអនាគតឬទេ ?

*<u>កំណត់សម្គាល់ការពិភាក្សា៖</u>*

**តើចាំបាច់ត្រូវការអ្វីខ្លះដើម្បីចាប់ផ្តើមអភិវឌ្ឍផែនទីបង្ហាញផ្លូវ៖**

- បង្កើតសៀវភៅណែនាំស្តីអំពីវិធីប្រើប្រាស់ប្រព័ន្ធ Primero និងដាក់ឱ្យមានសៀវភៅនេះអាចរកបានក្រៅប្រព័ន្ធអនឡាញ។ធ្វើឱ្យការអនុវត្តមានភាពខ្លីជាងមុន។
- ពង្រឹងសមត្ថភាពអ្នកប្រើប្រាសប្រព័ន្ធ Primero នៅកម្រិតរាជធានី/ក្រុង និងស្រុក ព្រមទាំងបង្កើនចំនួនអ្នកទទួលខុសត្រូវ។ ការងារនេះអាចមានមនុស្សទទួលខុសត្រូវចំនួន២-៣នាក់។
- កែលម្អមុខងារមួយចំនួនដូចជាមុខងារការថែទាំជំនួស និងស្មុំកូនជាដើម។ល។
- ពង្រឹងប្រព័ន្ធ M&E និងអនុវត្តប្រព័ន្ធនេះជាទៀងទាត់។
- បង្កើតក្រុមមួយដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធជាមួយការអនុវត្តដូចជាទិដ្ឋភាពបច្ចេកទេសនៅក្នុងការបញ្ចូលទិន្នន័យជាដើម ( ទីប្រឹក្សាបច្ចេកទេស និងអ្នកអនុវត្ត )
- ពង្រីកការអនុវត្ត និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីរបស់រដ្ឋាភិបាល និង NGOs ដោយឥតបង់ថ្លៃ ឬនៅក្នុងសមត្ថភាពដែលអាចឱ្យពួកគេប្រើប្រាស់បាន។
- បន្តប្រើប្រាស់ទម្រង់នៅលើក្រដាសដើម្បីបង្ការករណីបាត់បង់ទិន្នន័យនៅពេលប្រព័ន្ធមិនដំណើរការស្រួល

**របៀបដើម្បីធ្វើការសិក្សាស៊ីជម្រៅក្នុងការកំណត់រកវិធីប្រសើរបំផុតដើម្បីបន្សីការគ្រប់គ្រងករណីឱ្យរលូន៖**

- អនុវត្តការសិក្សាអង្កេតដើម្បីចាប់យកទិដ្ឋភាពចោះៗជាមួយអ្នកប្រើប្រាសប្រព័ន្ធគ្រប់គ្រងករណី។
- ចងក្រងជាឯកសារអំពីការអនុវត្តល្អបានទទួលពីបទពិសោធន៍របស់អ្នកអនុវត្តការថែទាំជំនួស និងស្មុំកូន ព្រមទាំងធ្វើការប្រៀបធៀបបទពិសោធន៍ទាំងនោះ។

**ការប្រែប្រួលនាពេលថ្មីៗនេះនៅក្នុងមូលនិធិម្ចាស់ជំនួយមានផលប៉ះពាល់មកលើប្រព័ន្ធ Primero ឬ OSCaR**

- មានការបាត់បង់ និងថយចុះមូលនិធិជាហេតុចាំបាច់ធ្វើឱ្យត្រូវឈប់ ឬត្រូវកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធ Primero ឬ OSCaR ។
- មានការថយចុះ ឬឈប់អនុវត្តសកម្មភាពពង្រឹងសមត្ថភាពអ្នកអនុវត្ត និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធ។

**ក្រុមទី ៤៖ ការផ្ទេរសេវាពី NGOs ទៅរដ្ឋាភិបាល**

*អនុសាសន៍សំខាន់ៗ*

→ បង្កើនភាពជាម្ចាស់របស់រដ្ឋាភិបាលលើកម្មវិធីថៃទាំជំនួស និងកម្មវិធីសុំកូនសម្រាប់និរន្តរភាពរយៈពេលវែង

→ ពិនិត្យរកលទ្ធភាពក្នុងការបង្កើតគំរូគណៈកម្មាធិការថៃទាំជំនួសសម្រាប់ប្រទេសកម្ពុជាតាមរយៈការប៉ាន់ប្រមាណរកវិធីកែសម្រួលគំរូទាំងនោះឱ្យស្របទៅតាមបរិបទក្នុងប្រទេសបច្ចុប្បន្ន។

*សំណួរមគ្គុទ្ទេសក៍សម្រាប់ការពិភាក្សា*

តើចាំបាច់ត្រូវមានសកម្មភាពអ្វីខ្លះដើម្បីបង្កើនភាពជាម្ចាស់របស់រដ្ឋាភិបាលលើកម្មវិធីការថៃទាំជំនួស និងសុំកូនសម្រាប់និរន្តរភាពរយៈពេលវែង ? តើវិធីសាស្ត្រដែលធ្វើឡើងជាជំហានៗអាចមានរូបភាពបែបណា ហើយតើរដ្ឋាភិបាល/NGO មានតួនាទីអ្វីខ្លះ ?

តើ NGOs និងរដ្ឋាភិបាលអាចសហប្រតិបត្តិការគ្នាដូចម្តេច ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រសម្រាប់ការផ្ទេរកម្មវិធីថៃទាំជំនួសដំណើរដោយ NGOs ទៅឱ្យរដ្ឋាភិបាល ? តើចាំបាច់ត្រូវឆ្លើយតបចំពោះចន្លោះខ្វះខាតផ្នែកការកសាងសមត្ថភាពអ្វីខ្លះ ?

តើគំរូគណៈកម្មាធិការថៃទាំជំនួសអាចដំណើរការដោយរបៀបណាសម្រាប់ប្រទេសកម្ពុជា ?

***កំណត់សម្គាល់ការពិភាក្សា៖***

- រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតថវិកាសម្រាប់ការអនុវត្ត។
- បង្កើតផែនការសកម្មភាពរួមគ្នាសម្រាប់ថ្នាក់ក្រោមជាតិដើម្បីអនុវត្ត និងពង្រឹងសមត្ថភាពសម្រាប់ការអនុវត្ត (មន្ត្រី)។
- ចាំបាច់ត្រូវមានយន្តការ M&E និងអនុវត្តយន្តការនេះជាទៀងទាត់។
- កំណត់រកមន្ត្រីរដ្ឋាភិបាលដើម្បីក្លាយជាអ្នកគ្រប់គ្រងករណី និងជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រងករណី។

**ក្រុមទី ៥៖ ការបង្កើតប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពប្រឆាំងជាមួយនឹងការប្រើប្រាស់ ICA បំពាន**

*អនុសាសន៍សំខាន់ៗ*

→ បញ្ឈប់រាល់ការព្រាង MoUs ការផ្តល់អាជ្ញាបណ្ណដល់ទីភ្នាក់ងារ ការទទួលពាក្យសុំពីឪពុកម្តាយចិញ្ចឹមសក្តានុពលជាជនបរទេស និងការកំណត់លក្ខណសម្បត្តិរបស់កុមារជាបុគ្គលក្នុងការដាក់ឱ្យសុំអន្តរប្រទេស ដោយត្រូវផ្តោតការយកចិត្តទុកដាក់មកលើការពង្រឹងដំណើរការសុំកូនក្នុងប្រទេសជំនួសវិញ។

→ បកស្រាយបញ្ជាក់ឱ្យច្បាស់ថា ប្រទេសកម្ពុជានៅតែបន្តបិទមិនដំណើរការ ICA។

→ បិទភ្ជិតគម្លាតរវាងគោលនយោបាយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រមរដ្ឋប្បវេណី ដើម្បីបន្ទឹងដំណើរការសុំកូនតាមផ្លូវច្បាប់ឱ្យរលូនដោយធានាឱ្យបានថា សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តការពារកុមារមានការបញ្ជាក់ជាក់លាក់អំពីសុំកូនដោយជនបរទេស។

→ បញ្ជាក់ឱ្យច្បាស់ថាក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តតែសម្រាប់ពលរដ្ឋកម្ពុជាដែលមានបំណងសុំកូនប៉ុណ្ណោះ។ ជនបរទេសដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានបំណងសុំកុមារកម្ពុជា គឺចាំបាច់ត្រូវយោងទៅតាមច្បាប់ ICA។

## *សំណួរមគ្គុទ្ទេសក៍សម្រាប់ការពិភាក្សា៖*

តើធ្វើដូចម្តេចទើបយើងអាចធានាឱ្យបានថា ចន្លោះខ្វះខាតផ្នែកច្បាប់ និងបញ្ហានានាដែលបានកំណត់ឃើញ ទាំងនៅក្នុងសុំកូនក្នុងប្រទេស និង ICA ត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព ក្នុងនោះរួមមាន

- ធ្វើបច្ចុប្បន្នភាពលើច្បាប់ ICA ឆ្នាំ ២០០៩ ដើម្បីឱ្យមានភាពអនុលោមតាមលិខិតបទដ្ឋានគតិយុត្តថ្មីៗស្តីពីសុំកូន?
- បកស្រាយបញ្ជាក់ឱ្យច្បាស់ថា ក្រមរដ្ឋប្បវេណីត្រូវអនុវត្តតែសម្រាប់ពលរដ្ឋកម្ពុជាដែលមានបំណងសុំកូនប៉ុណ្ណោះ ហើយជនបរទេស ចាំបាច់ត្រូវអនុលោមតាមច្បាប់ ICA?
- បង្ការកុំឱ្យមានការប្រតិបត្តិសុំកូនខុសច្បាប់ អំពើពុករលួយ និងការទូទាត់ប្រាក់លើកទឹកចិត្ត?
- ដោះស្រាយបញ្ហាកង្វះការចុះបញ្ជីកំណើតនៅមន្ទីរពេទ្យ សក្តានុពលដែលអាចកើតមានបណ្តាលមកពីការលុបចោលព័ត៌មានអត្តសញ្ញាណរបស់កុមារ ព្រមទាំងបញ្ហាដទៃទៀតពាក់ព័ន្ធជាមួយឯកសារអត្តសញ្ញាណតាមផ្លូវច្បាប់ និងការចុះបញ្ជីតាមផ្លូវច្បាប់?
- ធានាឱ្យមានការប្រតិបត្តិដោយបើកចំហ និងមានតម្លាភាព ក៏ដូចជាការផ្តន្ទាទោសចំពោះការរំលោភបំពាននៅក្នុងសុំកូន?
- តាមដាន និងបោះពុម្ពផ្សាយទិន្នន័យសុក្រឹតស្តីពីកុមារមានលក្ខណៈសមស្របសម្រាប់សុំកូន?

តើធ្វើដូចម្តេចទើបយើងអាចបញ្ឈប់រាល់ការសរសេរព្រាង MoUs ការផ្តល់អាជ្ញាបណ្ណដល់ទីភ្នាក់ងារ ការទទួលយកពាក្យសុំពីឪពុកម្តាយចិញ្ចឹមសក្តានុពលជាជនបរទេស និងការកំណត់លក្ខណសម្បត្តិសម្រាប់កុមារដើម្បីចូលរួមក្នុង ICA ប្រកបដោយប្រសិទ្ធភាពដោយផ្តោតជាជំនួសមកវិញលើការពង្រឹងដំណើរការសុំកូនក្នុងប្រទេស?

តើធ្វើដូចម្តេចទើបយើងអាចយកស្តង់ដាអន្តរជាតិនាពេលបច្ចុប្បន្នជាមូលដ្ឋានដើម្បីគាំទ្រដល់តម្រូវការក្នុងការពង្រឹងប្រព័ន្ធសុំកូនក្នុងប្រទេស ដើម្បីឈានទៅកាត់បន្ថយតម្រូវការងាកទៅប្រើប្រាស់ ICA?

ប្រទេសហ្គ័រតាម៉ាឡា គឺជាឧទាហរណ៍ដ៏ល្អនៃប្រទេសដែលមានប្រវត្តិប្រហាក់ប្រហែលកម្ពុជាដែលមានភាពមិនប្រក្រតីនៅក្នុង ICA ក្នុងយុគសម័យក្រោយជម្លោះ។ ពួកគេបានបិទកម្មវិធី ICA របស់ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញាទីក្រុងឡាអេ និងទទួលបានភាពអនុលោមតាមច្បាប់ ប៉ុន្តែពួកគេនៅតែបន្តបិទ ICA ស្របពេលដែលពួកគេបានជំរុញកម្មវិធីសុំកូនក្នុងប្រទេសរបស់ខ្លួន។ ខាងក្រោមនេះ គឺជាតារាងកំណែទម្រង់ដទៃទៀតរបស់ប្រទេសហ្គ័រតាម៉ាឡា ដែលអាចមានសារប្រយោជន៍សម្រាប់កម្ពុជា។ តើកម្ពុជាអាចបង្កើតផែនទីបង្ហាញផ្លូវស្រដៀងគ្នានេះបានឬទេ?

តារាង៖ ប្រព័ន្ធសុំកូននៅមុនពេលកំណែទម្រង់ធៀបជាមួយប្រព័ន្ធដែលបានកែទម្រង់រួចហើយបច្ចុប្បន្នក្នុងប្រទេសហ្គ័រតាម៉ាឡា (ប្រភព៖ Rotabi KS and Bromfield NF. (2017) *From Intercountry Adoption to Global Surrogacy: A Human Rights History and New Fertility Frontiers,* Abingdon: Routledge. p. 82.)

| **មុនកំណែទម្រង់ ឬប្រព័ន្ធចាស់** | **ប្រព័ន្ធកែទម្រង់រួចហើយ** |
|---|---|
| ការបោះបង់សិទ្ធិដោយស្ម័គ្រចិត្តដោយសារការី (អន្តរាគមន៍របស់មេធាវីឯកជន) | ការផ្តួចផ្តើមការប្រកាសលក្ខណសម្បត្តិអាចដាក់ឱ្យសុំបាន ធ្វើឡើងដោយអាជ្ញាធរកណ្តាលរបស់រដ្ឋាភិបាល (អន្តរាគមន៍ដោយអ្នកប្រកវិជ្ជាជីវៈរបស់រដ្ឋាភិបាល) |
| ការជ្រើសរើសកុមារដោយទីភ្នាក់ងារសុំកូនតាងនាមឱ្យឪពុកម្តាយជាសក្តានុពល | បុគ្គលិកសង្គមកិច្ច/អ្នកចិត្តសាស្ត្ររបស់រដ្ឋាភិបាលជ្រើសរើសកុមារដែលមានលក្ខណសម្បត្តិសមស្របនៅក្នុងដំណើរការផ្គូផ្គងកុមារជាមួយគ្រួសារជាលក្ខណៈប្រព័ន្ធដោយឈរលើព័ត៌មានបាន |

| | |
|---|---|
| | ពីការប៉ាន់ប្រមាណផ្នែកសង្គមដែលយកចិត្តទៅលើប្រវត្តិដោយឡែកៗ ជាពិសេសរបស់កុមារម្នាក់ៗ |
| ឆន្ទៈ ឬបំណងរបស់គ្រួសារចិញ្ចឹមជាសក្តានុពល គឺជាមានអាទិភាព | ឧត្តមប្រយោជន៍របស់កុមារ គឺជាអាទិភាព |
| សុំកូនអស់ថ្លៃចំណាយខ្ពស់ | មិនត្រូវអស់ថ្លៃចំណាយក្នុងសុំកូនឡើយ |
| គ្រួសារជនជាតិហ្វ័តាម៉ាឡា ត្រូវបានផាត់ចេញដោយហេតុថា ពួកគេពុំមានលទ្ធភាពបង់ថ្លៃដើម្បីចូលរួមក្នុងប្រព័ន្ធដែលអស់ចំណាយខ្ពស់នោះឡើយ | បច្ចុប្បន្នគ្រួសារជនជាតិហ្វ័តាម៉ាឡា គឺជាអាទិភាពយោងតាមគោលការណ៍អនុលោមភាពនៃ HCIA ដែលមិនត្រូវអស់ចំណាយអ្វីទាំងអស់ |
| មិនមានការសិក្សាផ្នែកសង្គមសេដ្ឋកិច្ចលើឪពុកម្តាយជាសក្តានុពលទេ | ការប៉ាន់ប្រមាណផ្នែកចិត្តសាស្ត្រ ច្បាប់ និងសង្គមសេដ្ឋកិច្ចទៅលើឪពុកម្តាយជាសក្តានុពល |
| មិនមានតម្រូវឱ្យពិនិត្យតាមដានក្រោយពេលសុំកូន | មានការតម្រូវឱ្យពិនិត្យតាមដានក្រោយសុំកូន |
| ពុំមានដេតាបេសអំពីកុមារដែលបានសុំ | បច្ចុប្បន្នអាជ្ញាធរកណ្តាល មានអង្គភាពមួយផ្តោតការយកចិត្តទុកដាក់ក្នុងការប្រមូល និងគ្រប់គ្រងទិន្នន័យនេះ អនុលោមតាមស្តង់ដា HCIA |
| មិនមានលទ្ធភាពកំណត់ទីតាំងគ្រួសារកំណើតរបស់កុមារ ដោយផ្អែកលើព័ត៌មានផ្លូវការឡើយ | កុមារដែលបានសុំ នឹងមានលទ្ធភាពដឹងអំពីគ្រួសារកំណើតតាមរយៈការរក្សាកំណត់ត្រាត្រឹមត្រូវ |

តើធ្វើដូចម្តេចទើបយើងអាចធានាតម្លាភាព និងគណនេយ្យភាពនៅក្នុងគ្រប់ដំណើរការសុំកូនទាំងអស់? តើនរណានឹងទទួលខុសត្រូវប្រសិនមានបញ្ហានៅពេលអនាគតពាក់ព័ន្ធជាមួយកូនដែលបានសុំ?

*កំណត់សម្គាល់ការពិភាក្សា៖*

**បកស្រាយបញ្ជាក់ឱ្យច្បាស់ថា កម្ពុជាបន្តបិទសម្រាប់ ICA។**

- កម្ពុជាបើកសម្រាប់ ICA។

**ធ្វើបច្ចុប្បន្នភាពច្បាប់ ICA ឆ្នាំ ២០០៩ ដើម្បីឱ្យមានភាពអនុលោមតាមលិខិតបទដ្ឋានគតិយុត្តថ្មីៗទាំងអស់ស្ដីពីសុំកូន ?**

- រាល់បច្ចុប្បន្នភាពទៅលើច្បាប់ ICA គួរធ្វើឡើងបន្ទាប់ពីច្បាប់កិច្ចការពារកុមារត្រូវបានអនុម័ត ព្រោះច្បាប់ទាំងពីរនេះអាចមានទំនាក់ទំនងគ្នា។

**បកស្រាយបញ្ជាក់ឱ្យច្បាស់ថាក្រមរដ្ឋប្បវេណីអាចយកទៅអនុវត្តបានសម្រាប់តែពលរដ្ឋកម្ពុជាដែលមានបំណងចង់សុំកូនប៉ុណ្ណោះ ហើយជនបរទេសចាំបាច់ត្រូវយោងទៅលើច្បាប់ ICA ?**

- ទាក់ទងជាមួយក្រមរដ្ឋប្បវេណី និងច្បាប់ ICA យើងគួរមានក្រុមការងារមួយរវាងក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបកស្រាយបញ្ជាក់ឱ្យច្បាស់ ថាតើនរណាអាចសុំកូនតាមរយៈក្រមរដ្ឋប្បវេណីបាន។
- មានកំណត់ពន្យល់ឆ្នាំ ២០១៦ ស្ដីពីក្រមរដ្ឋប្បវេណីពាក់ព័ន្ធជាមួយថាតើនរណាអាចសុំកូនបាន ប៉ុន្តែកំណត់ពន្យល់នេះ ពុំមានលក្ខណៈទូលំទូលាយ និងរឹងមាំគ្រប់គ្រាន់នោះទេ។

**ការទប់ស្កាត់ការត្រលប់ទៅរកប្រតិបត្តិសុំកូនខុសច្បាប់ អំពើពុករលួយ និងការផ្ដល់កម្រៃលើកទឹកចិត្តឡើងវិញ ?**

- សម្រាប់សុំកូនតាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
    - សុំកូនក្នុងប្រទេសពុំចាំបាច់ត្រូវចំណាយអ្វីនោះឡើយ។
- សម្រាប់ ICA (ICAA)
    - ប្រកាសរួមរវាងក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**ដោះស្រាយកង្វះការចុះបញ្ជីកំណើតតាមមន្ទីរពេទ្យ សក្ដានុពលក្នុងការលុបចោលព័ត៌មានកំណត់អត្តសញ្ញាណរបស់កុមារនៅពេលក្រោយមក ព្រមទាំងបញ្ហានានាដែលមានពាក់ព័ន្ធជាមួយឯកសារអត្តសញ្ញាណតាមផ្លូវច្បាប់ និងការចុះបញ្ជី ?**

- សម្រាប់កុមារដែលកើតក្នុងមន្ទីរពេទ្យ ចាំបាច់ត្រូវចេញសៀវភៅលឿងភ្លាមៗ
- មន្ទីរពេទ្យគួរទំនាក់ទំនងទៅអាជ្ញាធរមូលដ្ឋានសម្រាប់អ្នកដែលចង់បោះបង់កូនរបស់ខ្លួន

**ជានាឱ្យមានការប្រតិបត្តិប្រកបដោយតម្លាភាព ក៏ដូចជាការផ្តន្ទាទោសសម្រាប់ការរំលោភបំពានសុំកូន ?**

- ចែងនៅក្នុងច្បាប់ ICA  និងឯកសារច្បាប់ដែលមានសុពលភាពដទៃទៀតក្នុងប្រទេសកម្ពុជា

**តាមដាន និងបោះពុម្ពផ្សាយទិន្នន័យដែលមានសុពលភាពស្តីពីកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូន?**

- កត់ត្រា និងបោះពុម្ពផ្សាយចំនួនកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូន (សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស)